## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងារ
# ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៥
# និងទិសដៅឆ្នាំ២០១៦



ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្ងៃទី១២ធ្នូ ឆ្នាំ២០១៥នៅសាលមហោស្រពកោះពេជ្រ

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ**

www.ncct.gov.kh





**អនុសាសន៍ ០៤ ចំណុច**
**របស់ សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

ថ្លែងក្នុងទិវាជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៥ នៅសាលមហោស្រព
នៃមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌ កោះពេជ្រ

១-រាជរដ្ឋាភិបាលកម្ពុជាខិតខំប្រឹងប្រែងជម្នះឧបសគ្គដោះស្រាយបញ្ហានិងការលំបាកគ្រប់បែបយ៉ាងគឺដើម្បីប្រជាជនកម្ពុជា និងមនុស្សជាតិឲ្យទទួលបាននូវការគោរពសិទ្ធិសេចក្តីថ្លៃថ្នូរនិងផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។

២-រាជរដ្ឋាភិបាលកម្ពុជា បេជ្ញាចិត្តប្រយុទ្ធប្រឆាំងដាច់ខាតអំពើជួញដូរមនុស្សជាពិសេសលើស្ត្រីនិងកុមារ និងរួមសហការជាមួយបណ្តាប្រទេសពាក់ព័ន្ធនានាក្នុងតំបន់និងលើពិភពលោកដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស។

៣-បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងការអនុវត្តច្បាប់និងអនុសញ្ញាកតិកាសញ្ញាអន្តរជាតិច្បាប់ជាតិ អនុស្សរណៈនិងកិច្ចព្រមព្រៀងទ្វេភាគីនិងពហុភាគីនិងផែនការសកម្មភាពរួមព្រមទាំងផែនការជាតិនិងបទដ្ឋានគតិយុត្តទាំងឡាយឲ្យទទួលបានប្រសិទ្ធភាពខ្ពស់។

៤-គាំទ្រនិងជំរុញកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ឲ្យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញភារកិច្ចឲ្យបានជោគជ័យ។



## វិធានការ ០៦ចំណុច
## របស់សម្តេច ក្រឡាហោម ស ខេង
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ

ប្រកាសថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៥

១. គណៈកម្មាធិការជាតិ គ.ជ.ប.ជ គ្រប់លំដាប់ថ្នាក់ គប្បីពង្រឹងការដឹកនាំ សម្របសម្រួលប្រមូលផ្តុំកម្លាំង និងបញ្ជាឲ្យបានហ្មត់ចត់ដើម្បីឲ្យមន្ទីរអង្គភាពជំនាញទាំងឡាយមានសកម្មភាពតាមមុខសញ្ញារៀងៗខ្លួន និងត្រូវធ្វើរបាយការណ៍ឲ្យបានទៀងទាត់ វាយតម្លៃលើសភាពការណ៍ទូទៅសភាពការណ៍ជនល្មើស និងការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ព្រមទាំងឆ្លុះបញ្ចាំងចំណុចសេសសល់ ភាពប្រឈមនានាឲ្យបានច្បាស់លាស់ និងលើកទិសដៅកែលម្អ។

២. ធ្វើផែនការអនុវត្តឲ្យបានច្បាស់លាស់ ដោយត្រូវគ្រោងទុកថវិកា សម្ភារ មធ្យោបាយឲ្យបានគ្រប់គ្រាន់ក្នុងការអនុវត្តផែនការ សកម្មភាព និងជំនាញរបស់អង្គភាព ស្ថាប័នរៀងៗខ្លួនដោយពង្រឹងកិច្ចសហការការចូលរួមគាំទ្រគ្នាទៅវិញទៅមកនិងកិច្ចសហការជាមួយដៃគូដែលកំពុងធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

៣. ពង្រឹងរបៀបរបបការងារ និងរៀបចំកិច្ចប្រជុំឲ្យបានទៀងទាត់តាមបណ្តាក្រុមការងារអន្តរក្រសួងស្ថាប័ន និងតាមបណ្តាថ្នាក់នៃគណៈកម្មាធិការជាតិដោយដាក់ចេញនូវវិធានការចាំបាច់នានា ដើម្បីឆ្លើយតបឲ្យបានទាន់ពេលវេលាទៅនឹងបញ្ហា និងភាពប្រឈមដែលកើតមាន។

៤. ពង្រឹងការតាមដាន ត្រួតពិនិត្យជាប្រចាំ ដើម្បីប្រសិទ្ធភាពការងារ។

៥. សហការជាមួយអគ្គលេខាធិការដ្ឋាន បណ្តុះបណ្តាល ពង្រឹងសមត្ថភាពមន្ត្រី អនុវត្តន៍ដោយបង្កលក្ខណៈផ្តល់ការគាំទ្រ និងលើកទឹកចិត្ត ដើម្បីបានបំពេញភារកិច្ចល្អប្រសើរ។

៦. អគ្គលេខាធិការដ្ឋានត្រូវបន្តសម្របសម្រួល ប្រមូលផ្តុំព័ត៌មាន តាមដានសភាពការណ៍ និងតាមដានត្រួតពិនិត្យការងារតាមបណ្តាថ្នាក់នៃរចនាសម្ព័ន្ធបន្តទៀត ដោយធ្វើរបាយការណ៍ជូនគណៈកម្មាធិការជាតិ និងរាជរដ្ឋាភិបាលភិបាលឲ្យទាន់ពេលវេលា និងស្នើឡើងនូវវិធានការនានា តាមការចាំបាច់៕

# មាតិកា

លេខទំព័រ


**១. សភាពការណ៍ទូទៅ....................១**

**២. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៥....................២**

**២.ក. ការងារផ្នែកច្បាប់ គោលនយោបាយជាតិ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ.................... ៥**

**២.ខ-ការអនុវត្តយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស.................... ៨**

**២.ខ.១. ការងារបង្ការ ទប់ស្កាត់....................១១**

២.ខ.១.១. ការបង្ការ ទប់ស្កាត់ តាមរយៈការអប់រំផ្សព្វផ្សាយ....................១១

២.ខ.១.២. ការអនុវត្តវិធានការបង្ការ ទប់ស្កាត់....................១២

២.ខ.១.៣.ការងារបង្ការទប់ស្កាត់តាមវិធានការជំនាញ....................១២

២.ខ.១.៤. បង្ការទប់ស្កាត់តាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរ និងជនបរទេស....................១៣

**២.ខ.២-ការគ្រប់គ្រងលំហូរពលករចំណាកស្រុក....................១៤**

**២.ខ. ៣. ការងារ ការពារ ស្តារនីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្តន៍.១៨**

២.ខ.៣.១. ការងារការពារ និងស្តារនីតិសម្បទាជនរងគ្រោះ....................១៨

២.ខ. ៣.២-ការងារទេសន្តរប្រវេសន៍....................១៩

**២.ខ.៤. ការងារអនុវត្តច្បាប់....................២០**

២.ខ.៤.១.ការងារបង្ក្រាបនិងសង្គ្រោះជនរងគ្រោះ....................២០

២.ខ.៤.២. ការងារអនុវត្តនីតិវិធីច្បាប់....................២២

២.ខ.៤.៣. សកម្មភាពបង្ក្រាបនៅតាមរាជធានី ខេត្ត....................២៤

**២.ខ.៥. ការងារកិច្ចការយុត្តិធម៌....................២៥**

**២.ខ.៦. ការងារសហប្រតិបត្តិការអន្តរជាតិ....................២៨**

**២.ខ.៧. ការងារកុមារ....................៣២**

**២.គ. ការងារសម្របសម្រួល....................៣៣**

**២ឃ. ការលើកកម្ពស់សមត្ថភាព.................... ៣៩**

**៣. ការសន្និដ្ឋាន និងវាយតម្លៃ....................៤២**

**៣.១. ចំណុចខ្លាំង.................... ៤២**

**៣.២. ចំណុចសេសសល់ និងបញ្ហាប្រឈម .................... ៤៣**

**៤. ទិសដៅ ឆ្នាំ២០១៦.................... ៤៥**

**ឧបសម្ព័ន្ធ**....................ចាប់ពីទំព័រ ៤៨

# របាយការណ៍បូកសរុប
# សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទប្រចាំឆ្នាំ២០១៥និងទិសដៅ ឆ្នាំ ២០១៦

( គិតចាប់ពីថ្ងៃទី ០១ ខែ មករា ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥ )

## ១. សភាពការណ៍ទូទៅ

ស្ថានភាពនយោបាយ សេដ្ឋកិច្ចសង្គមក្នុងពិភពលោកមានការប្រែប្រួលជាប្រចាំ ហើយល្បឿននៃការវិវត្តរបស់វិស័យអប់រំ និងវិទ្យាសាស្ត្រមានការរីកចម្រើនជាទូទៅ តែអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនទាំងឡាយបាន និងកំពុងតែមានសកម្មភាពយ៉ាងស្រួចស្រាល់គួរឲ្យបារម្ភ ដែលនាំឲ្យប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូរ និងបង្កវិនាសកម្មយ៉ាងអយុត្តិធម៌ទៅលើមនុស្សជាច្រើន ដែលជាជនរងគ្រោះ។ រដ្ឋាភិបាលនៃប្រទេសទាំងឡាយផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះបញ្ហាសន្តិសុខ សុវត្ថិភាព ប្រទេសជាតិ ដែលក្នុងនោះ គឺការបង្កើនកិច្ចសហការក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ដែលបាន និងកំពុងតែបំផ្លាញដល់សេចក្តីសុខរបស់មនុស្សជាតិយ៉ាងធ្ងន់ធ្ងរ ។

សកលភាវូបនីយ៍កម្ម(Globalization) នៃបច្ចេកទេស វិទ្យាសាស្ត្រ និងព័ត៌មានវិទ្យា គឺជាមធ្យោបាយដ៏ស័ក្តិសិទ្ធិមួយដែលធ្វើឲ្យប្រទេស និងប្រជាជនរស់នៅលើពិភពលោក បានខិតជិតគ្នា និងអាចទំនាក់ទំនងសហការគ្នាយ៉ាងល្អប្រសើរ ។ តែទន្ទឹមនឹងនោះ បច្ចេកវិទ្យា ក៏បាននិងកំពុងតែបម្រើឲ្យក្រុមឧក្រិដ្ឋជនផងដែរ ហេតុនេះ ទើបនាំឲ្យមានភាពប្រទាញប្រទង់ និងច្របូកច្របល់ដល់ការសម្រេចចិត្តរបស់ប្រជាពលរដ្ឋ ជាពិសេសពលករដែលព្យាយាមស្វែងរកការងារនៅក្រៅប្រទេស ។ ពលករជាច្រើន បានសម្រេចចិត្តចាកចេញទៅតាមមេខ្យល់ ដោយប្រថុយប្រថាន បើទោះបីជាដឹងថា ពួកគាត់ត្រូវប្រឈមនឹងច្បាប់ និងភាពរងគ្រោះក៏ដោយ តែគាត់ក៏មិនអាចរង់ចាំដំណោះស្រាយផ្លូវច្បាប់ ដែលយឺតយូរ និងមិនអាចឆ្លើយតបនឹងតម្រូវការនោះដែរ ។ ទោះបីជាមានមនុស្សមួយចំនួន បាន និងកំពុងតែរងគ្រោះក៏ដោយ ក៏ពួកគាត់មើលឃើញថាមានមនុស្សជាច្រើន ដែលហ៊ានប្រថុយប្រថាន ក៏អាចមានសំណាង និងបានទទួលផលល្អប្រសើរដែរ ។ នេះគឺជាមូលហេតុ ដែលសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មិនទាន់ទទួលបានជោគជ័យ តាមការរំពឹងទុក ។

អស់រយៈពេលជិតបួនទសវត្សរ៍កន្លងមក ព្រះរាជាណាចក្រកម្ពុជាបានត្រឡប់មកទទួលកិត្តិយសជាថ្មីជាប្រទេសអច្ឆរិយៈមួយ ដែលអាចស្តារភាពខ្ទេចខ្ទាំទាំងស្រុងនៃរចនាសម្ព័ន្ធរូបវ័ន្ត និងរចនាសម្ព័ន្ធអរូបីនៃ

ធនធានមនុស្ស ដែលបន្សល់ទុកពីរបបប្រល័យពូជសាសន៍ និងភ្នក់ភ្លើងសង្គ្រាមស៊ីវិលបាន ថែមទាំងធ្វើឲ្យវប្បធម៌ អរិយធម៌ ប្រពៃណី ទំនៀមទម្លាប់ដ៏ល្អផូរផង់ មានពន្លឺដ៏ត្រចះត្រចង់ឡើងវិញ ប្រកបដោយកិត្តិយសដ៏ឧត្តុង្គឧត្តម និងមានឈ្មោះបោះសំលេងល្បីរន្ទឺជាថ្មីលើឆាកអន្តរជាតិ ។ ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយកិត្តិបណ្ឌិត និងគុណធម៌ របស់**សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឥស្សរជនជាអ្នកដឹកនាំទាំងឡាយគ្រប់លំដាប់ថ្នាក់ក្នុងរាជរដ្ឋាភិបាលកម្ពុជា ដែលរួមកម្លាំងគ្នាជាធ្លុងមួយ ខិតខំការពារ និងអភិវឌ្ឍន៍គ្រប់វិស័យ ធ្វើឲ្យនាវាកម្ពុជាឈានដំណើរចេញពីភាពខ្ទេចខ្ទាំ លំបាក តោកយ៉ាក ឆ្ពោះទៅកាន់ភាពរីកចម្រើន ប្រកបដោយភាពសុខដុមរមនា សម្រាប់ប្រជាពលរដ្ឋទូទាំងប្រទេស ទាំងនៅទីក្រុង និងជនបទ។ គោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលក្នុងកំណែទម្រង់គ្រប់វិស័យ បាននាំមកនូវការប្រែប្រួលល្អប្រសើរ និងផ្តល់នូវភាពជឿជាក់ ពីបណ្តាក្រុមហ៊ុនធំៗជាច្រើនដែលបាននាំគ្នាមកដាក់ទុនវិនិយោគ លើវិស័យគន្លឹះជាច្រើន ដូចជាវិស័យធនាគារហិរញ្ញវត្ថុ ទេសចរណ៍ ឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម អប់រំ សំណង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តគមនាគមន៍ដែលជាសរសៃឈាមសេដ្ឋកិច្ច និងវិស័យសំខាន់ៗមួយចំនួនទៀត ដែលការវិនិយោគទាំងនេះបានជួយបង្កើនការងារ មុខរបរ និងប្រាក់ចំណូលកាន់តែខ្ពស់ដល់ប្រជាពលរដ្ឋកម្ពុជា ឲ្យអាចរស់នៅបានក្នុងជីវភាពល្អប្រសើរជាបណ្តើរៗ គួរឲ្យមោទនៈ ។

ទោះបីជាយ៉ាងនេះក្តី ក្នុងឆ្នាំ២០១៤-២០១៥ ប្រជាជនកម្ពុជាមួយចំនួន នៅតែព្យាយាមស្វែងរកការធ្វើចំណាកស្រុកឆ្លងដែន ដើម្បីស្វែងរកការងារ មុខរបរ ឬការតាំងទីលំនៅឯក្រៅប្រទេស ទាំងតាមប្រព័ន្ធស្របច្បាប់ និងមិនស្របច្បាប់ ដែលនាំឲ្យមានជនទេសន្តរប្រវេសន៍មួយចំនួន នៅតែទទួលរងគ្រោះដោយអំពើល្មើសផ្សេងៗ រាប់ទាំងអំពើជួញដូរមនុស្ស ពិសេស អំពើជួញដូរពលកម្ម និងផ្លូវភេទតាមរូបភាពផ្សេងៗ។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បាននិងកំពុងបន្តបេសកកម្មរបស់ខ្លួន យ៉ាងមមាញឹក ក្រោមការដឹកនាំផ្ទាល់របស់ **សម្តេចក្រឡាហោម ស ខេង**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ និងមានការជំរុញលើកទឹកចិត្តពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឲ្យបណ្តាក្រសួង ស្ថាប័ន សង្គមស៊ីវិលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហគមន៍អន្តរជាតិ អង្គការជាដៃគូក្នុងស្រុក និងក្រៅស្រុក សមត្ថកិច្ចគ្រប់ស្ថាប័ន គ្រប់ជាន់ថ្នាក់ រឹតតែប្រឹងប្រែង និងយកចិត្តទុកដាក់កាន់តែខ្លាំងក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ទៅតាមមុខសញ្ញា ដើម្បីលុបបំបាត់នូវសកម្មភាពបទល្មើសពាក់ព័ន្ធទាំងឡាយ ដែលនាំឲ្យមានអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចលើកម្លាំងពលកម្មកុមារ និងជួញដូរផ្លូវភេទជាដើម ។

បន្ទាប់ពីបានប្រកាសជាផ្លូវការគណៈកម្មាធិការជាតិ នាខែកុម្ភៈ ឆ្នាំ២០១៥រួចមក អគ្គលេខាធិការដ្ឋានបានចាប់ផ្តើមពង្រឹងរចនាសម្ព័ន្ធ និងធនធានគ្រប់កម្រិត ដើម្បីឲ្យគ្រប់ក្រសួង ស្ថាប័ន និងរាជធានីខេត្ត មានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញភារកិច្ចប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទៅតាមយុទ្ធសាស្ត្រគ្រោងទុក ។

ឆ្នាំ២០១៥ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានផ្តោតការយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពមន្ត្រីគ្រប់ថ្នាក់នៃរចនាសម្ព័ន្ធ ជាពិសេស មន្ត្រីអនុវត្តន៍ច្បាប់ និងការពង្រីកការយល់ដឹង និងដាស់តឿនអំពីបញ្ហាជួញដូរមនុស្សដល់ប្រជាពលរដ្ឋ ដោយចាត់តាំងការចុះផ្សព្វផ្សាយតាមគ្រប់រូប

ភាព ការដាក់បញ្ចូលខ្លឹមសារស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ទៅតាមវេទិកាសាធារណៈ សិក្ខាសាលា ការអប់រំផ្ទាល់ដល់សិស្សានុសិស្ស យុទ្ធនាការទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ជាដើម ។ លើសពីនេះទៅទៀត គណៈកម្មាធិការជាតិ តាមរយៈអគ្គលេខាធិការដ្ឋាន បានបញ្ចប់គោលការណ៍ណែនាំថ្នាក់ជាតិ "ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីទទួលបានសេវាសមស្រប" ដើម្បីជំរុញការអនុវត្តទៅតាមស្តង់ដាររួមមួយ ទាំងនៅក្នុង និងក្រៅប្រទេស ការជួយធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ការរៀបចំប្រព័ន្ធទំនាក់ទំនងព័ត៌មានតាមបច្ចេកវិទ្យា ដើម្បីពង្រឹងកិច្ចសហការក្នុងការផ្តល់ព័ត៌មានឲ្យបានឆាប់រហ័ស ការធ្វើអន្តរាគមន៍ទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរ តាមបណ្តាមុខសញ្ញាគោលដៅដើម្បីទប់ស្កាត់ភាពរងគ្រោះដល់ជនងាយរងគ្រោះ និងជំរុញការផ្តន្ទាទោសជនសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស ទៅតាមផ្លូវច្បាប់។

**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) បានដាក់ចេញនូវវិធានការ ០៦ចំណុច សំដៅពង្រឹងកិច្ចសហការ និងការទទួលខុសត្រូវ របស់ក្រសួងស្ថាប័នជាសមាជិក ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលវិធានការនេះ បានធ្វើការផ្សព្វផ្សាយបន្តដល់គ្រប់គណៈកម្មាធិការរាជធានី/ខេត្ត ទាំង២៥ និងផ្សព្វផ្សាយទូលាយដល់គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញអនុវត្តឲ្យចំគោលដៅ និងមានប្រសិទ្ធភាព ។

ទន្ទឹមគ្នានេះដែរ នៅក្នុងការប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅថ្ងៃទី១២ធ្នូឆ្នាំ២០១៥ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្ញើសារដល់ជនរួមជាតិ ជាអនុសាសន៍០៤ចំណុច សម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការអនុវត្តទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដែលមានខ្លឹមសារផ្តោតជាសំខាន់ទៅលើការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការគោរពសិទ្ធិមនុស្ស ការប្រឆាំងដាច់ខាតនូវអំពើជួញដូរមនុស្ស ដោយពង្រឹងកិច្ចសហការរវាងផ្ទៃក្នុងជាតិ និងជាមួយអន្តរជាតិ ដើម្បីអនុវត្តនូវរាល់អនុសញ្ញា កតិកាសញ្ញា កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគីដែលកម្ពុជាបានហត្ថលេខា និងផែនការដែលមានស្រាប់ និងរៀបចំបន្តជាមួយប្រទេសពាក់ព័ន្ធដែលមិនទាន់មាន ព្រមទាំងគាំទ្រជំរុញកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ ឲ្យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញភារកិច្ចឲ្យបានជោគជ័យ ។

ឆ្នាំ២០១៥ គឺជាឆ្នាំនៃការកសាងមូលដ្ឋានគ្រឹះ សម្រាប់ការពង្រឹងគណៈកម្មាធិការជាតិ និងប្រសិទ្ធភាពការងារ ក្នុងនោះគឺ ការកសាងបទដ្ឋានគតិយុត្ត រចនាសម្ព័ន្ធនៃយន្តការជាតិដែលទូលំទូលាយ និងគ្រប់កម្រិត ការបណ្តុះបណ្តាលពង្រឹងសមត្ថភាព មន្ត្រីអនុវត្តន៍គ្រប់ថ្នាក់ ការពង្រឹងកិច្ចសហការជាមួយដៃគូពាក់ព័ន្ធ ជាតិ និងអន្តរជាតិ និងការជំរុញការអនុវត្តឲ្យទទួលបានលទ្ធផលខ្ពស់តាមការរំពឹងទុក ។

ជាលទ្ធផលនៃការអនុវត្តភារកិច្ច របស់គ្រប់បណ្តាថ្នាក់នៃរចនាសម្ព័ន្ធ ក្នុងគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងឆ្នាំ ២០១៥ មានដូចខាងក្រោម៖

## ២. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៥

នៅក្នុងឆ្នាំ២០១៥ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានអនុវត្ត យ៉ាងសកម្មដោយមានការចូលរួម និងកិច្ចសហការពីបណ្តាក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សមត្ថកិច្ចគ្រប់ស្ថាប័ននៅគ្រប់ថ្នាក់ រួមទាំងមានការចូលរួមពីទីភ្នាក់ងារអង្គការសហប្រជាជាតិ បណ្តាអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិជាច្រើន ដែលមានទិសដៅប្រឆាំងការជួញដូរមនុស្ស ការរត់ពន្ធ ការកេងប្រវ័ញ្ចកម្លាំងពលកម្មមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។

ដើម្បីជំរុញឲ្យការប្រមូលព័ត៌មាន កាន់តែមានភាពទូលំទូលាយ និងទាន់ពេលវេលា អគ្គលេខាធិការដ្ឋានបានបង្កើតប្រព័ន្ធបញ្ជូនព័ត៌មាន តាមរយៈប្រព័ន្ធអេឡិកត្រូនិកមានដូចជាប្រព័ន្ធតេលេក្រាម (Telegram) មេស៊ិនជ័រ (Messenger) អ៊ីមែល (Email) ទូរស័ព្ទ (Telephone) និងបានធ្វើការផ្សព្វផ្សាយអំពីសកម្មភាពរបស់គណៈកម្មាធិការជាតិ និងតាមបណ្តារាជធានី-ខេត្ត តាមប្រព័ន្ធវិបសាយ (Website) ទ្វីតធ័រ(Twitter) និងហ្វេសប៊ុក (Facebook) ថែមទៀត ដោយធានានូវភាពងាយស្រួល និងទាន់ពេលវេលា ។ ប្រព័ន្ធទាំងនេះត្រូវបានបើកឲ្យប្រើប្រាស់ដើម្បីជួយសម្រួលដល់ការប្រមូលព័ត៌មាន និងបានបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុក ក្នុងអគ្គលេខាធិការដ្ឋាន និងថ្នាក់រាជធានី ខេត្ត ឲ្យចេះប្រើប្រាស់ដើម្បីទំនាក់ទំនងគ្នា ។

តាមរយៈការផ្តល់ព័ត៌មាន ដែលទទួលបានពីក្រុមការងារអន្តរក្រសួងចំនួន ០៦ អង្គភាពស្ថាប័នចំនួន២២ រាជធានីខេត្ត ២៥ អង្គការដៃគូជាតិអន្តរជាតិមួយចំនួន គួបផ្សំនឹងព័ត៌មានជាតិ និងអន្តរជាតិសំខាន់ៗ មួយចំនួនទៀត យើងបានរកឃើញថាៈ

- ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ត្រូវបានរកឃើញជាច្រើនករណី ជាពិសេសតាមរូបភាពទេសន្តរប្រវេសន៍ ទាំងទេសន្តរប្រវេសន៍ស្វែងរកការងារ ទាំងទេសន្តរប្រវេសន៍ស្វែងរកគូស្រករនៅក្រៅប្រទេស ទាំងតាមប្រព័ន្ធស្របច្បាប់ ទាំងមិនស្របច្បាប់។
- ជនរងគ្រោះត្រូវបានសង្គ្រោះជាបន្តបន្ទាប់ ខ្លះត្រូវគេចាប់បញ្ជូនមកកម្ពុជាវិញ ខ្លះមកដោយខ្លួនឯង ឬក្រុមហ៊ុនដោយមានស្ថានទូត និងអង្គការដៃគូនៅក្រៅប្រទេសជួយសម្របសម្រួលកិច្ចសហការជាមួយអាជ្ញាធរ និងសមត្ថកិច្ចនៃប្រទេសដែលមានជនរងគ្រោះកម្ពុជាស្ថិតនៅ ។
- ការឆ្លើយតបនៅមិនទាន់មានលក្ខណៈជាប្រព័ន្ធហើយនៅមានបញ្ហាសេសសល់ជាច្រើនដែលត្រូវការការខិតខំបន្តទៀត ដូចជាខ្វះការតាមដានស្ថានភាពជនរងគ្រោះបន្ត បន្ទាប់ពីត្រូវបានបញ្ជូនត្រឡប់ទៅគ្រួសារ ឬសហគមន៍ ការសិក្សាអំពីការត្រឡប់ទៅធ្វើទេសន្តរប្រវេសន៍ជាថ្មី ការស្រាវជ្រាវលើបណ្តឹងរបស់ជនរងគ្រោះដើម្បីទាមទារយុត្តិធម៌ សំណងរដ្ឋប្បវេណី ...ជាដើម ។

## ២.ក. ការខារផ្នែកច្បាប់ គោលនយោបាយជាតិ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

ក្នុងឆ្នាំ២០១៥នេះ ដើម្បីបំពេញឲ្យសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជរដ្ឋាភិបាល គណៈកម្មាធិការជាតិ គ.ជ.ប.ជ និងក្រសួង អង្គភាពពាក់ព័ន្ធមួយចំនួន បានដាក់ចេញនូវសេចក្តីសម្រេច គោលការណ៍ វិធានការ មួយចំនួន ដូចខាងក្រោម៖

- **គណៈកម្មាធិការជាតិ (គ.ជ.ប.ជ) បានចេញសេចក្តីសម្រេចបង្កើតក្រុមការងារចំនួន ០៦ គឺ៖**

(១). សេចក្តីសម្រេចលេខ០០៥/១៥ស.សរ ចុះថ្ងៃទី២១ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពក្រុមការងារបង្ការទប់ស្កាត់ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ។

(២). សេចក្តីសម្រេចលេខ០៧៣/១៥.ស.ស.រ ចុះថ្ងៃទី២៩ខែកញ្ញាឆ្នាំ២០១៥ស្តីពីការតែងតាំងសមាសភាពក្រុមការងារការពារជនរងគ្រោះ ដឹកនាំដោយក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ។

(៣). សេចក្តីសម្រេចលេខ០៧១.១៥ស.ស.រ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពក្រុមការងារអនុវត្តច្បាប់ ដឹកនាំដោយ អគ្គស្នងការដ្ឋាននគរបាលជាតិ

(៤). សេចក្តីសម្រេចលេខ០៦៩/១៥ស.សរ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពក្រុមការងារយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ។

(៥). សេចក្តីសម្រេចលេខ០៧០/១៥ស.ស.សរ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពក្រុមការងារទេសន្តរប្រវេសន៍ ដឹកនាំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

(៦). សេចក្តីសម្រេចលេខ០៧២/១៥ស.ស.រ ចុះថ្ងៃទី២៩ខែកញ្ញាឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពក្រុមការងារសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយក្រសួងកិច្ចការនារី ។

- **គណៈកម្មាធិការជាតិ (គ.ជ.ប.ជ)** បានចេញសេចក្តីសម្រេចលេខ០២៦/១៥ ស.ស.រ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ និង គ.ខ.ប.ជ) ទាំង ២៥ ។
- **គណៈកម្មាធិការជាតិ(គ.ជ.ប.ជ)** បានដាក់ចេញនូវផែនការសកម្មភាពជាតិ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ឆ្នាំ២០១៤-២០១៨ ដែល រួមបញ្ចូលរាល់កិច្ចខិតខំប្រឹងប្រែងពីគ្រប់ផ្នែក គ្រប់វិស័យពាក់ព័ន្ធ ដើម្បីដោះស្រាយ និងលុបបំបាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស រួមទាំងការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដែលកើតមាននៅក្នុងប្រទេសកម្ពុជា និងទៅលើប្រជាជនកម្ពុជា ទោះជានៅទីណាក៏ដោយ។ ផែនការនេះមានគោលបំណង *លើកកម្ពស់ប្រសិទ្ធភាពនៃការបង្ការទប់ស្កាត់បទល្មើសជួញដូរមនុស្ស អំពើកេងប្រវ័ញ្ចលើមនុស្សគ្រប់រូបភាព ការជួយជនរងគ្រោះ ការអនុវត្តច្បាប់ ការផ្តន្ទាទោសជនល្មើសជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទប្រកបដោយភាពអយុត្តិធម៌* ។
- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើអនុសញ្ញាអាស៊ានប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ កាលពីថ្ងៃទី

២១ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅទីក្រុងកូឡាំពួ ប្រទេសម៉ាឡេស៊ី ។ នេះគឺជាការបង្ហាញអំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងអន្តរជាតិឲ្យបានខ្លាំងក្លា និងមានប្រសិទ្ធភាពថែមទៀត ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានចរិតជាបទល្មើសឆ្លងដែន ក្នុងចំណោមឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំងដទៃទៀត ។

- គោលនយោបាយជាតិ ស្តីពីមុខរបរនិងការងារឆ្នាំ ២០១៥-២០២៥ របស់រាជរដ្ឋាភិបាល បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៥។ គោលនយោបាយនេះមានគោលបំណង ១).បង្កើនឱកាសការងារសមរម្យនិងមានផលិតភាពការងារខ្ពស់ ២). ការលើកកម្ពស់ការអភិវឌ្ឍជំនាញ និងធនធានមនុស្ស ៣). ការពង្រឹងអភិបាលកិច្ចទីផ្សារការងារ ដែលជាគន្លឹះនៃការកសាងបរិស្ថានការងារក្នុងស្រុកដើម្បីជាជម្រើសជូនប្រជាជនកម្ពុជា កាត់បន្ថយការឆ្លងដែនធ្វើទេសន្តរប្រវេសន៍ដោយខុសច្បាប់ ដែលនាំឲ្យប្រឈមនឹងអំពើជួញដូរ និងការកេងប្រវ័ញ្ចគ្រប់រូបភាព ។
- **ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** បានដាក់ចេញនូវគោលនយោបាយស្តីពី ទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា (ខែធ្នូ ២០១៤)។ គោលនយោបាយនេះ ផ្តោតជាសំខាន់លើវិធានការដើម្បីគ្រប់គ្រង និងទាញយកអត្ថប្រយោជន៍អំពីទេសន្តរប្រវេសន៍ការងាររបស់ពលករកម្ពុជាទៅកាន់ប្រទេសដទៃទៀត។ គោលនយោបាយនេះ មានគោលការណ៍សំខាន់បីគឺ៖ ១). អភិបាលកិច្ចកាន់តែប្រសើរឡើងលើទេសន្តរប្រវេសន៍ តាមរយៈក្របខ័ណ្ឌច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយដែលផ្អែកទៅលើសិទ្ធិយេនឌ័រ គោលការណ៍តម្លាភាព និងភាពជាប់ទាក់ទងគ្នា ដែលគិតទៅដល់តម្រូវការទីផ្សារការងារ និងតាមរយៈកិច្ចសន្ទនាសង្គមនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់ទ្វេភាគី ថ្នាក់អនុតំបន់ និងថ្នាក់អន្តរជាតិ ២). ការការពារនិងការលើកកម្ពស់សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ទាំងបុរស និងស្ត្រី ទៅតាមវិស័យជាក់លាក់ និង ៣). ការរៀបចំទេសន្តរប្រវេសន៍ការងារ និងការបន្លាស់ទី សម្រាប់ពង្រឹងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា ដោយនិរន្តរភាព ដោយទទួលស្គាល់ថាពលករទេសន្តរប្រវេសន៍ គឺជាភ្នាក់ងារនៃរបកគំហើញថ្មី និងការផ្លាស់ប្តូរ។

- បាន និងកំពុងជំរុញការអនុវត្តសេចក្តីសម្រេចទាំង០៨នៃអនុក្រឹត្យលេខ១៩០។ក្រសួងក៏កំពុងតែពិភាក្សាអនុក្រឹត្យស្តីពីប្រាក់សោធននិវត្តន៍កម្មករ ប្រាក់ធានារ៉ាប់រងសង្គមដល់កម្មករកម្ពុជា ។
- បានចុះហត្ថលេខារួមគ្នាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងជួយជនរងគ្រោះដោយការជួញដូរមនុស្ស ( ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១៥) ។
- បានចុះហត្ថលេខារួមគ្នាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ ស្តីពីកិច្ចសហប្រតិបត្តិការ លើវិស័យការងារ (ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៥) ។

- បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ ស្តីពីកិច្ចសហប្រតិបត្តិការ លើការជ្រើសរើស និងការប្រើប្រាស់ពលករ (ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៥) ។
- បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលម៉ាលេស៊ី ស្តីពីកិច្ចសហប្រតិបត្តិការ លើការជ្រើសរើស និងការប្រើប្រាស់ពលករការងារផ្ទះ (ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥) ។
- បានចាត់បញ្ជូនក្រុមការងារអន្តរក្រសួង ទៅប្រចាំការនៅប្រទេសថៃ រួមសហការជាមួយឯកអគ្គរាជទូតកម្ពុជាប្រចាំនៅទីក្រុងបាងកក ដើម្បីសហការជាមួយភាគីថៃ ពិនិត្យ និងផ្តល់ភាពស្របច្បាប់ជូនពលករខ្មែរ ដែលចូលទៅធ្វើការនៅក្នុងទឹកដីថៃដោយខុសច្បាប់ ។

• **ក្រសួងមហាផ្ទៃ** បានចេញប្រកាសផ្ទេរក្របខ័ណ្ឌ និងភារកិច្ច និងតែងតាំងមន្ត្រីដឹកនាំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ចំនួន**៧១**នាក់ ដើម្បីធ្វើជាសេនាធិការជូនគណៈកម្មាធិការជាតិ និងជាអង្គភាពប្រតិបត្តិ ក្រោមការដឹកនាំផ្ទាល់របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ ។

• **ក្រសួងអប់រំយុវជននិងកីឡា**

- ចេញលិខិតលេខ៥៦៦៣ អយក.នក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងអប់រំ ដើម្បីជូនដំណឹងដល់វិទ្យាល័យទូទាំងប្រទេស សរុប ៤៥៥ វិទ្យាល័យ និងគ្រឹះស្ថានឧត្តមសិក្សាចំនួន ០៩ ដើម្បីឲ្យរៀបចំប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ និងធ្វើពិធីបង្ហោះប៉េងប៉ោងនាំសារនៅតាមវិទ្យាល័យទាំងឡាយនៅទូទាំងប្រទេស។
- បានដាក់ចេញឯកសារជំនួយស្មារតី ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ ដើម្បីឲ្យវិទ្យាល័យទាំង៤៥៥ និង៩គ្រឹះស្ថានឧត្តមសិក្សា យកទៅផ្សព្វផ្សាយក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ នៅទូទាំងប្រទេស ដើម្បីបានយល់ពីសារៈសំខាន់ នៃទិវាជាតិផង និងដើម្បីទាក់ទាញការចាប់អារម្មណ៍របស់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក្នុងការចូលរួមបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

• **ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា**

- ប្រកាសដាក់ចេញសេចក្តីសម្រេចលេខ១២៧៤ ស.អ.យ ចុះថ្ងៃទី១៩ខែឧសភា ឆ្នាំ២០១៤ ស្តីពីបទដ្ឋានអប្បបរមា សម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

• **ក្រសួងយុត្តិធម៌**

- ចេញលិខិតលេខ១០៩៧ កយអអកប្រទ/១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ណែនាំអយ្យការ និងសាលាដំបូងរាជធានី-ខេត្ត ផ្តល់របាយការណ៍ពាក់ព័ន្ធបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ។
- ចេញសេចក្តីសម្រេច លេខ២២កយ.សសរ/១៤ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៤ ស្តីពី ការកែសម្រួលសមាសភាពក្រុមការងារបច្ចេកទេស នៃកម្មវិធីអូស្ត្រាលី-អាស៊ីដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា

- **ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ៖**
  - ចេញសេចក្តីសម្រេចលេខ១១១ ក.ជ.ក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសការពារកុមារ
  - ចេញសេចក្តីសម្រេច លេខ១២៣ ក.ជ.ក ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពី ការបង្កើតគណៈកម្មាធិការពិនិត្យសេចក្តីព្រាងច្បាប់ ស្តីពីយុត្តិធម៌អនីតិជន ។
- **គណៈកម្មាធិការរាជធានី-ខេត្ត**(គ.រ.ប.ជ)និង(គ.ខ.ប.ជ)ទាំង២៥បានចេញសេចក្តីប្រកាសតែងតាំងសមាសភាពមន្ត្រីស្រុក និងមន្ត្រីឃុំ សង្កាត់ ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

## ២.ខ-ការអនុវត្តយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស

### ២.ខ.១-ការងារបង្ការ ទប់ស្កាត់

កិច្ចខិតខំប្រឹងប្រែងដើម្បីបង្ការទប់ស្កាត់បទល្មើសជួញដូរមនុស្សដើម្បីលប់បំបាត់រាល់ហានិភ័យកើតមានចំពោះពលរដ្ឋកម្ពុជា និងអាចក្លាយជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ដោយគោរពតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការថែរក្សាកម្លាំងពលកម្មទាំងនៅក្នុងប្រទេស និងក្រៅប្រទេស និងរារាំងការធ្វើអន្តោប្រវេសន៍ចូលមកប្រទេសកម្ពុជាដោយខុសច្បាប់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានដឹកនាំសម្របសម្រួល និងជំរុញការធ្វើសកម្មភាពបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សយ៉ាងសកម្ម។ ការផ្សព្វផ្សាយអប់រំ បំផុសការយល់ដឹងតាមគ្រប់រូបភាព បានធ្វើឡើងតាមរយៈវេទិកាសាធារណៈ កិច្ចប្រជុំ សិក្ខាសាលា តាមប្រព័ន្ធផ្សព្វផ្សាយនានា រួមទាំងវិទ្យុ ទូរទស្សន៍ ប្រព័ន្ធបណ្តាញសង្គមយ៉ាងទូលំទូលាយ នៅគ្រប់ទីកន្លែង ដល់មន្ត្រី រាជការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សាលារៀន និងប្រជាពលរដ្ឋតាមបណ្តាឃុំសង្កាត់ ភូមិ និងសហគមន៍នានា ។

#### ២.ខ.១.១. ការបង្ការ ទប់ស្កាត់ តាមរយៈការអប់រំផ្សព្វផ្សាយ

សរុបការងារផ្សព្វផ្សាយអប់រំក្នុងឆ្នាំ២០១៥នេះ ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ស្ថាប័នពាក់ព័ន្ធអាជ្ញាធរ និងសមត្ថកិច្ចបានសហការជាមួយអង្គការដៃគូធ្វើការផ្សព្វផ្សាយជាសាធារណៈទៅតាមគោលដៅបាន ចំនួន **២៩,៨៩១**លើក មានមនុស្សចូលរួមចំនួន**៣,៣៤៦,២៣៧**នាក់ **ស្ត្រី** **១,៦៧៦,២៧៥**នាក់ (កើនលើសឆ្នាំ ២០១៤ ដែលមានអ្នកចូលរួមត្រឹមតែ ១,១៧៤,០២៤នាក់ គឺកើនបាន ២,១៧២,២១៣នាក់ ស្មើនឹង ១៨៥.០២%) ក្នុងនោះ៖

- ✓ ដោយក្រសួង ស្ថាប័ន បានចំនួន **៩០៤**លើក មានមនុស្សចូលរួមចំនួន**៥៤៨,៨៣៧**នាក់ ស្រីចំនួន **២៧៣,៩៩៣**នាក់ ស្មើនឹង ៤៩.៨៣% ។
- ✓ តាមរយៈការផ្សព្វផ្សាយគោលនយោបាយ ភូមិឃុំមានសុវត្ថិភាព បាន**២៨,៩៨៧**លើក មានមនុស្សចូលរួមសរុបចំនួន**២,៧៩៧,៤០០នាក់** ស្រីចំនួន**១,៤០២,៧៨២**នាក់ ស្មើនឹង ៥០.១៤% ។

## ក. ការអប់រំផ្សព្វផ្សាយ ដោយក្រសួង ស្ថាប័ន៖

### *ក.១. ការផ្សព្វផ្សាយ អប់រំផ្ទាល់៖*

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
  - លើកកម្ពស់ការយល់ដឹងដល់ពលករចំណាកស្រុក ដែលត្រូវបានអាជ្ញាធរថៃបណ្តេញចេញ(ធ្វើនិរទេស)មកកម្ពុជាវិញ ដោយក្រសួងបានធ្វើការផ្សព្វផ្សាយព័ត៌មាន និងចែកផ្សាយប័ណ្ណប្រកាស ខិត្តប័ណ្ណ ផ្ទាំងរូបភាព និងសម្ភារអប់រំ ស្តីពីពលកម្មកុមារ ច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ពលករចំណាកស្រុកឆ្លងដែនខុសច្បាប់ ដែលត្រូវបានអជ្ញាធរថៃបញ្ជូនមកវិញ ចំនួន**៩,៥៣៦**នាក់ ស្រី**៣,៣៥២**នាក់ (កុមារ**៥៥៧**នាក់ កុមារី**៣៤៩**នាក់) ។
- **ក្រសួងកិច្ចការនារី**ចុះធ្វើវេទិកាផ្សព្វផ្សាយថ្នាក់ភូមិ អំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅខេត្តគោលដៅ ទាំងនោះ បាន**១២**លើក មានប្រជាជនចូលរួមសរុប**៦០០**នាក់ ស្រី**៤២៩**នាក់។
- **ក្រសួងអប់រំ យុវជន និងកីឡា**
  - បានធ្វើការផ្សព្វផ្សាយ ស្តីពីអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ តាមរយៈទិវាជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ចំនួន**៤៥៥**វិទ្យាល័យទូទាំងប្រទេស មានអ្នកចូលរួមចំនួន**៥០៤,៧៧១**នាក់ ស្រី**២៤៩,៣២៨**នាក់។
- **អគ្គស្នងការដ្ឋាននគរបាលជាតិ** ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង, កំពង់ស្ពឺ, កណ្តាល,កំពង់ធំនិងខេត្តមណ្ឌលគិរី បានផ្សព្វផ្សាយ ច្បាប់ស្តីអំពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ភូមិ-ឃុំមានសុវត្ថិភាព ដល់ម្ចាស់អាជីវកម្ម អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ចំនួន**៣២៦**លើក មានប្រជាពលរដ្ឋចូលរួមចំនួន**៣៣,៩៣០**នាក់ ស្រីចំនួន**២០,៣៨៤**នាក់។

### *ក.២. ការផលិត និងចែកផ្សាយសម្ភារអប់រំ ផ្សព្វផ្សាយ៖*

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានសហការជាមួយអង្គការទស្សនៈពិភពលោក បោះពុម្ព និងផ្សព្វផ្សាយ ស្តីពីបទដ្ឋានអប្បបរមា សម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន**៣,០០០**ក្បាល។

- **ក្រសួងអប់រំយុវជន និងកីឡា** បានចែក DVDវីដេអូរឿងខ្លីសម្រាប់ការងារបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សទៅដល់វិទ្យាល័យចំនួន៤៥៥ និងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡាចំនួន០៩។
- **ក្រសួងទេសចរណ៍**សហការជាមួយអង្គការទស្សនៈពិភពលោកកម្ពុជា ផលិតសម្ភារផ្សព្វផ្សាយសម្រាប់ការងារបង្ការទប់ស្កាត់ ក្នុងការជួយកុមារឲ្យរួចផុតពីការកេងប្រវ័ញ្ចផ្លូវភេទ និងការធ្វើបាបគ្រប់រូបភាព ហើយបានធ្វើផ្ទាំងប៉ាណូដែលមានខ្លឹមសារ សូមធ្វើជាអ្នកដំណើរដែលជួយរក្សាសុវត្ថិភាពកុមារ សម្រាប់ដាក់ផ្សព្វផ្សាយនៅរាជធានី ខេត្តទាំង**២៥** មានចំនួន**៥៨**ផ្ទាំង។

### *ក.៣. ការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍៖*

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**ការផ្តល់សេវារកការងារធ្វើជូនប្រជាពលរដ្ឋ រួមចំណែកដោះស្រាយការងារធ្វើ និងមុខរបរបានល្អ។ គួរកត់សម្គាល់អត្រាគ្មានការងារធ្វើមានប្រមាណ១% ប៉ុណ្ណោះ។ សេវារកការងារធ្វើបានពង្រីកការផ្សព្វផ្សាយព័ត៌ទីផ្សារការងារនៅតាមមជ្ឈមណ្ឌលការងាររាជធានី/ខេត្ត វិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក (អ៊ីនធើណែត)។ គ្រាន់តែផ្នែកវាយនភ័ណ្ឌកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើងមានចំនួនជាង១.០០០រោងចក្រ ដែលទទួលប្រាក់ឈ្នួលប្រមាណ ១.០០០លានដុល្លារ ក្នុង១ឆ្នាំ។
- **លេខាធិការដ្ឋាននៃគណៈកម្មាធិការខេត្ត**(គ.ខ.ប.ជ) ផ្សព្វផ្សាយតាមវិទ្យុខេត្ត បានចំនួន**១១០**លើកក្នុងនោះ (ខេត្តសៀមរាបចំនួន**៣៩**លើក, ស្វាយរៀងចំនួន**៣១**លើក និងខេត្តតាកែវចំនួន**៤០**លើក) ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឧបាយកលជនល្មើស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព គ្រោះថ្នាក់ផ្សេងៗដោយការធ្វើទេសន្តរប្រវេសន៍ការងារ ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ការការពារសុវត្ថិភាពកុមារ ក្នុងវិស័យទេសចរណ៍ ការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើកុមារ ការទប់ស្កាត់អំពើជួញដូរមនុស្ស ។

### ខ. <u>ការអប់រំផ្សព្វផ្សាយ តាមការបញ្ជ្រាបខ្លឹមសារនៅក្នុង វេទិកាសាធារណៈ ស្តីពីភូមិឃុំមានសុវត្ថិភាព៖</u>

- បានដាក់បញ្ចូលខ្លឹមសារស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកលល្បិចជនល្មើស ទៅក្នុងវេទិកាសាធារណៈនៃការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋបានចំនួន**២៨,៩៨៧**លើក មានមនុស្សចូលរួមសរុបចំនួន**២,៧៩៧,៤០០**នាក់ស្រីចំនួន**១,៤០២,៧៨២**នាក់ ។

*តារាងទិន្នន័យនៃការអប់រំផ្សព្វផ្សាយតាមរយៈវេទិកាគោលនយោបាយភូមិឃុំមានសុវត្ថិភាព*
*(ទិន្នន័យពីបណ្តាខេត្ត)*

| ល.រ | ក្រសួង ស្ថាប័ន<br>រាជធានី-ខេត្ត | ចំនួនដង/លើក | សរុបអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | រាជធានីភ្នំពេញ | ៥,៧៣៦ លើក | ៣៣៦,៦៩១នាក់ | ១៩៤,១២១នាក់ |
| ២ | ព្រះសីហនុ | ៩៣លើក | ៩,២៣៦នាក់ | ៣,៨៨៦ នាក់ |
| ៣ | កំពត | ៣,៣៧៤លើក | ១៧៤,៩៦៨ នាក់ | ៩៤,៥៥៨ នាក់ |
| ៤ | កែប | ៣៧៤ លើក | ៣៩,៥៧៧ នាក់ | ២២,៧៧៦ នាក់ |
| ៥ | តាកែវ | ១,២៦២លើក | ២៩០,៧១២ នាក់ | ៧៦,៦៥៧ នាក់ |
| ៦ | កណ្តាល | ២៩៤ លើក | ៤១,៧០៥ នាក់ | ២៣,៨៤១ នាក់ |
| ៧ | ស្វាយរៀង | ១,៤០៩ លើក | ១៨,៥៧៤ នាក់ | ១,៤០៩ នាក់ |
| ៨ | ព្រៃវែង | ២៩៩លើក | ៤០,៤៨៣នាក់ | ១៧,៦៧៧នាក់ |
| ៩ | កំពង់ស្ពឺ | ១,៥០៣ លើក | ១៧៧,៦៥២ នាក់ | ៩១,៩០៨ នាក់ |
| ១០ | កោះកុង | ៥២ លើក | ២,៥៣៩ នាក់ | ១,២១៧ នាក់ |
| ១១ | ឧត្តរមានជ័យ | ៨៣១ លើក | ១៤៩,០២៩ នាក់ | ៧៤,៤៦២ នាក់ |
| ១២ | បន្ទាយមានជ័យ | ៦៨២លើក | ៤១,៤០២នាក់ | ២១,៧៨៧នាក់ |
| ១៣ | ប៉ៃលិន | ២១ លើក | ៥,៧៩០ នាក់ | ២,០៤៤ នាក់ |
| ១៤ | បាត់ដំបង | ៣,៨៧៩លើក | ៣៩៩,៧០៣ នាក់ | ១៩១,៧៥៩ នាក់ |
| ១៥ | ពោធិ៍សាត់ | ៤,០៥៣ លើក | ៦២៩,១៧៤ នាក់ | ៣៣០,៣១៩ នាក់ |
| ១៦ | កំពង់ឆ្នាំង | ៤,១៨២ លើក | ៣៥៦,២៥៧ នាក់ | ១៨៧,៨៣៤ នាក់ |
| ១៧ | ព្រះវិហារ | ៥៩៣ លើក | ៧៥,២៤២ នាក់ | ៤៣,២១៨ នាក់ |
| ១៨ | សៀមរាប | ១៩៣ លើក | ៩,២៤៨ នាក់ | ៤,៩៤៧ នាក់ |
| ១៩ | កំពង់ធំ | ៣៦លើក | ៧,២១១នាក់ | ៤,០១៥ នាក់ |
| ២០ | រតនគិរី | ៧៦ លើក | ៧,៧៥០ នាក់ | ៣,០១៤ នាក់ |
| ២១ | ស្ទឹងត្រែង | ៣៤ លើក | ៩៥៧ នាក់ | ៥៣២ នាក់ |
| ២២ | ក្រចេះ | ២៥ លើក | ១,៥៥១ នាក់ | ៨៣៦ នាក់ |
| ២៣ | កំពង់ចាម | ០៥លើក | ៥១១នាក់ | ១៨៥នាក់ |
| ២៤ | ត្បូងឃ្មុំ | ១៧៤ លើក | ២១,៩២១ នាក់ | ៩៧៨០ នាក់ |
| | សរុបរួម | ២៨,៩៨៧ លើក | ២,៧៩៧,៤០០ នាក់ | ១,៤០២,៧៨២ នាក់ |

### ២.៩.១.២. ការអនុវត្តវិធានការបង្ការ ទប់ស្កាត់

តាមបណ្តាច្រករបៀង ដែលជាទីតាំងឈរជើងរបស់ កងកម្លាំងនគរបាលវរៈការពារព្រំដែនគោក លេខ៨១៧, ៨២៣ និង៣១០ នៅខេត្តបាត់ដំបង បានធ្វើការទប់ស្កាត់ និងអប់រំប្រជាពលរដ្ឋដែលព្យាយាមឆ្លងកាត់ព្រំដែនទៅប្រទេសថៃ ដោយខុសច្បាប់ ។ ដូចគ្នាដែរ នគរបាលប៉ុស្តិ៍អូរបីជាន់នៃ អធិការដ្ឋាននគរបាលស្រុកអូរជ្រៅបានសហការជាមួយ ការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងវរៈការពារព្រំដែន ៩១១ ចុះទប់ស្កាត់ និងអប់រំពលករ បម្រុងធ្វើចំណាកស្រុក ទៅរកការងារធ្វើនៅប្រទេសថៃដោយមិនមានច្បាប់ត្រឹមត្រូវ ឬតាមរយៈមេខ្យល់ ។

*តារាងសកម្មភាពអប់រំបង្ការនិងទប់ស្កាត់*

| ល.រ | លេខាធិការដ្ឋាន | សកម្មភាពទប់ស្កាត់ | ចំនួនលើក | ចំនួនរួម | ស្រី | អនីតិជន |
|---|---|---|---|---|---|---|
| ១ | បាត់ដំបង | កងកម្លាំងនគរបាលវរៈការពារព្រំដែនគោកលេខ៨១៧,៨២៣,៣១០ ទប់ស្កាត់និងអប់រំប្រជាពលរដ្ឋដែលត្រៀមធ្វើចំណាក ស្រុកឆ្លងដែនខុសច្បាប់ទៅធ្វើការនៅប្រទេសថៃ | **៤៦** | **២៦៩** | **១០០** | |
| ២ | បន្ទាយមានជ័យ | កងកម្លាំងនគរបាលវរៈការពារព្រំដែនគោកលេខ៩១១ ៨១៥ ឈរជើងនៅនៅប៉ុស្តិ៍បឹងសាគួ បានធ្វើការទប់ស្កាត់សកម្មភាពចំណាកស្រុកពលរដ្ឋខ្មែរទៅរកការងារធ្វើដោយខុស ច្បាប់នៅប្រទេសថៃ | | **៣៣៧** | **១៣២** | **៧៥** |

ពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ ក្នុងឆ្នាំ២០១៥ នេះ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីធ្វើសកម្មភាពបង្ការទប់ស្កាត់តាមបណ្តាគោលដៅ និងទទួលបានលទ្ធផលដូចខាងក្រោម៖

- តាមរបាយការណ៍ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ ចំនួនគោលដៅពាក់ព័ន្ធនឹងអាជីវកម្មសេវាកម្សាន្តនៅតាមរាជធានី ខេត្ត សរុបមានចំនួន **៤៣០** គោលដៅ ក្នុងនោះគោលដៅសង្ស័យពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើជួញដូរមនុស្ស មានចំនួន**៦៧** គោលដៅ ។ ក្នុងចំណោមគោលដៅសង្ស័យទាំង៦៧ គោលដៅដែលសង្ស័យថាប្រព្រឹត្តអំពើជួញដូរមនុស្សមាន **៥**គោលដៅ និងសង្ស័យថាមានអំពើធ្វើអាជីវកម្មផ្លូវភេទមានចំនួន **៦២**គោលដៅ ហើយត្រូវបានឃ្លាំមើលនិងត្រួតពិនិត្យជាប្រចាំពីអាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាន។
- ស្នងការដ្ឋាននគរបាលខេត្ត សៀមរាប បន្ទាយមានជ័យ តាកែវ កណ្តាល កំពង់ឆ្នាំង ព្រះវិហារ ស្វាយរៀង ព្រះសីហនុ ពោធិ៍សាត់ ឧត្តរមានជ័យ កំពង់ស្ពឺ កែប និងខេត្តក្រចេះ បានធ្វើការស្រង់ស្ថិតិអាជីវកម្មដ្ឋាន និងផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអំពើ

អាជីវកម្មផ្លូវភេទដល់ម្ចាស់អាជីវកម្មទាំង៤៣០គោលដៅ ដល់មនុស្សចំនួន **៧០៩**នាក់ ស្រី **៦៤៣** នាក់។

### ២.ខ.១.៣.ការងារបង្ការទប់ស្កាត់តាមវិធានការជំនាញ

- ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង ព្រៃវែង កំពង់ចាម កំពង់ធំ និងខេត្តតាកែវ ល្បាតឃ្លាំមើលគោលដៅសង្ស័យ**២៧៧**លើក និងគណៈបញ្ជាការឯកភាពខណ្ឌដូនពេញប្រមូលស្ត្រីរកស៊ីផ្លូវភេទ និងកុមារអនាថាពេលយប់បានចំនួន**១៨៩**នាក់ ប្រគល់ឲ្យមន្ទីរសង្គមកិច្ច។
- ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង កំពង់ស្ពឺ កណ្តាល កំពង់ធំ មណ្ឌលគិរី ផ្សព្វផ្សាយច្បាប់បង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋចំនួន**៣២៦**លើក មនុស្សចូលរួម**៣៣,៩៣០**នាក់ ស្រី **២០,៣៨៤**នាក់។

### ២.ខ.១.៤. បង្ការទប់ស្កាត់តាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរ និងជនបរទេស

ដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរូបភាពអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរនិងជនបរទេស ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ បានរួមគ្នាអនុវត្តអនុក្រឹត្យលេខ ១៨៣ អនក្រ.បក តាំងពីឆ្នាំ២០០៩ តាមរយៈការបង្កើតឲ្យមានក្រុមការងារច្រកចេញ-ចូលតែមួយសម្រាប់ការទទួលពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេស ជាមួយប្រជាពលរដ្ឋខ្មែរ ដើម្បីងាយស្រួលក្នុងការពិនិត្យ តាមដានទំនាក់ទំនង រវាងជនបរទេស និងពលរដ្ឋខ្មែរ ដែលងាយស្រួលក្នុងការនាំមនុស្សឆ្លងដែន និងដើម្បីជំរុញឲ្យពលរដ្ឋគោរពច្បាប់ ។ ដោយឡែក ក្នុងឆ្នាំ២០១៥ ការដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍ ដែលត្រូវបានអនុញ្ញាតឲ្យចុះបញ្ជី មានចំនួន**១.៦៤៣**គូ ដែលមាន ៣៧ សញ្ជាតិ ជនជាតិ រួមមាន កូរ៉េ (៤៤១ ខ្មែរកូរ៉េ២) អាមេរិក (៤១ ខ្មែរអាមេរិក ៥៤១) អូស្ត្រាលី (១៩ ខ្មែរអូស្ត្រាលី ១០៤) បារាំង (៥០ ខ្មែរបារាំង៥៦) កាណាដា (១៣ ខ្មែរកាណាដា៥៨) ម៉ាលេស៊ី (២៦) ជប៉ុន (២៣ ខ្មែរជប៉ុន ១) ញូហ្ស៊ីលែន (២ ខ្មែរញូហ្ស៊ីលែន ២៥)... ។ល។

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានធ្វើការសម្ភាសតាមដានស្ថានភាពទំនាក់ទំនងរវាងគូស្វាមី ភរិយា ដែលសង្ស័យថាមានបញ្ហា ទៅក្រៅប្រទេស តាមទូរស័ព្ទចំនួន**១១១**គូ តែជាលទ្ធផលគឺពុំមានបញ្ហាគួរឲ្យបារម្ភឡើយ ហើយបាន និងកំពុងរស់នៅជាមួយគ្រួសារដោយសុខសប្បាយ។

នគរបាលជំនាញ ប្រឆាំងការជួញដូរមនុស្ស បានធ្វើការសម្ភាសពលករ ពលការនីចំនួន **៤៣០**នាក់ ដែលត្រូវបានត្រឡប់ ឬបញ្ជូនត្រឡប់មកមាតុប្រទេសកម្ពុជាវិញ ក្នុងនោះគឺមកពីប្រទេស ឥណ្ឌូនេស៊ី **៣៨៤** នាក់ ពីប្រទេសម៉ាឡេស៊ី **៣៤**នាក់ ពីប្រទេសចិន **១១**នាក់ ពីប្រទេសសិង្ហបុរី **១**នាក់ ។

តាមរយៈការសម្ភាស បានរកឃើញថា :

| | |
|---|---|
| -ទៅដោយខ្លួនឯង | **២៩៤**នាក់ |
| -ទៅតាមមេខ្យល់មិនស្គាល់អត្តសញ្ញាណ | **១១៦**នាក់ |
| -តាមមេខ្យល់ស្គាល់អត្តសញ្ញាណចំនួន | **១០**នាក់ |

សមត្ថកិច្ចកំពុងសហការជាមួយខេត្តពាក់ព័ន្ធ ស្រាវជ្រាវអនុវត្តនីតិវិធីដើម្បីចាត់ការតាមផ្លូវច្បាប់។ បច្ចុប្បន្ន ពលករពលការិនី ទាំងនោះ ត្រូវបានអប់រំ ឲ្យវិលត្រឡប់ទៅរស់នៅឯលំនៅដ្ឋានវិញ ។

## ២.ខ.២-ការគ្រប់គ្រងលំហូរពលករចំណាកស្រុក

### ២.ខ.២.១. ការគ្រប់គ្រងស្ថិតិចំណាកស្រុករបស់ពលរដ្ឋខ្មែរតាមខែនីមួយៗ

យោងតាមស្ថិតិរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត បានស្រង់ទិន្នន័យអំពីពលរដ្ឋចំណាកស្រុកក្នុងមូលដ្ឋានទូទាំងប្រទេសឆ្នាំ២០១៥ បានរកឃើញពលរដ្ឋចំណាកស្រុកក្រៅប្រទេសមានតួរលេខដូចតារាងខាងក្រោម៖

*តារាងតាមដានបច្ចុប្បន្នភាពចំណាកស្រុករបស់ពលរដ្ឋខ្មែរតាមខែនីមួយៗ ក្នុងឆ្នាំ២០១៥ (ក្នុងនិងក្រៅប្រទេស)*

| ល.រ | គិតក្នុងខែ | ចំនួនពលរដ្ឋចំណាកស្រុក ប្រប្រួលតាមខែនីមួយៗ | | ចំនួនកុមារ | | កំណត់សំគាល់ |
|---|---|---|---|---|---|---|
| | | ចំនួនរួម | ស្រី | សរុបអនីតិជន | អនីតិជនជាកុមារី | |
| ១ | មករា | ២៥០,៤៥០ | ១០៧,៧៨២ | ៨,៣៥៧ | ៣,២០៥ | ថយចុះ |
| ២ | កុម្ភៈ | ២៧០,៤២៧ | ១១៧,៦២៨ | ៩,៣៧៣ | ៣,៤៩៨ | កើនឡើង |
| ៣ | មីនា | ២៧៤,៣៧៣ | ១១៧,៥៧០ | ៩,៥០៦ | ៣,៥៦៩ | កើនឡើង |
| ៤ | មេសា | ៤១៦,១៧៤ | ១៨៦,៨៤៧ | ៩,៨០៦ | ៣,៦៦០ | កើនឡើង |
| ៥ | ឧសភា | ៤២៨,៨៤២ | ១៨៨,៤៧១ | ៩,៦៣០ | ៣,៥៦០ | កើនឡើង |
| ៦ | មិថុនា | ៤៣១,៦១៦ | ១៩៤,៤៥៥ | ១០,១៤៧ | ៣,៧៨១ | កើនឡើង |
| ៧ | កក្កដា | ៤៣៨,១៦០ | ២០២,១៣៧ | ១០,១០៧ | ៣,៧៣២ | កើនឡើង |
| ៨ | សីហា | ៤៥៣,៤៦៣ | ២០០,៣៩៣ | ១០,៨៣៥ | ៣,៧៦៩ | កើនឡើង |
| ៩ | កញ្ញា | ៤៥៩,៤០៦ | ២០៤,១១៤ | ១០,៨៩៩ | ៣,៧៨៩ | កើនឡើង |
| ១០ | តុលា | ៤៧២,២០៥ | ២១០,៨១៤ | ១១,៤៣៨ | ៤,០០៦ | កើនឡើង |
| ១១ | វិច្ឆិកា | ៤៥០,៨៤៥ | ២០០,៧៦០ | ១១,០៩០ | ៣,៩០៦ | ថយចុះ |

ក្រាហ្វិកនៃចំណាកស្រុកក្នុងឆ្នាំ២០១៥







### ២.ខ.២.២. ការគ្រប់គ្រងធ្នាក់ងារជ្រើសរើសឯកជន

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្កើនកិច្ចខិតខំប្រឹងប្រែង ក្នុងការគ្រប់គ្រងទីភ្នាក់ងារជ្រើសពលករនៅក្នុងប្រទេសកម្ពុជា ដែលត្រូវតែចុះឈ្មោះនិងទទួលបានអាជ្ញាប័ណ្ណពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្របតាមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទីភ្នាក់ងារជ្រើសរើសពលករ ត្រូវបានតម្រូវឲ្យមានថវិកា តម្កល់ទុក (មូលប័ត្រ)ដែលនឹងត្រូវប្រើសម្រាប់ការទូទាត់សំណងដល់ពលករចំណាកស្រុកដែលរងគ្រោះ។

ទីភ្នាក់ងារជ្រើសរើសពលករទាំងនោះត្រូវបានទទួលការត្រួតពិនិត្យជាប្រចាំដោយក្រុមអធិការកិច្ចរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ជាក់ស្តែងក្នុងឆ្នាំ ២០១៥ ចំនួនទីភ្នាក់ងារជ្រើសរើសពលករ ៣៩ ត្រូវបានធ្វើអធិការកិច្ច ៧១លើក ។ ទោះបីយ៉ាងណាក៏ដោយ ក៏ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននឹងកំពុងបន្តការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករទាំងនោះយ៉ាងហ្មត់ចត់ ដើម្បីឲ្យ [illegible] ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

តាមស្ថិតិបង្ហាញថា ក្នុងឆ្នាំ២០១៥ ពលករទៅធ្វើការនៅក្រៅប្រទេស មានចំនួន ២៥.៦៧៦នាក់ ស្រីចំនួន ៩.៩៣១នាក់ (ស្មើនឹង៣៨,៦៧%) ដែលកំពុងធ្វើការងារដោយស្របច្បាប់នៅទីនោះ ក្នុងនោះ តាមរយៈទីភ្នាក់ងារជ្រើសរើសពលករមានចំនួន១៨.៤៦៨នាក់ ស្រី ៨.១៣៦នាក់ (ស្មើនឹង ៤៤.៣៥%) តាមរយៈប្រព័ន្ធអនុញ្ញាតការងារទៅប្រទេសកូរ៉េ (EPS) មានចំនួន ៧.២០៨នាក់ ស្រី ១.៧៩៥នាក់(ស្មើនឹង ២៤.៩០%) ។

*១.តារាងគ្រប់គ្រង និងបញ្ជូនពលករខ្មែរទៅធ្វើការនៅក្រៅប្រទេស*

| តាមរយៈ | ចំនួនពលករឆ្នាំ២០១៥ | | ចំនួនពលករឆ្នាំ២០១៤ | | ចំនួនពលករឆ្នាំ២០១៣ | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ភ្នាក់ងារជ្រើសរើសឯកជន | ១៨,៤៦៨ | ៨,១៣៦ | ១៧,០១៧ | ៧,១៩១ | ១៣,៧៨០ | ៤,៨២០ |
| គ.ប.ប.ភ.ប(MTOSB) | ៧,២០៨ | ១,៧៩៥ | ៧,៦៧១ | ១,៦១៩ | ៨,៨២០ | ១,៨៨៩ |
| **សរុប** | **២៥,៦៧៦** | **៩,៩៣១** | ២៤,៦៨៨ | ៨,៨១០ | ២២,៦០០ | ៦,៧០៩ |
| ចំនួនក្រុមហ៊ុនស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេស | ៤៧ | | | | | |

*២.ចំនួនពលករ ពលការិនីខ្មែរ នៅបរទេសបញ្ជូនដោយទីភ្នាក់ងារជ្រើសរើសឯកជន*

| បរិយាយ | ម៉ាឡេស៊ី | | ថៃ | | ជប៉ុន | | សិង្ហបូរី | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ឆ្នាំ២០១៥ | ៨០៧ | ៥៨៥ | ១៦,១៦៣ | ៦,៥៣៧ | ១,៣៩៩ | ៩១៥ | ៩៩ | ៩៩ | **១៨,៤៦៨** | **៨,១៣៦** |
| ឆ្នាំ២០១៤ | ៤៧០ | ២៩០ | ១៥,៨៣៩ | ៦,៣៣៨ | ៥១៨ | ៣៧៣ | ១៩០ | ១៩០ | ១៧,០១៧ | ៧,១៩១ |
| ប្រៀបធៀប % | ៧១.៧០ | ៥០.៤២ | ២.០០ | ៣.០៤ | ៦២.៩៧ | ៥៩.២៣ | -៩១.៩១ | -៩១.៩១ | ៧.៦០ | ១១.៦១ |

*៣.ចំនួនពលករដែលបានចេញទៅបម្រើការងារនៅសាធារណរដ្ឋកូរ៉េក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ (EPS) ក្នុងឆ្នាំ២០១៥*

| បរិយាយ | ឧស្សាហកម្ម | | កសិកម្ម | | នេសាទ | | សំណង់ | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ឆ្នាំ២០១៥ | ៣,៧០៥ | ២៧៧ | ២,៦១៨ | ១,៥១៧ | ៤ | ០ | ៨៨១ | ០ | **៧,២០៨** | **១,៧៩៥** |
| ឆ្នាំ២០១៤ | ៤,១៦២ | ២៩៩ | ២,៥៩១ | ១,២៨៨ | ០ | ០ | ៦៥៧ | ០ | ៧,៤១០ | ១,៥៨៧ |
| ប្រៀបធៀប % | -១៥.៧ | -១១.៤ | -១.៤៧ | ១៥.៨ | - | - | ៤៣.៦ | - | -២.៧ | ១៣.១ |

២.៩.២.៣. ការសិក្សាស្ថានភាពលំហូរជនទេសន្តរប្រវេសន៍ (តាមច្រកអន្តរជាតិ ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ)

តាមរបាយការណ៍ពីគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តបន្ទាយមានជ័យ ក្នុងរយៈពេល ១០ខែ ដើមឆ្នាំ២០១៥ បានឲ្យដឹងថា ក្រុមការងារទទួលជនទេសន្តរប្រវេស ដែលថៃបានបញ្ជូនមកតាមច្រកទ្វារអន្តរជាតិ តាមរថយន្ត ១.១៦៧គ្រឿង ទទួលបានពលរដ្ឋខ្មែរ ចំនួន ៥១.៣១៨នាក់ ក្នុងនោះស្រី ១៦.៥១៧នាក់ កុមារ ៤.០៣០នាក់ (កុមារី ១.៤៦៨នាក់) ។ តាមរយៈការសម្ភាសន៍ បានរកឃើញថា៖

- បានចេញតាមច្រកអន្តរជាតិ ២៣៦៤២នាក់ តាមច្រករបៀង ២៧.៦៤៦នាក់(៥៣.៨៧%)
- ចេញដោយខ្លួនឯង ២៤.៣៧១នាក់ តាមគេនាំ ២៦.៩៤៧នាក់ (៥២.៥០%)
- បានជាប់ពន្ធនាគារ លើសពី ១ខែ មាន ៨៣៤នាក់(១.៦២%) ។

ក្រុមការងារ បានធ្វើការសម្ភាសន៍ពលករចំនួន ៣.១៨៤នាក់ ក្នុងនោះស្រី១.១៨៧នាក់ មិនបានរកឃើញអត្តសញ្ញាណជនសង្ស័យជួញដូរមនុស្សទេ ។

បានសម្ភាសន៍កុមារ៦៤៦នាក់ (កុមារី ២៧៨នាក់) ពិនិត្យឃើញថា៖

- កុមារ ៣៧២នាក់ ទៅតាមឪពុក ម្តាយ ធ្វើការនៅការដ្ឋានសំណង់
- កុមារ ២៧៤នាក់ ទៅតាមបងប្អូន ទៅធ្វើការដកដំឡូង និងធ្វើការនៅការដ្ឋានសំណង់ ។ កុមារទាំងនោះបានឲ្យដឹងថា គេបានទទួលការឃោសនា អូសទាញពីមេខ្យល់តាមទូរស័ព្ទ ដែលមិនចាំលេខ មិនស្គាល់អត្តសញ្ញាណ ។

ដោយមានការរឹតបន្តឹងការលួចឆ្លងដែនខុសច្បាប់ ពលរដ្ឋមួយចំនួន បានត្រឡប់មកធ្វើប័ណ្ណឆ្លងដែន និងលិខិតឆ្លងដែនតាមផ្លូវច្បាប់វិញ ដើម្បីចូលក្នុងផ្សារថៃ និងប្រទេសថៃ មានចំនួនសរុប ១០៨.៤៨២នាក់ (ស្រី ៤៥.៦៧៨នាក់ កុមារ ៥.០២៦នាក់) ។

- ប្រើលិខិតឆ្លងដែន មានចំនួន ២៩.៦៧៩នាក់ (ស្រី ១២.២១០នាក់)
- ប្រើប័ណ្ណឆ្លងដែន មានចំនួន ៤១.៦៤៦នាក់ (ស្រី១៨.០១២នាក់ កុមារ ២៧៩នាក់)
- ប្រើកាតចូលផ្សារថៃ មានចំនួន ៣៧.១៥៧នាក់ (ស្រី១៥.៤៥៦នាក់ កុមារ ២.២៣៤នាក់) ។

ក្នុងរយៈពេល ១០ខែ ពលរដ្ឋក្នុងខេត្តបន្ទាយមានជ័យ ធ្វើចំណាកស្រុក ៥១.៧៦៥នាក់ (ស្រី ២៤.៧៦៧នាក់ ស្មើ ៤៧.៨៤% កុមារ ៩៨៨នាក់) ក្នុងនោះ៖

- ចេញដោយស្របច្បាប់ ចំនួន ៤.៨៣០នាក់ ស្មើ ៩.៣៣% (ស្រី ១.៩៦៥នាក់)
- ចេញដោយមិនមានឯកសារស្របច្បាប់ ចំនួន ៤៦.៩៣៥នាក់ ស្មើនឹង ៩០.៦៦% (ស្រី២២.៥៦៧នាក់ កុមារ ៩៨៨នាក់) ។

- ពលរដ្ឋក្នុងខេត្ត ដែលត្រឡប់មកវិញ មាន ១៨.៣៦៨នាក់ ស្មើនឹង <u>**៣៥.៤៨%**</u> (ស្រី ៨.៧៧០នាក់ កុមារ ៥៥៦នាក់) ។

តាមរបាយការណ៍ដែលប្រព័ន្ធព័ត៌មាននៅខេត្តបន្ទាយមានជ័យទទួលបានពីកុងស៊ុលខ្មែរ ដែលបានសហការជាមួយរាជរដ្ឋាភិបាលថៃ បានឲ្យដឹងថា សម្រាប់ឆ្នាំ២០១៥កន្លងទៅនេះ មានពលរដ្ឋចំណាកស្រុកស្រប

ច្បាប់ និងមិនស្របច្បាប់**ស្លាប់ ដោយមូលហេតុផ្សេងៗចំនួន២១៣នាក់ ក្នុងនោះស្រី ៥១នាក់** ប្រៀបធៀបនឹងឆ្នាំ២០១៤ កើន៨៤នាក់ ស្មើ៦៥,១២ភាគរយ ។

## ២.ខ. ៣. ការខារ ការពារ ស្តារនីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្តន៍

### ២.ខ.៣.១. ការងារការពារ និងស្តារនីតិសម្បទាជនរងគ្រោះ

គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូចុះជួយដល់ជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម រួចបានធ្វើការស្តារនីតិសម្បទាជនរងគ្រោះទៅតាមអង្គការនានា ដើម្បីទទួលការពិនិត្យសុខភាព, ផ្តល់ប្រឹក្សាសម្រាប់ជម្រើស ឬការដោះស្រាយផ្លូវច្បាប់, ផ្តល់ជំនួយសង្គ្រោះបន្ទាន់, ផ្តល់ការស្នាក់នៅ និងអាហារ, ផ្តល់វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបំណិនវិជ្ជា ទើបប្រគល់ឲ្យគ្រួសារវិញ សរុបបានចំនួន**៧៩២**នាក់ស្ត្រីមានចំនួន**៤៧៥**នាក់ (កុមារាចំនួន**១០៥**នាក់និងកុមារីចំនួន**១៣៤**នាក់) ដូចរាយលម្អិតខាងក្រោម ៖

*តារាងជួយសង្គ្រោះ ផ្តល់សេវា និងស្តារនីតិសម្បទាជនរងគ្រោះ*

| ល.រ | មន្ទីរ និងអង្គការពាក់ព័ន្ធ | ជនរងគ្រោះ | ចំនួនរួម | ស្រី | កុមារា | កុមារី |
|---|---|---|---|---|---|---|
| ១ | មន្ទីរស.អ.យរាជធានីភ្នំពេញនិងដៃគូពាក់ព័ន្ធ | -អំពើជួញដូរមនុស្ស<br>-ការរំលោភបំពានផ្លូវភេទ<br>-កេងប្រវ័ញ្ចកម្លាំងពលកម្ម | ៤៨១ | ៣៩២ | ៥៩ | ៧០ |
| ២ | មន្ទីរស.អ.យ ខេត្តសៀមរាប និងដៃគូពាក់ព័ន្ធ | -អំពើជួញដូរមនុស្ស<br>-ការរំលោភបំពានផ្លូវភេទ<br>-កេងប្រវ័ញ្ចកម្លាំងពលកម្ម | ៩៥ | ៤៩ | | ០៩ |
| ៣ | មន្ទីរស.អ.យ ខេត្តតាកែវ និងដៃគូពាក់ព័ន្ធ | -អំពើជួញដូរផ្លូវភេទ | | ០៥ | | |
| ៤ | មន្ទីរស.អ.យ ខេត្តស្វាយរៀង និងដៃគូពាក់ព័ន្ធ | -អំពើជួញដូរផ្លូវភេទ | ០៨ | ០៦ | | ០២ |
| ៥ | អង្គការសង្គ្រោះនិងថែទាំអន្តរជាតិស៊ីធីភញ | -ការរំលោភបំពានផ្លូវភេទ | | | | ០២ |
| ៦ | អង្គការ IOM | -អំពើជួញដូរមនុស្ស | | ០២ | | |
| ៧ | មណ្ឌលសំចតប៉ោយប៉ែត និងដៃគូពាក់ព័ន្ធ | -កំណត់អត្តសញ្ញាណជនរងគ្រោះ | ៧៤ | ២៦ | ១៦ | ០៧ |
| | | -ករណីជួញដូរមនុស្ស | ៥១ | ១៦ | ០៩ | ២០ |
| | | -ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម | ៥២ | ០៩ | ១១ | ១៣ |
| | | -ករណីជួញដូរផ្លូវភេទ | | ០១ | | |
| | | -ករណីងាយរងគ្រោះ | ៣១ | ០៩ | ១០ | ១១ |
| | សរុបចំនួនរួម | | **៧៩២** នាក់ | **៤៧៥** នាក់ | **១០៥** នាក់ | **១៣៤** នាក់ |

## ២.ខ. ៣.២-ការងារទេសន្តរប្រវេសន៍

ការផ្តល់នាពស្របច្បាប់ដល់ពលករនៅប្រទេសថៃ ៖ យោងតាមជំរឿនពលករបរទេសលើកទី២ របស់រដ្ឋាភិបាលថៃ កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៥ មានពលករកម្ពុជាដែលមិនទាន់មានភាពស្របច្បាប់ មានចំនួន ច្រើនជាង ៤៥០.០០០នាក់ ដែលកំពុងស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ ។ គិតពីថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ ក្រុមការងារក្រសួង ការងារ ស្ថានទូតកម្ពុជា ប្រចាំនៅព្រះរាជាណាចក្រថៃ បានផ្តល់ភាពស្របច្បាប់ដល់ពលករដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេស ថៃ បានចំនួន ២៣៣.០៣២នាក់ ។

ការទទួលពលរដ្ឋខ្មែរពីអាជ្ញាធរបរទេស ៖ ក្នុងឆ្នាំ ២០១៥ ចំនួនជនដែលបានធ្វើមាតុភូមនិវត្តន៍ និងត្រូវបានបញ្ជូនត្រឡប់ដោយអាជ្ញាធរមានសមត្ថកិច្ចបរទេស មិនត្រូវបានរកឃើញថា ជាជនរងគ្រោះដោយ អំពើជួញដូរមនុស្សទាំងអស់ទេ តែគឺជាជនរងគ្រោះក្នុងអំឡុងពេលធ្វើទេសន្តរប្រវេសន៍ ដោយអំពើហិង្សា ការកេងប្រវ័ញ្ច ការរំលោភលើទំនុកចិត្ត ជាដើម ។ ជនទាំងនោះ មានសិទ្ធិដាក់បណ្តឹងទាមទារយុត្តិធម៌បាន តែករណីជាច្រើន មិនកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ។

នៅក្នុងឆ្នាំ ២០១៥នេះ ចំនួនពលកររងគ្រោះដែលត្រូវបានបញ្ជូនត្រឡប់តាមអាជ្ញាធរបរទេស សរុបចំនួន**៦៧,៨៥២**នាក់(ស្រី**២២,៦៩១**នាក់) ក្នុងនោះតាម ៖

- ផ្លូវអាកាសមានចំនួន**៥៥៨**នាក់ (ស្រី**៨៦**នាក់)
- ផ្លូវគោកចំនួន**៦៧,២៩៤**(ស្រី **២២,៦០៥នាក់)**

*តារាងចំនួនពលកររងគ្រោះដែលត្រូវបានបញ្ជូនត្រឡប់ (តាមផ្លូវគោក និងផ្លូវអាកាស)*

| ប្រទេសបញ្ជូនត្រឡប់ | ផ្លូវគោក | | ផ្លូវអាកាស | |
|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី |
| ម៉ាឡេស៊ី | | | ៩៩ | ៦៧ |
| ឥណ្ឌូនេស៊ី | | | ៣៥៣ | |
| ថៃ | ៦៧,១៣៦ | ២២,៥១៨ | ៥០ | ១៧ |
| វៀតណាម | ១៣៣ | ៨៣ | ២០ | ១០ |
| ហ្វីលីពីន | | | ៤ | |
| សិង្ហបុរី | | | | ១ |
| ចិន | | | ២៥ | |
| ប៉ាពូហ្គីណេ | | | ៦ | |
| អាហ្វ្រិកត្បូង | | | ១ | |
| រុស្ស៊ី | | | | ១ |
| ឡាវ | ២៥ | ៤ | | |
| ***សរុប*** | ***៦៧,២៩៤*** | ***២២,៦០៥*** | ***៥៥៨ នាក់*** | ***៨៦ នាក់*** |

- ការការពារពលករទេសន្តរប្រវេសន៍នៅក្នុងវិស័យឧស្សាហកម្មនេសាទ

ជាមួយនឹងការប្តេជ្ញាចិត្តខ្ពស់ ចំពោះការដោះស្រាយបញ្ហាដែលមានលក្ខណៈជាប្រព័ន្ធក្នុងការកេងប្រវ័ញ្ចកម្លាំងពលកម្មក្នុងឧស្សាហកម្មនេសាទសមុទ្រ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈបានប្រមូលទិន្នន័យនៃពលករទេសន្តរប្រវេសន៍នៅប្រទេសគោលដៅ និងរិះរកវិធានការដើម្បីការពារសុវត្ថិភាពពលករទេសន្តរប្រវេសន៍លើទូកនេសាទ។ក្នុងចំណោមជនរងគ្រោះទាំងនោះមាន៣៩១នាក់ ជាពលករទេសន្តរប្រវេសន៍បម្រើការងារលើទូកនេសាទ។

*តារាងសរុបចំនួនពលកររងគ្រោះដែលធ្វើមាតុភូមនិវត្តន៍ក្នុងឧស្សាហកម្មនេសាទសមុទ្រ៖*

| បញ្ជូនមកពីប្រទេស | | | | | មូលហេតុ នៃការនាំចេញដោយ | | | |
|---|---|---|---|---|---|---|---|---|
| ម៉ាឡេស៊ី | ថៃ | អាហ្វ្រិកខាងត្បូង | ឥណ្ឌូនេស៊ី | ប៉ាពូហ្គីនេ | មេខ្យល់ | ខ្លួនឯង | ក្រុមហ៊ុន Giant Ocean | មិនច្បាស់ |
| ១៨ | ១៣ | ១ | ៣៥៣ | ៦ | ៩៩ | ២៩០ | ១ | ១ |
| **៣៩១ នាក់** | | | | | **៣៩១ នាក់** | | | |

## ២.ខ.៤.ការខារអនុវត្តច្បាប់

ក្នុងឆ្នាំ ២០១៥ នេះយើង ទទួលបានលទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ពីបណ្តាអង្គភាពចំនួន១៨ គឺ៖ ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តកណ្តាល ខេត្តកោះកុង រាជធានីភ្នំពេញ ខេត្តព្រះវិហារ ខេត្តព្រៃវែង ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តស្វាយរៀង ខេត្តតាកែវ ខេត្តប៉ៃលិន ខេត្តត្បូងឃ្មុំ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ។

### ២.ខ.៤.១.ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ៖

ដោយមានការដឹកនាំ និងកិច្ចសហការសម្របសម្រួលយ៉ាងជិតស្និទ្ធ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ) ជាមួយស្ថាប័នអនុវត្តច្បាប់ មានអគ្គស្នងការនគរបាលជាតិកងរាជអាវុធហត្ថ អគ្គព្រះរាជអាជ្ញា ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងស្ថាប័នតុលាការ បានធ្វើឲ្យការបង្ក្រាបអំពើជួញដូរមនុស្សនិងការផ្តន្ទាទោសជនល្មើសទទួលបានលទ្ធផលល្អគួរជាទីពេញចិត្ត ទាំងបរិមាណ ទាំងគុណភាព ។ ជាលទ្ធផល៖

យោងតាមរបាយការណ៍ អង្កេតរយៈពេល ១០ឆ្នាំ របស់អង្គការ(IJM) អត្រាប្រេវ៉ាឡង់នៃការជួញដូរផ្លូវភេទលើកុមារ តាមគ្រឹះស្ថានសេវាកម្សាន្ត បានធ្លាក់ចុះពី ៣០ ទៅ៣៥ភាគរយ ក្នុងឆ្នាំ២០០៤ ដល់២ភាគរយ ក្នុងឆ្នាំ២០១៤ និងសង្ឃឹមអាចបន្តថយចុះរហូតដល់ 0.១% ក្នុងឆ្នាំបន្ទាប់ទៀត ។

ពីឆ្នាំ២០១២ដល់ឆ្នាំ២០១៥អត្រាប្រេវ៉ាឡង់អនីតិជនអាយុ១៧ឆ្នាំចុះ ថយចុះ៧៣% គឺពី ៨.១៦% មកត្រឹម២.0២ % (រាជធានី ខេត្តធំៗចំនួន៣គឺ ភ្នំពេញ សៀមរាប និងព្រះសីហនុ)។

ជាទូទៅជោគជ័យនេះ គឺអាស្រ័យដោយមានការផ្លាស់ប្តូរប្រែប្រួលយ៉ាងសំខាន់ផ្នែកសមត្ថភាព ឥរិយាបថ និងការប្តេជ្ញាចិត្តរបស់មន្ត្រីអនុវត្តន៍ច្បាប់ នៅក្នុងនីតិវិធីស៊ើបអង្កេត ប្រមូលភស្តុតាង និងក្នុងប្រព័ន្ធតុលាការក្នុងរឿងក្តីជួញដូរមនុស្ស ដោយឈរលើមូលដ្ឋាននៃការស៊ើបអង្កេតពីករណីមួយទៅកាន់ករណីមួយ ដោយផ្តោតទៅលើទំហំករណី និងបណ្តាញនៃប្រព័ន្ធជួញដូរមនុស្ស។

ក្នុងឆ្នាំ ២០១៥ ដោយមានកិច្ចសហការជាមួយព្រះរាជអាជ្ញាតាមបណ្តារាជធានី ខេត្ត សកម្មភាពបង្ក្រាបបានអនុវត្ត ចំនួន**១០៥**ករណី (លើ**៩៥**ករណីបៀបធៀបឆ្នាំ២០១៤ កើនឡើង**១០**ករណី)។ ឃាត់ខ្លួនជនសង្ស័យបានចំនួន**១៨៤**នាក់ ស្រី**៧១**នាក់ និងអនីតិជន **៥**នាក់ ត្រូវបានចាប់ខ្លួន។ ក្នុងនេះចំនួនជនសង្ស័យដែលជាជនបរទេស **១៦**នាក់ មាន១០សញ្ជាតិៈ ចិន ៦នាក់. កូរ៉េ ១នាក់. ស្វីស ១នាក់ រុស្ស៊ី ១នាក់ អាមេរិក ២នាក់ ម៉ុលដូវី ១នាក់ បារាំង ១នាក់ អាឡឺម៉ង់ ១នាក់ ម៉ិចស៊ិចកូ ១នាក់ អង់គ្លេស ១នាក់ ។

ដោយឡែក ចំនួនជនរងគ្រោះដែលសង្គ្រោះបានទាំងករណីជួញដូរពលកម្ម និងនិងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុប មានចំនួន**២៩៥**នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំ **៨៣**នាក់ អាយុពី១៥-ក្រោម១៨ឆ្នាំ ចំនួន **៣៧**នាក់ អាយុ១៨ឆ្នាំឡើង ចំនួន**១៧៥**នាក់ បានបញ្ជូនទៅមន្ទីរសង្គមកិច្ចចំនួន**១២១**នាក់ គ្រួសារចំនួន **១៧០**នាក់ និងអង្គការដៃគូចំនួន៤នាក់ ។

**១. ករណីអំពើជួញដូរមនុស្សៈ** បង្ក្រាបបាន**៤៧**ករណី ឃាត់ខ្លួនជនសង្ស័យចំនួន**៧៥**នាក់ ស្រី**៤៧**នាក់ (អនីតិជន១នាក់.) សង្គ្រោះជនរងគ្រោះបានចំនួន**១១០**នាក់ (ឆ្នាំ២០១៤សង្គ្រោះបាន**២៣០**នាក់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោមៈ

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | បរទេស |
|---|---|---|---|
| -នាំអនីតិជនចេញមិនស្របច្បាប់ | ៥ | ៦ | |
| -នាំចេញមិនស្របច្បាប់មានគោលដៅ | ១៣ | ១៨ | ម៉ុលដូវី១ |
| -នាំចេញមិនស្របច្បាប់ឆ្លងដែន | ១៤ | ២៧ | ចិន២ |
| -ជ្រើសរើសមិនស្របច្បាប់កេងប្រវ័ញ្ច | ២ | ២ | |
| -អំពើលក់ដូរមនុស្ស | ២ | ៣ | ចិន១ |
| -អំពើលក់ដូរមនុស្សឆ្លងដែន | ៤ | ១០ | ចិន៣ |
| -ទិញផេស្យាចារកុមារ | ៧ | 0៩ (អនីតិជន0១) | (កូរ៉េ១ អាម៉េរិក១ បារាំង១ ម៉ិចស៊ិចកូ១ រុស្ស៊ី១) |
| **សរុប** | **៤៧** | **៧៥** | **១២** |

*បញ្ជីជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលសង្គ្រោះបានក្នុងពេលប្រតិបត្តិការបង្ក្រាប៖*

| ចំនួនជនរងគ្រោះសរុប | អាយុក្រោម ១៥ឆ្នាំ | ពី១៥ឆ្នាំ ដល់ក្រោម១៨ឆ្នាំ | អាយុ ១៨ឆ្នាំ ឡើង | ការបញ្ជូនជនរងគ្រោះ | | |
|---|---|---|---|---|---|---|
| | | | | ទៅមន្ទីរស/ក | ទៅអង្គការ | ទៅគ្រួសារ |
| ១១០នាក់ | ២៧នាក់ | ១៥នាក់ | ៦៨នាក់ | ០៧នាក់ | ០២នាក់ | ១០១នាក់ |

**២. អំពើជួញដូរផ្លូវភេទ៖** បង្ក្រាបបាន**៥៨**ករណី ឃាត់ខ្លួនជនសង្ស័យចំនួន**៦៩**នាក់ ស្រី**២៤**នាក់ (អនីតិជន ៣នាក់) ក្នុងនោះជនបរទេស៤នាក់ សង្គ្រោះជនរងគ្រោះបានចំនួន**១៨៥**នាក់ (ឆ្នាំ២០១៤សង្គ្រោះបាន **១៨២**នាក់) ។

*តារាងស្ថិតិបទល្មើសជួញដូរផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | បរទេស |
|---|---|---|---|
| -សញ្ចារកម្ម | ១០ | ១៤ | |
| -សញ្ចារកម្មមានអនីតិជន | ២ | ២ | |
| -សញ្ចារកម្មមានស្ថានទម្ងន់ | ៥ | ៦ | |
| -សញ្ចារកម្មពេស្យាចារកុមារ | ៨ | ១៤ | |
| -រូបភាព-សម្ភារៈអាសអាភាស | ១ | ១ | ស៊ុីស១ |
| -រួមភេទអនីតិជនក្រោម១៥ឆ្នាំ | ២៣ | ២៣(អនី.៤) | អាម៉េរិក១ |
| -អំពើអាសអនីតិជនក្រោម១៥ឆ្នាំ | ៩ | ៩ | អាឡឺម៉ង់១<br>អង់គ្លេស១ |
| ***សរុប*** | ***៥៨*** | ***៦៩*** | ***៤*** |

*បញ្ជីជនរងគ្រោះដោយអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលសង្គ្រោះបានក្នុងពេលប្រតិបត្តិការបង្ក្រាប៖*

| ចំនួនជនរងគ្រោះសរុប | អាយុក្រោម ១៥ឆ្នាំ | ពី១៥ឆ្នាំ ដល់ក្រោម១៨ឆ្នាំ | អាយុ ១៨ឆ្នាំ ឡើង | ការបញ្ជូនជនរងគ្រោះ | | |
|---|---|---|---|---|---|---|
| | | | | ទៅមន្ទីរស/ក | ទៅអង្គការ | ទៅគ្រួសារ |
| ១៨៥នាក់ | ៥៦នាក់ | ២២នាក់ | ១០៧នាក់ | ១១៤នាក់ | ០២នាក់ | ៦៩នាក់ |

### ២.ខ.៤.២. ការងារអនុវត្តនីតិវិធីច្បាប់៖

ការចោទប្រកាន់ ត្រូវបានអនុលោមតាមមាត្រាដែលមានចែងក្នុងច្បាប់ស្តីពី«ការបង្ក្រាបអំពើជួញមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ» ដែលជាឧបករណ៍ច្បាប់ដ៏មានប្រសិទ្ធភាព គួបផ្សំនឹងវិធានការជំនាញ ធ្វើការបង្ក្រាប ដែលអាចកាត់បន្ថយសកម្មភាពរបស់ក្រុមឧក្រិដ្ឋជនជួញដូរមនុស្សយ៉ាងមានប្រសិទ្ធភាព។

យោងតាមស្ថិតិ របស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជននៃអគ្គស្នងការដ្ឋាននគរបាលជាតិឆ្នាំ២០១៥ លទ្ធផលនៃការបញ្ជូនសំណុំរឿងទៅតុលាការ ត្រូវបានបែងចែកតាមមាត្រានៃច្បាប់ស្តីពី«ការបង្ក្រាបអំពើជួញមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ» សរុបមានដូចខាងក្រោម៖

## *តារាងស្ថិតិបញ្ជូនសំណុំរឿងទៅតុលាការ*

| លរ | អំពើ | មាត្រា | ចំនួនករណី | | ចំនួនជនល្មើស | | ចំនួនជនរងគ្រោះ | |
|---|---|---|---|---|---|---|---|---|
| | | | ជួញដូរមនុស្ស | ជួញដូរភេទ | ជួញដូរមនុស្ស | ជួញដូរភេទ | ជួញដូរមនុស្ស | ជួញដូរភេទ |
| ១ | ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ៩* | ៤ | | ៤ | | ៤ | |
| ២ | ការនាំយកចេញមិនស្របច្បាប់ដោយមានគោលដៅ | ១០* | ១២ | | ១៥ | | ១៣ | |
| ៣ | ការនាំចេញមិនស្របច្បាប់សម្រាប់ឆ្លងដែន | ១១ | ១៤ | | ២៧ | | ៣៣ | |
| ៤ | ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ១២* | ២ | | ២ | | ១៣ | |
| ៥ | អំពើលក់ដូរមនុស្ស | ១៤ | ២ | | ៣ | | ២ | |
| ៦ | អំពើលក់ដូរមនុស្សដោយមានគោលដៅ | ១៥* | 0 | | 0 | | 0 | |
| ៧ | អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ១៦ | ២ | | ៤ | | ៩ | |
| ៨ | ការដឹកជញ្ជូនដោយមានគោលដៅ | ១៧* | 0 | | 0 | | 0 | |
| ៩ | អំពើនាំឆ្លងដែន | ១៨ | 0 | | 0 | | 0 | |
| ១០ | ការទទួលយកដោយមានគោលដៅ | ១៩* | 0 | | 0 | | 0 | |
| ១១ | ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ២០ | 0 | | 0 | | 0 | |
| ១២ | ការពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ២១ | | 0 | | 0 | | 0 |
| ១៣ | ស្ថានទម្ងន់ (ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង) | ២២ | | | | 0 | | |
| ១៤ | អំពើសញ្ចារកម្ម | ២៤ | | | | 0 | | |
| ១៥ | សញ្ចារកម្ម | ២៦ | | ១០ | | ១២ | | ៣៩ |
| ១៦ | ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | ២៧ | | ៤ | | ៥ | | ១៦ |
| ១៧ | សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ | ២៨* | | ៥ | | ៩ | | ៣០ |
| ១៨ | សញ្ចារកម្មដោយមានការធ្វើទារុណកម្ម | ២៩ | | 0 | | 0 | | 0 |
| ១៩ | ការដឹកនាំពេស្យាចារ | ៣០ | | 0 | | 0 | | 0 |
| ២០ | ការដឹកនាំគ្រឹះស្ថានពេស្យាចារ | ៣១ | | 0 | | 0 | | 0 |
| ២១ | ការផ្តល់កន្លែងសម្រាប់ធ្វើពេស្យាចារ | ៣២ | | 0 | | 0 | | 0 |
| ២២ | បទល្មើសទាក់ទងនឹងពេស្យាចារកុមារ | ៣៣* | | 0 | | 0 | | 0 |
| ២៣ | ការទិញពេស្យាចារកុមារ | ៣៤* | ៧ | | ៩ | | ២៧ | |
| ២៤ | អំពើអូសទាញពេស្យាចារកុមារ | ៣៥* | 0 | | 0 | | 0 | |
| ២៥ | ការឲ្យខ្ចីប្រាក់ដោយមានលក្ខខណ្ឌទាក់ទងនឹងអំពើពេស្យាចារកុមារ | ៣៦* | 0 | | 0 | | 0 | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២៦ | កិច្ចសន្យានៃអំពើពេស្យាចារកុមារ | ៣៧ | ០ | | ០ | | ០ | |
| ២៧ | រូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ | ៣៩ | | ១ | | ១ | | ១ |
| ២៨ | រូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ | ៤១ | | ០ | | ០ | | ០ |
| ២៩ | អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ | ៤២ | | ២០ | | ២០ | | ២៤ |
| ៣០ | អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម ១៥ឆ្នាំ | ៤៣ | | ៨ | | ៨ | | ២៣ |
| ៣១ | កិច្ចសន្យាសម្រាប់អំពើលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ | ៤៥* | ០ | | ០ | | ០ | |
| | សរុប | ៣១ | ៤៣ | ៤៨ | ៦៤ | ៥៥ | ១០១ | ១៣៣ |
| | **សរុបរួម** | **៣១** | **៩១** | | **១១៩** | | **២៣៤** | |

( * ) ជាមាត្រាដែលសហរដ្ឋអាមេរិកកំណត់យកក្នុងការវាយតម្លៃ ។

សរុបលទ្ធផលតាមមាត្រាទាំង១២ ដែលកំណត់ដោយក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក៖ មានតែ ២៨ ករណី ជនសង្ស័យ ៣៨ នាក់ ជនរងគ្រោះ ៨៥ នាក់ ប៉ុណ្ណោះ ។

### ២.ខ.៤.៣. សកម្មភាពបង្ក្រាបនៅតាមរាជធានី ខេត្ត៖

ដោយឡែក នៅតាមបណ្តារាជធានី ខេត្ត បានយកចិត្តទុកដាក់ក្នុងការបង្ក្រាបករណីបទល្មើសជួញដូរមនុស្សយ៉ាងសកម្មផងដែរ ។ តារាងស្ថិតិខាងក្រោមនេះបង្ហាញអំពីលទ្ធផលនៃការអនុវត្តរបស់រាជធានី/ខេត្ត នៅក្នុងការបង្ក្រាបអំពើជួញដូរមនុស្សនៅក្នុងឆ្នាំ ២០១៥៖

*តារាងស្ថិតិលទ្ធផលបង្ក្រាបអំពើជួញដូរមនុស្ស រាជធានីខេត្ត*

| ល.រ | នាយកដ្ឋាន រាជធានី ខេត្ត | បង្ក្រាបរួម | ជនល្មើស | | | ជនរងគ្រោះ | | | |
|---|---|---|---|---|---|---|---|---|---|
| | | | រួម | ស្រី | បរទេស | រួម | -១៥ | ១៥-១៧ | ១៨+ |
| ១ | បន្ទាយមានជ័យ | ៣ | ៤ | ១ | ០ | ៧ | ២ | ០ | ៥ |
| ២ | បាត់ដំបង | ២ | ៤ | ១ | ០ | ១៤ | ១ | ៥ | ៨ |
| ៣ | កំពង់ចាម | ៦ | ៨ | ៧ | ០ | ១៣ | ០ | ១ | ១២ |
| ៤ | កំពង់ឆ្នាំង | ៤ | ៥ | ២ | ០ | ៨ | ២ | ២ | ៤ |
| ៥ | កំពង់ធំ | ៥ | ៦ | ៤ | ០ | ១៦ | ០ | ១ | ១៥ |
| ៦ | កណ្តាល | ១ | ១ | ០ | ០ | ១ | ១ | ០ | ០ |
| ៧ | កោះកុង | ២ | ២ | ២ | ០ | ៨ | ០ | ១ | ៨៧ |
| ៨ | ភ្នំពេញ | ២២ | ៣៧ | ២០ | ៥ | ៥៦ | ១៥ | ៤ | ៣៧ |
| ៩ | ព្រះវិហារ | ១ | ១ | ១ | ០ | ១ | ១ | ០ | ០ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១០ | ព្រៃវែង | ១ | ១ | ១ | ០ | ២ | ០ | ០ | ២ |
| ១១ | សៀមរាប | ៨ | ៩ | ៣ | ៤ | ១៦ | ៨ | ៤ | ៤ |
| ១២ | ព្រះសីហនុ | ១១ | ១២ | ៤ | ២ | ១៨ | ១០ | ១ | ៧ |
| ១៣ | ស្វាយរៀង | ៣ | ៨ | ២ | ០ | ១១ | ២ | ៣ | ៦ |
| ១៤ | តាកែវ | ៥ | ៥ | ០ | ១ | ៩ | ២ | ១ | ៦ |
| ១៥ | ប៉ៃលិន | ១ | ១ | ១ | ០ | ៣ | ២ | ១ | ០ |
| ១៦ | ត្បូងឃ្មុំ | ៤ | ៧ | ៦ | ១ | ២ | ០ | ០ | ២ |
| ១៧ | នាយកដ្ឋាន | ១៧ | ២២ | ១៤ | ៣ | ៩៦ | ៣០ | ១៣ | ៥៣ |
| ១៨ | កងរាជអាវុធហត្ថ | ៩ | ១១ | ២ | ០ | ១៤ | ៧ | ០ | ៧ |
| សរុប | | ***១០៥*** | ***១៤៤*** | ***៧១*** | ***១៦*** | ***២៩៥*** | ***៨៣*** | ***៣៧*** | ***១៧៥*** |

(ដោយឡែកខេត្តចំនួន ៩ មិនមានរបាយការណ៍ ស្តីពីសកម្មភាពបង្ក្រាបបទល្មើសជួញដូរមនុស្សទេ រួមមានៈ ខេត្ត កែប, កំពង់ស្ពឺ, កំពត, ក្រចេះ, មណ្ឌលគិរី, ពោធិ៍សាត់, រតនគិរី, ស្ទឹងត្រែង និងឧត្តរមានជ័យ)។

## ២.ខ.៥. ការងារកិច្ចការយុត្តិធម៌

តាមទិន្នន័យដែលបានទទួលពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត ការងារផ្តន្ទាទោស នៅក្នុងឆ្នាំ២០១៥នេះ តុលាការរាជធានីខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ គិតត្រឹមរយៈពេល១២ខែ ក្នុងឆ្នាំ២០១៥ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

ក. លទ្ធផលចំណាត់ការ ៖

**ក-១ ចំណាត់ការរបស់អយ្យការរាជធានី-ខេត្ត៖**

ចំណាត់ការអយ្យការរាជធានី-ខេត្ត សរុបមានចំនួន២៦៣ករណី ជនរងគ្រោះចំនួន**៣៧៦**នាក់ (អនីតិជន **១២៨**នាក់) ជនត្រូវចោទមានចំនួន**៣០១**នាក់ មានអនីតិជន ២៣នាក់ ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន**១៥២**ករណី, តម្កល់ទុកឥតចាត់ការចំនួន**២១**ករណី និងកំពុងចាត់ការចំនួន**៩០**ករណី ដូចមានតារាងខាងក្រោម៖

*តារាងចំណាត់ការក្ដីករណីជួញដូរមនុស្ស៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | តម្កល់ទុកឥតចាត់ការ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | |
| ២៦៣ | ៧៧ | ១៧១ | ២០ | ១០៨ | ២០៨ | ៧០ | ២២ | ០១ | ១៥២ | ២១ | ៩០ |
| **សរុប** | **២៤៨** | | **១២៨** | | **២៧៨** | | **២៣** | | **២៦៣** | | |

## ក-២ ចំណាត់ការរបស់ចៅក្រមស៊ើបសួរ រាជធានី-ខេត្ត៖

ចំណាត់ការរបស់ចៅក្រមស៊ើបសួររាជធានី-ខេត្តសរុបមានចំនួន**៣៥៣**ករណី ជនរងគ្រោះចំនួន**៤៨២**នាក់ (អនីតិជន**១៦១**នាក់) ជនត្រូវចោទមានចំនួន**២៦៧**នាក់ (អនីតិជន ២៧នាក់) នៅក្នុងឃុំចំនួន**១១៩**នាក់ និងបានចំណាត់ការ ដោយបញ្ជូនទៅជម្រះចំនួន**៧២**ករណី, លើកលែងចោទចំនួន**៩**ករណី និងកំពុងចាត់ការចំនួន**១៦៤**ករណី ដូចមានតារាងខាងក្រោម៖

*តារាងចំណាត់ការក្ដីជួញដូរមនុស្សរបស់ចៅក្រមស៊ើបសួរ*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | នៅក្នុងឃុំ | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | ជូនទៅជម្រះ | លើកលែងចោទ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | |
| ២៤៥ | ១១៥ | ២០៦ | ២៨ | ២៣៣ | ១៩៥ | ៤៥ | ២២ | ៥ | ៧១ | ២៨ | ១៧ | ៣ | ១៣២ | ១១ | ២១០ |
| **សរុប** | **៣២១** | | **១៦១** | | **២៤០** | | **២៧** | | **៩៩** | | **២០** | | **៣៥៣** | | |

## ក-៣ ចំណាត់ការរបស់ចៅក្រម ជម្រះ៖

ចំណាត់ការរបស់ចៅក្រមជម្រះ រាជធានី-ខេត្តសរុបមានចំនួន**២៩៩**ករណី ជនរងគ្រោះចំនួន**៥២៣**នាក់ (អនីតិជន**១២០**នាក់) និងបានធ្វើចំណាត់ការដោយបានព្យួរ០៤ចំនួនករណី, ពិន័យជាប្រាក់ចំនួន០៧ករណី រួចផុតពី បទចោទចំនួន**១០**ករណី រំលត់បណ្ដឹងអាជ្ញាចំនួន**០៤**ករណី ចាត់ការរួច**១២៧**ចំនួនករណី ផ្ដន្ទាទោសដាក់ពន្ធនាគារចំនួន**២០១**ករណី និងកំពុងចាត់ការចំនួន**១២៣**ករណី ដូចមានតារាងខាងក្រោម៖

*តារាងចំណាត់ការរឿងក្ដីជួញដូរមនុស្ស របស់ចៅក្រមជម្រះ*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ប្រភេទចំណាត់ការ | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ព្យួរទោស | ពិន័យជាប្រាក់ | រួចផុតពីបទចោទ | រំលត់បណ្ដឹងអាជ្ញា | ចាត់ការរួច | ផ្ដន្ទាទោសជាប់ពន្ធនាគារ<br>ក្នុងឃុំ | កំពុងចាត់ការ |
| ២៥០ | ប្រុស | ស្រី | ប្រុស | ស្រី | | | | | | | |
| **សរុប** | ១៦៧ | ២៣៦ | ១៧ | ១០៣ | ០៤ | ០៧ | ១០ | ០៤ | ១២៧ | ២០១ | ១២៣ |
| | **៤០៣** | | **១២០** | | | | | | | | |

## ខ. ការពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

ក្រសួងយុត្តិធម៌ បានពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ទាក់ទងរឿងក្ដីជួញដូរមនុស្ស ក្នុងបទល្មើសឧក្រិដ្ឋ ដែលមានការចាត់តាំង និងជាសកម្មភាពបទល្មើសរំលោភទៅលើសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ដែលយើងចាត់ទុកថា ជាការងារ អាទិភាពដ៏សំខាន់ ក្នុងការឆ្លើយតប និងការប្រយុទ្ធប្រឆាំង ទៅនឹងអំពើជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ។ ជាលទ្ធផលមានដូចខាងក្រោម៖

- ពង្រឹងកិច្ចសហប្រតិបត្តិការ ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌរវាងប្រទេសក្នុងតំបន់ ដែលជាការឆ្លើយតបលើសន្ធិសញ្ញារបស់ថ្នាក់តំបន់ ក្នុងនោះមាន អាជ្ញាធរកណ្ដាលជាតិ របស់កម្ពុជា ដែលស្ថិតនៅក្រោម យុត្តាធិការរបស់អគ្គនាយកដ្ឋានស្រាវជ្រាវ និង អភិវឌ្ឍន៍លើវិស័យព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ ។ អាជ្ញាធរនេះ បានចូលរួមប្រជុំនិងបណ្ដុះបណ្ដាលរវាងប្រទេសជាសមាជិកក្នុងតំបន់ ក្នុងការដកពិសោធន៍ និងពង្រឹងកិច្ចសហប្រតិបត្តិការជំនួយផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌឲ្យគ្នាទៅវិញទៅមក ។
- យើងបានបង្កើត ក្រុមការងារបច្ចេកទេស នៃកម្មវិធីអូស្ត្រាលីអាស៊ី ដើម្បីប្រឆាំងការជួញដូរមនុស្ស នៅក្នុងប្រទេសកម្ពុជា ហៅកាត់ថា (AAPTIP) ដែលមានសមាសភាពអន្តរក្រសួង (មានក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) មានភារកិច្ចសំខាន់ៗ ក្នុងការរៀបចំផែនការ សកម្មភាព ផែនការយុទ្ធសាស្ត្រ ដើម្បីពង្រឹងការឆ្លើយតប ប្រព័ន្ធយុត្តិធម៌ ព្រហ្មទណ្ឌ លើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កំណត់ការងារអាទិភាព ថ្នាក់ជាតិពាក់ព័ន្ធវិស័យច្បាប់ វិស័យយុត្តិធម៌ និងកិច្ចសហប្រតិបត្តិការទូទៅក្នុងការប្រយុទ្ធប្រឆាំងទៅនឹងអំពើជួញដូរមនុស្ស ក្នុងនោះដែរ ជាលទ្ធផល ក្រុមការងារបច្ចេកទេស (AAPTIP) បានធ្វើការប្រជុំចំនួន ៥លើក ដោយផ្ដោតលើបច្ចុប្បន្នភាពគម្រោង ការកសាងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់គម្រោង៖
  - ការបណ្ដុះបណ្ដាលអ្នកស៊ើបអង្កេត និងនីតិវិធីប្រតិបត្តិការ
  - ការស៊ើបអង្កេតឆ្លងព្រំដែន ព្រះរាជាណាចក្រកម្ពុជា
  - កម្មវិធីសម្របសម្រួលសម្រាប់ព្រះរាជអាជ្ញា និងសាក្សីជនរងគ្រោះ
  - កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈព្រះរាជអាជ្ញា
  - ការបណ្ដុះបណ្ដាលចៅក្រម ស្ដីពីករណីជួញដូរមនុស្ស
  - កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាមួយបរទេស សម្រាប់អាជ្ញាធរកណ្ដាល និងព្រះរាជអាជ្ញា ។

## ២.១.៦. ការងារសហប្រតិបត្តិការអន្តរជាតិ

សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិ ព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន បានផ្តល់កិត្តិយស អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងទិវាជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រួមជាមួយសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងឥស្សរជនជាន់ខ្ពស់ ក្នុងរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល ស្ថានទូតបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារអង្គការសហប្រជាជាតិ ព្រមទាំង ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន រាជធានីខេត្តខណ្ឌ សង្កាត់ សាស្ត្រាចារ្យ និស្សិតសាកលវិទ្យាល័យ លោកគ្រូអ្នកគ្រូ សិស្សានុសិស្សវិទ្យាល័យ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ តុលាការ សហភាពសហព័ន្ធយុវជន យុវជនកាយរឹទ្ធិ សមាគមនារី កម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ អង្គការសមាគមមិនមែនរដ្ឋាភិបាល ផ្នែកឯកជន ព្រះសង្ឃ ដូនជី តាជី ប្រជាពលរដ្ឋ សរុបទាំងអស់ ប្រមាណ ៣០០០នាក់ ។ សម្តេចតេជោ នាយករដ្ឋមន្ត្រី បានផ្តល់នូវសារជូនជនរួមជាតិ ដោយបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពាវនាវឲ្យប្រជាពលរដ្ឋគ្រប់រូប ស្វែងយល់អំពីអំពើជួញដូរមនុស្ស ត្រៀមខ្លួន និងចូលរួមធ្វើសកម្មភាពទាំងអស់គ្នា ។

ក្នុងឆ្នាំ២០១៥នេះបានចូលរួមកិច្ចប្រជុំនិងបំពេញកិច្ចសហប្រតិបត្តិការលើការងារពាក់ព័ន្ធទៅនឹងអំពើជួញដូរនៃប្រទេសក្នុងតំបន់សរុបមានចំនួន**៥១**លើក បើប្រៀបធៀបនៅឆ្នាំ២០១៤ មានចំនួន **៤៦**លើក មានការកើនឡើងចំនួន **០៤**លើក ស្មើនឹង**៩.៨០%**ក្នុងនោះមាន៖

គណៈកម្មាធិការជាតិគ.ជ.ប.ជចំនួន**១២**លើក ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាចំនួន**០៥** ក្រសួងកិច្ចការនារីចំនួន**០៥**លើក នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិចំនួន**១២**លើក និងលេខាធិការដ្ឋានគ.ខ.ប.ជខេត្ត កណ្តាលចំនួន**០២**លើក តាកែវចំនួន**០១**លើក ស្វាយរៀងចំនួន**០៦**លើក ប៉ៃលិនចំនួន**០១**លើក បាត់ដំបងចំនួន**០១**លើក ព្រះវិហារចំនួន**០៤**លើក ត្បូងឃ្មុំចំនួន**០១**លើក និងខេត្តព្រៃវែងចំនួន០១លើក។

*តារាងកិច្ចសហប្រតិបត្តិការ*

| ក្រសួង /ស្ថាប័ន | សកម្មភាពកិច្ចសហប្រតិបត្តិការ |
|---|---|
| **គណៈកម្មាធិការជាតិ គ.ជ.ប.ជ** | - សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ បានដឹកនាំគណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទៅចូលរួមក្នុងកិច្ចពិភាក្សា ស្តីពី ឧក្រិដ្ឋកម្មឆ្លងដែន ដែលរួមទាំងអំពើជួញដូរមនុស្សផងដែរ នៅប្រទេសចិន ។<br>- លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី អនុប្រធាន គ.ជ.ប.ជ ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (ក.ជ.ក.ស) និងលោកជំទាវជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ អនុប្រធាន ក.ជ.ក.ស បានចូលរួមការពាររបាយការណ៍ ស្តីពីការអនុវត្តសិទ្ធិកុមារ នៅប្រទេសចិន (០១លើក) និងនៅប្រទេសស្វីស (០១លើក) ។<br>- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំប្រតិភូចូលរួមក្នុងសិក្ខាសាលាបច្ចេកទេសស្តីពីការអនុវត្តល្អៗក្នុង ដំណើរការបញ្ជូនឆ្លងដែននូវជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងមហាអនុតំបន់មេគង្គ នៅប្រទេសភូមា និងបានអនុ- |

| | |
|---|---|
| | ញ្ញាតផ្តល់បទសម្ភាសន៍ជាមួយទូរទស្សន៍លេខ៩របស់ថៃ (TV9 Thailand) អំពីសកម្មភាព គ.ជ.ប.ជ ក្នុងការប្រឆាំងការរំលោភបំពានលើកុមារ។<br>- បានជួបពិភាក្សាជាមួយទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ និងអង្គការក្នុងស្រុក ស្តីពីកិច្ចសហការក្នុងការរៀបចំគម្រោងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមជំហាននីមួយៗ<br>- ដឹកនាំគណៈប្រតិភូទៅធ្វើទស្សនកិច្ចសិក្សា និងពិភាក្សាលើសេចក្តីព្រាងកិច្ចព្រមព្រៀងទ្វេភាគីរវាង ចិន-កម្ពុជា ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាធារណរដ្ឋប្រជាមានិតចិន។<br>- បានបញ្ជូន លោកជំទាវអគ្គលេខាធិការរងទទួលបន្ទុកក្រុមជំនួយកិច្ចការការពារជនរងគ្រោះបានចូលរួមកម្មសិក្សា ភាពជាអ្នកដឹកនាំនារីនគរបាល ជាមួយប្រទេសក្នុងតំបន់អាស៊ី ២៦ ប្រទេស ស្តីពីការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ។<br>- បានបញ្ជូន មន្ត្រីជាន់ខ្ពស់ ០៥រូប ក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (Trafficking in Persons Course: Session 6 August 17-28, 2015) at International Law Enforcement Academy: ILEA, Bangkok , Thailand.<br>- បានបញ្ជូន ប្រធានក្រុមជំនួយបច្ចេកទេសកិច្ចសហប្រតិបត្តិការអន្តរជាតិ ចូលរួម៖<br>o សន្និសីទតំបន់ ស្តីពីទំហំពលកម្មនៃអំពើជួញដូរមនុស្សនៅក្នុងតំបន់អាស៊ានដែលបានប្រព្រឹត្តទៅ នៅប្រទេសហ្វីលីពីន។<br>o ចូលរួមសិក្ខាសាលាអ្នកអនុវត្តច្បាប់អាស៊ាន ដើម្បីលើកកម្ពស់ការគ្រប់គ្រងលើការស៊ើបអង្កេត និងកិច្ចប្រតិបត្តិការឆ្លងដែនក្នុងករណីរឿងជួញដូរមនុស្ស។<br>o ចូលរួមកិច្ចប្រជុំក្រុមការងារSOMTCទទួលបន្ទុកអំពើជួញដូរមនុស្សនិង APPTIP ដើម្បីពិភាក្សាលើសេចក្តីព្រាងផែនការការងារសម្រាប់ឆ្នាំ២០១៥-២០១៨<br>o ចូលរួមកិច្ចប្រជុំពិសេស ស្តីពីទេសន្តរប្រវេសន៍មិនប្រក្រតីនៅក្នុងមហាសមុទ្រឥណ្ឌា ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ២៩ឧសភា ឆ្នាំ២០១៥។<br>o ចូលរួមកិច្ចប្រជុំឧត្តមមន្ត្រីអាស៊ានលើកទី ១៥ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន(15th SOMTC)។ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | - បានចាត់មន្ត្រីចូលរួមប្រជុំក្រុមការងារបច្ចេកទេសចំនួន០១លើក ស្តីអំពីបច្ចេកទេសអនុវត្តកម្មវិធីអូស្ត្រាលី-អាស៊ី ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(AATIP)។<br>- បានចូលរួមសហការរៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី២ ឆ្នាំ២០១៥ របស់ក្រុមជួយកុមាររងគ្រោះដោយអំពើជួញដូរតាមបណ្តោយព្រំដែនកម្ពុជា-ថៃ (ប៊ិកស៊ី BIG-C) ជាមួយស្ថាប័នរដ្ឋពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា-ថៃ។<br>- បានចូលរួមសន្និសីទ និងសិក្ខាសាលាថ្នាក់តំបន់ ស្តីពីការប្រើប្រាស់បច្ចេកទេសព័ត៌មានវិទ្យា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងស្តីពីការគាំទ្រជនរងគ្រោះ នៃអំពើជួញដូរក្នុងប្រព័ន្ធយុត្តិធម៌ ព្រហ្មទណ្ឌ ចំនួន០២លើក ។ |

| | |
|---|---|
| | - បានចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ |
| **ក្រសួងកិច្ចការនារី** | - បានចូលរួមកិច្ចប្រជុំលើកទី១ សម្រាប់ឆ្នាំ២០១៥ របស់ UN-ACT ស្តីពីការរៀបចំសេចក្តីព្រាងផែនការសកម្មភាពមហាអនុតំបន់មេគង្គលើកទី៤(SPA IV) នៅប្រទេសថៃ ។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើឲ្យប្រសើរឡើងនៃបណ្តាញការងារប្រឆាំង ការជួញដូរមនុស្សក្នុងចំណោមប្រទេសអាស៊ាន នៅប្រទេសជប៉ុន ។<br>- បានចូលរួមសិក្ខាសាលារួមគ្នារវាងគណៈកម្មការអន្តររាជរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្ស អាស៊ាន (AICHR) និងមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកប្រឆាំងបទល្មើសឆ្លងដែន(SOMTC) ស្តីពីយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្សផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន នៅប្រទេសឥណ្ឌូនេស៊ី ។<br>- ទស្សនកិច្ចសិក្សា និងពិភាក្សាលើសេចក្តីព្រាងទ្វេភាគីរវាងចិន-កម្ពុជា ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅប្រទេសចិន ។<br>- បានចូលរួមសិក្ខាសាលាថ្នាក់តំបន់ ស្តីពីការកំណត់អត្តសញ្ញាណកម្មជនរងគ្រោះ ដោយការជួញដូរមនុស្ស នៅប្រទេសម៉ាលេស៊ី ។ |
| **អគ្គស្នងការដ្ឋាននគរបាលជាតិ** | នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានចូលរួមវគ្គបណ្តុះបណ្តាលចំនួន **០៧**លើក និងសិក្ខាលាសាលាចំនួន**០៥**លើក៖<br>• វគ្គបណ្តុះបណ្តាលចំនួន**០៧**លើក៖<br>- ស្តីពីការស៊ើបអង្កេត ការរត់ពន្ធមនុស្សសម្រាប់តំបន់អាស៊ីអាគ្នេយ៍ ប្រទេសឥណ្ឌូនេស៊ី ។<br>- ស្តីពីភាពជាអ្នកដឹកនាំសម្រាប់ស្ត្រីក្នុងការអនុវត្តច្បាប់, ស្តីពីការស៊ើបអង្កេត និងនីតិវិធីក្នុងការចោទប្រកាន់ពាក់ព័ន្ធបទល្មើសបច្ចេកវិទ្យាប្រឆាំងនឹងកុមារស្តីពីការស៊ើបអង្កេតការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើកុមារ ស្តីពីការសម្ភាស បែបកោសល្យវិច័យជនរងគ្រោះដោយអំពើកេងប្រវ័ញ្ចលើកុមារ(០៤លើក) នៅប្រទេសថៃ ៖<br>- ស្តីពីការក្លែងបន្លំឯកសារ និងប្រឆាំងការជួញដូរមនុស្ស។<br>- ស្តីពីការពង្រឹងសន្តិសុខមនុស្ស ការកំណត់អត្តសញ្ញាណ និងការពារជនរងគ្រោះ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក នៅប្រទេសម៉ាលេស៊ី ។<br>- សិក្ខាសាលាចំនួន**០៥**លើក (ដោយមានការចូលរួមពីប្រទេស ម៉ាលេស៊ី ប្រទេសកូរ៉េ ប្រទេសថៃ ប្រទេសប្រ៊ុយណេ ប្រទេសហ្វីលីពីន ប្រទេសរុស្ស៊ី ប្រទេសឥណ្ឌូនេស៊ី)៖<br>- ចូលរួមសន្និសីទថ្នាក់តំបន់ ស្តីពីបច្ចេកវិទ្យាទំនាក់ទំនងផ្នែកព័ត៌មានវិទ្យា(ICT)ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ចូលរួមសិក្ខាសាលា ស្តីពីការទប់ស្កាត់ការជួញដូរមនុស្សឆ្លងកាត់ព្រំដែនក្នុងតំបន់សាធារណៈ។<br>- ចូលរួមសិក្ខាសាលា ស្តីពីការរៀបចំ និងយុទ្ធវិធីតាមដានការបង្ការ និងដោះ ស្រាយបទល្មើសតាមលក្ខណៈបុគ្គលរួមទាំងការជួញដូរមនុស្ស។<br>- ស្តីពីមូលវិវត្តកម្មរបស់កម្មករក្រៅប្រទេស។<br>- ស្តីពីកិច្ចសហប្រតិបត្តិការឆ្លងដែនលើករណីជួញដូរមនុស្សលើទូកនេសាទ។ |
| **ខេត្តក[illegible]បេ** | • បានប្រជុំបូកសរុបសកម្មភាពកិច្ចសហប្រតិបត្តិការ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរស្ត្រីនិងកុមារ |

| | |
|---|---|
| | រវាងខេត្តកណ្តាល ខេត្តតាកែវ នៃព្រះរាជាណាចក្រកម្ពុជា និងខេត្តអានយ៉ាង ប្រទេសវៀតណាម ។<br>• ប្រធានស្តីទីមន្ទីរកិច្ចការនារីខេត្ត បានទៅចូលរួមប្រជុំបូកសរុបការងារកិច្ចសហការប្រចាំឆមាសទី១ឆ្នាំ២០១៥ នៅខេត្តអានយ៉ាង និងមានថ្នាក់ដឹកនាំ មន្ទីរជុំវិញខេត្ត សមាជិកក្រុមប្រឹក្សាខេត្ត មានអ្នកចូលរួមចំនួន៤២នាក់ ស្រី០៤នាក់។ |
| **ខេត្តតាកែវ** | • បានចូលរួមប្រជុំបូកសរុបការងារសហប្រតិបត្តិការរវាងសមាគមនារីខេត្តតាកែវ ខេត្តកណ្តាល និងសហព័ន្ធនារីវៀតណាម ខេត្តអាងយ៉ាង ប្រចាំឆ្នាំ២០១៤ និងលើកផែនការសកម្មភាពបន្តឆ្នាំ២០១៥ ស្តីពីការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងកុមារឆ្លងដែនដោយសមាគមនារីខេត្តកណ្តាល ។ |
| **ខេត្តស្វាយរៀង** | • លេខាធិការដ្ឋានខេត្តស្វាយរៀង បានចូលរួមប្រជុំ ស្តីពីកិច្ចសហប្រតិបត្តិការការពារព្រំដែន ជាមួយគណៈប្រតិភូ ការពារព្រំដែនស្រុកឡុងអាន ពាក់ព័ន្ធបទល្មើសជួញដូរមនុស្សឆ្លងដែន។<br>• បានរៀបចំកិច្ចប្រជុំទ្វេភាគីរវាងអាជ្ញាធរកម្ពុជា-វៀតណាម ស្តីពីកិច្ចការពារកុមារឆ្លងដែន នៅខេត្តស្វាយរៀង។<br>• ក្រុមការងារការពារកុមារឆ្លងដែន បានចូលរួមប្រជុំទ្វេភាគីរវាងអាជ្ញាធរកម្ពុជា និងវៀតណាម ស្តីពីកិច្ចការពារកុមារឆ្លងដែន នៅខេត្តឡុងអាន ប្រទេសវៀតណាម ០១លើក និងនៅខេត្តស្វាយរៀង ០១លើក ។<br>• ក្រុមការងារការពារជនរងគ្រោះ បានដឹកនាំប្រតិភូទៅទស្សនកិច្ចសិក្សានៅមណ្ឌលសង្គមកិច្ច ក្រុងហូជីមិញ ប្រទេសវៀតណាម ដើម្បីកំណត់អត្តសញ្ញាណប្រជាជនកម្ពុជាដែលឆ្លងដែនខុសច្បាប់ ។<br>• បានធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ពីការអនុវត្ត ការផ្ទេរការងារពីក្រសួង ផែនការ និងវិនិយោគនៃសាធារណរដ្ឋសង្គមនិយមវៀតណាម តាមបែបវិមជ្ឈការ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធ ស្ត្រី និងកុមារនៅខេត្តតៃនិញ និងទីក្រុងហូជី មិញ ប្រទេសវៀតណាម ។ |
| **ខេត្តប៉ៃលិន** | • លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តប៉ៃលិន បានសហការជាមួយអាជ្ញាធរថៃនៅខេត្តច័ន្ទបូរី ប្រជុំរួមគ្នាដើម្បីសម្របសម្រួលដល់ការធ្វើចរាចរណ៍ ឆ្លងកាត់តាមច្រកទ្វារព្រំដែន អន្តរជាតិព្រំ ខេត្តប៉ៃលិន និងរឹតបន្តឹង ការចេញចូលឆ្លងដែនរបស់ប្រជាពលរដ្ឋ ដើម្បីរកការងារធ្វើដោយខុសច្បាប់ ទាំងពីរភាគី។ |
| **ខេត្តបាត់ដំបង** | បានបញ្ជូននាយនគរបាល០១រូបពីការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ឲ្យទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេត ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើកុមាររយៈពេល២សប្តាហ៍នៅបណ្ឌិត្យសភា ILEA ទីក្រុងបាងកក ប្រទេសថៃ ។ |
| **ខេត្តព្រះវិហារ** | • បានចូលរួមប្រជុំជាមួយប្រទេសថៃ និងឡាវ ចំនួន០៣លើក ស្តីពីកិច្ចសហប្រតិបត្តិការ ការពារសន្តិសុខតាមបណ្តោយព្រំដែន និងបញ្ហាពលករធ្វើចំណាកស្រុកដើម្បី ស្វែងរកការងារធ្វើខុសច្បាប់ក្រៅប្រទេស និងពាក់ព័ន្ធអំពើជួញដូរមនុស្សឆ្លងដែនខុសច្បាប់ (នៅប្រទេសថៃ និងប្រទេសឡាវ)។ |

| | |
|---|---|
| | • ស្នងការដ្ឋាននគរបាលខេត្តបានទៅចូលរួមកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំជំនាញការខេត្ត និងមេបញ្ជាការកងពលលេខ១៥ ខេត្តយ៉ាឡាយ ប្រទេសវៀតណាម ស្ដីពីកិច្ចសហប្រតិបត្តិការ រវាងខេត្តទាំងពីរ ក្នុងការបង្ការ បង្ក្រាបទប់ស្កាត់ និងដំណោះស្រាយរាល់បទល្មើសដែលកើតឡើងពាក់ព័ន្ធអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើទេសន្តរប្រវេសន៍ដោយខុសច្បាប់ និងការប្រព្រឹត្តបទល្មើសផ្សេងៗ ។ |
| **ខេត្តត្បូងឃ្មុំ** | • ជួបប្រជុំជាមួយសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍស្រុកសហគមន៍អតីតយុវជន នៅតាមព្រំដែនមានស្រុកមេមត់ ពញាក្រែក ខេត្តត្បូងឃ្មុំ និងស្រុករមាសហែក ខេត្តស្វាយរៀងនៅខេត្តតៃនិញប្រទេសវៀតណាម ដែលបានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការលើគ្រប់វិស័យ ពិសេសការជួញដូរលើស្ត្រីនិងកុមារ តាមបណ្ដាស្រុកនៅជាប់ព្រំដែន ។ |
| **ខេត្តព្រៃវែង** | • បានសហការជាមួយសហព័ន្ធនារីខេត្តដុងថាប់ នៃប្រទេសវៀតណាម ផ្សព្វផ្សាយដល់ឃុំចំនួន៤ នៅជាប់ព្រំដែន ស្ដីពីការទប់ស្កាត់ការជួញដូរមនុស្សឆ្លងដែន |

### ២.ខ.៧. ការខារកុមារ

គណៈកម្មាធិការជាតិ គ.ជ.ប.ជ គណៈកម្មាធិការរាជធានី-ខេត្ត (គ.រ.ប.ជ)(គ.ខ.ប.ជ) និងក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី-ខេត្ត បានសហការជាមួយមណ្ឌលរដ្ឋនិងមណ្ឌលអង្គការនានាជាដៃគូក្នុងឆ្នាំ២០១៥យើងបានជួយសង្គ្រោះកុមារករណីអំពើជួញដូរមនុស្ស, ជួញដូរផ្លូវភេទ, កេងប្រវ័ញ្ចកម្លាំងពលកម្មនិងការគ្រប់គ្រង ការថែទាំកុមារាសរុបចំនួន**១២៤**នាក់ និងកុមារីចំនួន**១៥៥**នាក់មានដូចតារាងខាងក្រោម៖

| ល.រ | រាជធានី-ខេត្ត | មណ្ឌលរដ្ឋ/អង្គការទទួលថែទាំកុមាររងគ្រោះ | កុមារាសរុប | កុមារីសរុប |
|---|---|---|---|---|
| ១ | កណ្ដាល | អង្គការក្ដីសង្ឃឹមពិភពលោក និងយុត្តិធម៌ អង្គការHCC និង ARM | | ១៨នាក់ |
| ២ | ស្វាយរៀង | អង្គការម្លប់តាប៉ាង(CCPCR) | ៤៣នាក់ | ៤៤នាក់ |
| ៣ | បន្ទាយមានជ័យ | មណ្ឌលសំចតប៉ោយប៉ែតនិងអង្គការកម្ពុជាជួយស្ត្រីមានវិបត្តិ អង្គការCWCC, KHR, DT (ARM) | ៣០នាក់ | ៤៥នាក់ |
| ៤ | ក្រចេះ | អង្គការAFESIP | | ០១នាក់ |
| ៥ | សៀមរាប | អង្គការនានានៅរាជធានីភ្នំពេញ | | ០៦នាក់ |
| ៦ | តាកែវ | អង្គការនានានៅរាជធានីភ្នំពេញ | | ០៤នាក់ |

| | | | | |
|---|---|---|---|---|
| ៦ | ពោធិ៍សាត់ | អង្គការកុមារនៃក្ដីសង្ឃឹម,<br>អង្គការទស្សនៈពិភពលោកកម្ពុជា,<br>អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍(COCD) | ៥១នាក់ | ៣៥នាក់ |
| ៧ | អង្គការ | សួននៃក្ដីសង្ឃឹម | | ០២នាក់ |
| **សរុបកុមារដែលរកឃើញថាត្រូវគេជួញដូរ និងទទួលការថែទាំនៅមណ្ឌលអង្គការ** | | | **១២៤នាក់** | **១៥៥នាក់** |

## ២.គ. ការងារសម្របសម្រួល

ការងារដឹកនាំ សម្របសម្រួល ដឹកនាំការងារផ្ទៃក្នុងស្ថាប័ន អន្តរស្ថាប័ន និងជាមួយអន្តរជាតិ ក្នុងឆ្នាំ២០១៥ សរុបរួមមានចំនួន**២៣៣**លើក៖ ដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងអគ្គលេខាធិការដ្ឋាន **៥៥**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា **៣៣**លើ ក្រសួងអប់រំ យុវជន និងកីឡា **០៣**លើក ក្រសួងកិច្ចការនារី**១០**លើក និងដោយលេខាធិការដ្ឋានរាជធានី-ខេត្ត (គ.រ.ប.ជ និង គ.ខ.ប.ជ)**១៣២**លើករួមមាន ៖

*តារាងការងារដឹកនាំ និងសម្របសម្រួលកិច្ចសហការ*

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| **គណៈកម្មាធិការជាតិ** | - សម្ដេចក្រឡាហោម **សខេង**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ បានដឹកនាំសម្របសម្រួល ៖<br>○ សន្និបាតបូកសរុបសកម្មភាព និងលទ្ធផលការងារបង្ការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៤ និងទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០១៥ ។<br>○ កិច្ចប្រជុំ ស្ដីពីការត្រួតពិនិត្យនិងឆ្លងអនុក្រឹត្យសម្រេចទម្រង់ឯកសារលើគោលការណ៍ណែនាំស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងការបញ្ជូនបន្តទៅរក សេវាគាំទ្រ (នៅក្រសួងមហាផ្ទៃអគារA )។<br>○ កិច្ចប្រជុំឆ្លងរបាយការណ៍ឆមាសទី១ ឆ្នាំ២០១៥ ។<br>○ អញ្ជើញជាអធិបតី និងផ្ដល់មតិស្វាគមន៍ ក្នុងការប្រារព្ធពិធីទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរ |

| | |
|---|---|
| | មនុស្ស ១២ ធ្នូ ឆ្នាំ២០១៥ ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** នៅសាលប្រជុំកោះពេជ្រ ដែលមានអ្នកចូលរួមចំនួន៣០០០នាក់ ។ |
| **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ និង អគ្គលេខាធិការដ្ឋាន** | - បានប្រជុំក្រុមការងារបច្ចេកទេសអនុវត្តកម្មវិធីAAPTIP លើកទី៤<br>- រៀបចំផែនការបណ្តុះបណ្តាល ចាត់តាំង និងបណ្តុះបណ្តាលគ្រូបង្គោល និងចុះបណ្តុះបណ្តាលក្នុងគណៈកម្មាធិការរាជធានី-ខេត្ត ដើម្បីពង្រឹងរចនាសម្ព័ន្ធ និងរបៀបរបបការងារ។<br>- បានជួបពិភាក្សាជាមួយអង្គការពាក់ព័ន្ធមានអង្គការ World Vision អង្គការ Winrock អង្គការ UNACT ស្តីពីសេចក្តីព្រាងគោលការណ៍ កំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។<br>- បានជួបពិភាក្សាជាមួយតំណាងស្ថានទូតអាមេរិក ស្តីពីការវាយតម្លៃ ផ្តល់ចំណាត់ថ្នាក់លើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា ។<br>- បានអនុញ្ញាតឲ្យទីប្រឹក្សាផ្នែកស្រាវជ្រាវរបស់អង្គការ UN-ACT ចូលជួបសម្ភាសន៍ដើម្បីស្វែងយល់ពីការកសាងសម្ថភាព ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។<br>- បានដឹកនាំប្រជុំពិភាក្សា ជាមួយអ្នកដឹកនាំកម្មវិធី របស់អង្គការ IOM លោកស្រី Tara Dermott និងតំណាងអង្គការ IOM ចំនួន០២រូប ព្រមទាំងតំណាងក្រសួងអប់រំ យុវជន និងកីឡា ទទួលបន្ទុកការងារបង្ការទប់ស្កាត់ ចំនួន០១រូប ពិភាក្សាលើកម្មវិធី IOM សម្រាប់យុទ្ធនាការបង្ការទប់ស្កាត់<br>- បានអនុញ្ញាតឲ្យអង្គការ Cambodian-ACT និងតំណាងអង្គការ PLAN ប្រចាំប្រទេសថៃ និងស៊ុីសចូលជួបពិភាក្សាណែនាំពីគម្រោងថ្មីរបស់PLAN សហការជាមួយCambodian-ACT ទាក់ទងនឹងការជួយផ្តល់ការអប់រំដល់ពលករខ្មែរដែលបានធ្វើចំណាកស្រុកទៅប្រទេសថៃលើការងារនេសាទ ។<br>- ចូលរួមកិច្ចប្រជុំពិភាក្សាលើបច្ចុប្បន្នភាព (COMMIT)<br>- ប្រជុំរៀបចំរបាយការណ៍បូកសរុបពីធីប្រកាសជាផ្លូវការ គ.ជ.ប.ជ រចនាសម្ព័ន្ធ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងផែនការជំហានទី២ ចំនួន០២លើក។<br>- ជួបពិភាក្សាជាមួយអង្គការ WINROCK។<br>- បានចូលរួមកិច្ចប្រជុំលើកទី១របស់ក្រុមការងារបង្ការទប់ស្កាត់ដើម្បីប្រកាសសមាសភាពតួនាទីភារកិច្ច និងទិសដៅអនុវត្តរបស់ក្រុមការងារ នៅក្រសួងអប់រំ។<br>- បានដឹកនាំកិច្ចប្រជុំសម្រេចទម្រង់ឯកសារលើគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ។<br>- អនុញ្ញាតផ្តល់បទសម្ភាសជាមួយអង្គការ IJM សម្រាប់ការផលិតខ្សែវីដេអូឯកសារខ្លីមួយ។<br>- បានចូលរួមជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ផ្សព្វផ្សាយនិងប្រកាសដាក់ឲ្យប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសណ្ឋាគារសាន់វេភ្នំពេញ ។<br>- បានរៀបចំក្រុមគ្រូឧទ្ទេសក៏ ឧបករណ៍បណ្តុះបណ្តាល និងចុះធ្វើបទឧទ្ទេសនាម ស្តីពីការងារទេសន្តរប្រវេសន៍ និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ជូនដល់សិក្ខាកាមវគ្គបណ្តុះបណ្តាលជំនាញការងារព្រំដែន នៅសាលាហ្វឹកហ្វឺនយោធាព្រំដែន (លង្វែក) ។ |

| | |
|---|---|
| | - បានចូលរួមផ្សព្វផ្សាយពីលទ្ធផលការងារស្រាវជ្រាវថ្មី១ ផ្តោតលើសមាហរណកម្មនៃបុរសរងគ្រោះដោយការជួញដូរមនុស្ស នៅសណ្ឋាគារ សាន់វ៉េ ភ្នំពេញ ។<br>- ធ្វើរបាយការណ៍ប្រចាំត្រីមាស ឆមាស និងឆ្នាំ និងរបាយការណ៍សកម្មភាពក្រុមការងារទាំង០៦។<br>- ជួបសម្ភាសន៍ពីលទ្ធផលចំណាត់ថ្នាក់របស់សហរដ្ឋអាមេរិកលើការងារប្រយុទ្ធប្រាំងអំពើជួញដូរមនុស្ស ជាមួយទូរទស្សន៍ហង្សមាស ។<br>- បានសម្របសម្រួលកិច្ចប្រជុំបូកសរុប និងផ្ទៀងផ្ទាត់របាយការណ៍ឆមាសទី១ ចំនួន០៣លើក ជាមួយក្រុមការងារអន្តរក្រសួង លេខាធិការដ្ឋានរាជធានី ខេត្ត និងអង្គការមិនមែនរដ្ឋាភិបាល ។<br>- ដឹកនាំ សម្របសម្រួលកិច្ចប្រជុំពិភាក្សាលើការងាររៀបចំកម្មវិធី កំណត់ប្រធានបទ តែងតាំងសមាសភាព និងកំណត់តួនាទីភារកិច្ចគណៈកម្មការសម្រាប់ត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្ងៃទី ១២ ធ្នូ ឆ្នាំ២០១៥ នៅសាលប្រជុំ គ.ជ.ប.ជ ចំនួន០៣លើក ត្រួតពិនិត្យ សកម្មភាពអនុគណៈកម្មការ និងគម្រោងចំណាយសម្រាប់ត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ នៅសាលប្រជុំ ក្រសួងមហាផ្ទៃអគារ ៩។<br>- រៀបចំសម្ភារៈ ឧបករណ៍ លិខិតអញ្ជើញ ឯកសារ ហ្វឹកហាត់សិល្បៈ និងរៀបចំប្រារព្ធពិធីទិវាជាតិប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ នៅសាលមហាស្រព ក្នុងមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ដែលមានអ្នកចូលរួម ៣០០០នាក់ ក្រោមអធិបតីភាពសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន សម្តេចក្រឡាហោម សខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគ.ជ.ប.ជ និងឥស្សរជនជាច្រើនរូបទៀត<br>- បានប្រជុំផ្ទៃក្នុង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចំនួន០៦លើក ដើម្បីពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់មន្ត្រី ។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សារវាង គ.ជ.ប.ជ ជាមួយនាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងក្រសួងយុត្តិធម៌ ស្តីពីចំណុចខ្វះចន្លោះក្នុងការកំណត់មាត្រានៃច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដើម្បីវាយតម្លៃចំណាត់ថ្នាក់របស់សហរដ្ឋអាមេរិក ការប្រមូលទិន្នន័យ នៃការកាត់ទោស ភាពខុសគ្នានៃតួលេខនិងបញ្ហាកុមាររងគ្រោះច្រើនដង នៅសាលប្រជុំ គ.ជ.ប.ជ ។<br>- បានសម្របសម្រួល និងធ្វើជាអធិបតី ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលយោធាការពារព្រំដែន នៅសាលាហ្វឹកហ្វឺនយោធាព្រំដែន នៅបន្ទាយលង្វែក ខេត្តកំពង់ឆ្នាំង (១៣៥នាក់) ស្តីពីការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាជួញដូរមនុស្ស ។<br>- បានទទួលជួបពិភាក្សា ជាមួយតំណាងស្ថានទូតអាមេរិក ស្តីពី កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការវាយតម្លៃចំណាត់ថ្នាក់ ឆ្នាំ២០១៥ នៅសាលប្រជុំ គ.ជ.ប.ជ ។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សា អំពីការពិនិត្យកែសម្រួលសេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសាលប្រជុំក្រសួងមហាផ្ទៃអគារ ៩ និងបន្តកែសម្រួលជាមួយក្រុមបច្ចេកទេស ចំនួន៥លើក ។<br>- បានដឹកនាំកិច្ចប្រជុំត្រៀមរបាយការណ៍អនុវត្ត ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ១០ខែ(ពីខែមករា ដល់ ខែតុលា) ឆ្នាំ២០១៥ ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំ២០១៥ |

| | |
|---|---|
| | នៅសាលប្រជុំមហាផ្ទៃ អគារ S។<br>- បន្តដឹកនាំសម្របសម្រួលការងាររបាយការណ៍ ជាមួយលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- ពិភាក្សាលើសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារក្នុងអនុគណៈកម្មាធិការផែនការ និងរបាយការណ៍ជាតិស្តីពីកុមារ ដើម្បីពិនិត្យ និងសម្រេចលើការផ្សព្វផ្សាយ សេចក្តីសង្កេតចុងក្រោយ របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិលើរបាយការណ៍ជាតិលើកទី១ និងទី២ ស្តីពីការអនុវត្តពិធីសារបន្ថែមលើការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបអាសអាភាសកុមារ និងការចូលរួមរបស់ កុមារនៅក្នុងជម្លោះប្រដាប់អាវុធមុននឹងទៅការពារ នៅអង្គការសហប្រជាជាតិ ។<br>- ចូលរួមធ្វើជាវាគ្មិននៅក្រសួងទេសចរណ៍ធ្វើបទបង្ហាញអំពីរចនាសម្ព័ន្ធ និងយន្តការរបស់គណៈកម្មាធិការជាតិ និងយន្តការថ្នាក់ក្រោមជាតិប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស<br>- ប្រជុំបូកសរុបរបាយការណ៍សកម្មភាពការងារ និងលទ្ធផលនៃ ការបណ្តុះបណ្តាល របស់ក្រុមជំនួយកិច្ចការទាំង៦ ស្តីពីតួនាទី និងភារកិច្ចរបស់ក្រុម និងការិយាល័យរដ្ឋបាលនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ<br>- ប្រជុំបូកសរុបលទ្ធផលការងារប្រចាំសប្តាហ៍របស់អគ្គលេខាធិការដ្ឋាន ។<br>- ចូលរួមប្រជុំអនុគណៈកម្មាធិការផែនការនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងពិនិត្យរបាយការណ៍ជាតិដើម្បីឆ្លើយតបទៅអង្គការសហប្រជាជាតិ តាមការកំណត់ ដែលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានជូនដំណឹង ដើម្បីឲ្យកម្ពុជាផ្តល់ព័ត៌មានស្តីពីការការពារកុមារ ពីការគំរាមកំហែង តាមប្រព័ន្ធអ៊ិនធឺណែត ការបង្ការទប់ស្កាត់អំពើជួញដូរ និងការរំលោភបំពានលើកុមារ ការយល់ដឹងជាសាធារណៈ វិធានការច្បាប់ ការសិក្សាស្រាវជ្រាវ និងការប្រមូលទិន្នន័យ ។<br>- បានចូលរួមជាអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីភាពឆ្លាតវៃក្នុងការធ្វើទេសន្តរប្រវេសន៍ការងារ និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស រៀបចំដោយអង្គការមូលនិធិ អាស៊ី និងសមាគមន៍យុវជនខ្មែរ ។<br>- បានជួបសំណេះសំណាល និងពិភាក្សាការងារជាមួយលោក William Heidt ឯកអគ្គរដ្ឋទូត អាមេរិកប្រចាំកម្ពុជា នៅអគារ គ.ជ.ប.ជ ។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុង ត្រៀមរបាយការណ៍ប្រចាំឆ្នាំ២០១៥ នៅសាលប្រជុំ គ.ជ.ប.ជ ។<br>- បានចូលជាគណៈអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាលព័ត៌មានវិទ្យាដល់មន្ត្រីលេខាធិការដ្ឋានរាជធានី/ខេត្ត ដែលមានសិក្ខាកាមចូលរួមចំនួន៤០នាក់(ស្រី១៦នាក់) នៅអគារ គ.ជ.ប.ជ ។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង លើសេចក្តីព្រាងរបាយការណ៍ជាតិ ពាក់ព័ន្ធនឹងសកម្មភាពជួញដូរមនុស្សឆ្នាំ២០១៥ នៅអគារ S ក្រសួងមហាផ្ទៃ ។ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចូលធ្វើការសម្របសម្រួល ចំនួន**៣២**លើករួមមាន៖<br>- បានចូលរួមប្រជុំពិភាក្សាករណីមុនពេលជនចំណាកស្រុកធ្វើមាតុភូមិនិវត្តន៍ជាមួយអង្គការចំនួន០៤ គឺ CWCC, WVC, DT, KT ។<br>- បានចូលរួមជាគ្រូឧទ្ទេសក៍ ដើម្បីផ្សព្វផ្សាយគោលនយោបាយនិងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារ |

សិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលរៀបចំដោយក្រសួងស.អ.យជូនដល់អង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់សេវាជួយជនរងគ្រោះ។

- បានចាត់មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការសង្គ្រោះបន្ទាន់លើវិស័យកិច្ចការពារកុមារ និងកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស, បទដ្ឋានអប្បបរមាជនរងគ្រោះ និងងាយរងគ្រោះ(ចំនួន**០៣**លើក) ។
- បានចូលរួមកិច្ចប្រជុំ ស្តីពីការបង្ហាញលទ្ធផលនៃការស្រាវជ្រាវអំពីផលប៉ះពាល់ដល់ការធ្វើចំណាកស្រុកទៅលើកុមារងាយរងគ្រោះដោយអំពើជួញដូរ។
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយអំពីគម្រោងអ្នកសម្របសម្រួលសាក្សីនិងជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅសណ្ឋាគារហ៊ីម៉ាវ៉ារី។
- បានចូលរួមប្រជុំពិនិត្យ និងផ្តល់យោបល់ ស្តីពីការសិក្សាប្រមូលទិន្នន័យ ការវិភាគ និងការចែករំលែកព័ត៌មានអំពីពលករអន្តរប្រវេសន៍ការងារ, ការលើកកម្ពស់ និងការការពារសិទ្ធិស្ត្រី និងកុមារ, ពិគ្រោះយោបល់ផ្លាស់ប្តូរបទពិសោធន៍ និងប្រមូលនូវអនុសាសន៍ ស្តីពីការអនុវត្ត MOU ស្តីពីកិច្ចសហប្រតិបត្តិការប្រើប្រាស់កម្លាំងពលកម្មព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃឡង់ ពិគ្រោះយោបល់លើកទី២ ដើម្បីអភិវឌ្ឍផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តអនុសញ្ញាអន្តរជាតិលេខ ១៨៩ ស្តីពីកម្មករការងារផ្ទះ (ចំនួន០៦លើក)។
- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារ ឆមាសទី១, ត្រៀមបូកសរុបលទ្ធផលការងារឆមាសទី១, ត្រីមាសទី១ ឆ្នាំ២០១៥ និងទិសដៅបន្តការងារបញ្ហាប្រឈម ដើម្បីស្វែងរកដំណោះស្រាយ និងវត្តភាពរបស់ក្រុមការងារក្នុងស្ថាប័នរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ និងអង្គការដៃគូ សង្គមស៊ីវិលដែលកំពុងធ្វើការជាមួយកុមារ OVC និងចែករំលែកព័ត៌មានដើម្បីពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិរបស់ក្រសួង បូកសរុបលទ្ធផលការងារភាពជាដៃគូ ដែលសហការរៀបចំដោយ ក្រសួង ស.អ.យ អង្គការ យូនីសេហ្វ និងអង្គការ FI (ចំនួន**០៥**លើក)។
- បានចូលរួមកិច្ចប្រជុំប្រឹក្សាគម្រោង ILO-Triangle នៅប្រទេសកម្ពុជា ស្តីពីទេសន្តរប្រវេសន៍ ។
- បានរៀបចំ និងដឹកនាំកិច្ចប្រជុំប្រមូលមតិយោបល់ដែលបានមកពីការចុះអនុវត្តសាកល្បង លើសេចក្តីព្រាងឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។
- បានរៀបចំកិច្ចប្រជុំពិភាក្សា កិច្ចការផ្សេងៗទាក់ទងនឹងអំពើជួញដូរមនុស្សជាមួយមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ចំនួន០៥លើក ។
- បានចូលរួមប្រជុំស្តីពីការពិនិត្យផ្សព្វផ្សាយ ស្តីពីសមាហរណកម្មនៃបុរសខ្មែរដែលត្រូវគេជួញដូរ និងលើបទដ្ឋានអប្បបរមា ស្តីពីការផ្តល់យោបល់បឋមដល់ជនរងគ្រោះ ចំនួន០២លើក ។
- បានចូលរួមកិច្ចប្រជុំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅសាលប្រជុំ គ.ជ.ប.ជ ។
- បានចូលរួមប្រជុំពិភាក្សាការងារទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនាឆ្នាំ២០១៥។
- បានចូលរួមកិច្ចប្រជុំអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិទេសន្តរប្រវេសន៍និងគ្រួសាររបស់ពួកគេនៅក្រសួងការងារនិបណ្តុះបណ្តាលវិជ្ជាជីវៈ(ចំនួន២លើក)
- បានចូលរួមពិធីធ្វើបទបង្ហាញស្តីពីការប្រយុទ្ធប្រឆាំងអំពើធ្វើអាជីវកម្មផ្លូវភេទលើកុមារនៅប្រទេសក

| | |
|---|---|
| | ម្ពុជាដែលរៀបចំដោយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ។ |
| **ក្រសួងកិច្ចការនារី** | • រៀបចំកិច្ចប្រជុំត្រួតពិនិត្យ កែសម្រួល ពិភាក្សា និងពិគ្រោះយោបល់ជាមួយសមាជិកក្រុមការងារខមមីតកម្ពុជាជាច្រើនលើក សម្រេចបាន៖<br>- របាយការណ៍សកម្មភាពការងារខមមីតកម្ពុជាឆ្នាំ២០១៤ និងទិសដៅឆ្នាំ២០១៥<br>- របាការណ៍អនុវត្តផែនការកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុ តំបន់ទន្លេមេគង្គលើកទៅ៣(SPA III) ឆ្នាំ២០១១-២០១៤<br>- ផែនការសកម្មភាពឆ្នាំ២០១៦ របស់ក្រុមសហប្រតិបត្តិការអន្តរជាតិដែលមាន៥ផ្នែក និងជាង៥០សកម្មភាព<br>• រៀបចំកិច្ចប្រជុំត្រៀមសម្រាប់កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីតលើកទី១០(SOM10) និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៃដំណើរការខមមីតលើកទី៤(IMM4) ជាច្រើនលើកសម្រេចបាន៖<br>- អនុម័តសេចក្តីថ្លែងការណ៍រួមលើកទី៣ នៃដំណើរការខមមីត ឆ្នាំ២០១៥ ស្តីពីការប្តេជ្ញាចិត្តរបស់ប្រទេសសមាជិកខមមីតទាំង៦ ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរ មនុស្ស<br>- អនុម័តផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់ទន្លេមេគង្គ(SPA IV) ឆ្នាំ២០១៥-២០១៨<br>- ប្រទេសមាជិកខមមីតស្វាគមន៍ក្នុងការពិភាក្សាធ្វើMOUរវាងប្រទេសនិងប្រទេស<br>• រៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងដកបទពិសោធន៍ពីកិច្ចប្រជុំ SOM10 និងIMM4<br>• បៀបចំកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលនៃការសិក្សា អំពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកចំពោះគ្រួសារ និងសហគមន៍<br>• បានទទួលជួបស្វាគមន៍ ដើម្បីស្វែងយល់អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា០៦លើក |
| **ក្រសួងអប់រំ យុវជន និងកីឡា** | • បានប្រជុំលើកទី១ដើម្បីប្រកាសសមាសភាព តួនាទី ភារកិច្ចរបស់ក្រុមការងារបង្ការ ទប់ស្កាត់ និងកសាងផែនការសកម្មភាពអនុវត្តសម្រាប់ឆ្នាំ២០១៤-២០១៨។<br>• បានប្រជុំជាមួយអង្គការទេសន្តរប្រវេសន៍ (IOM) ដើម្បីពិភាក្សាលើការរៀបចំសេចក្តីព្រាងMOU ស្តីពីការសហការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>• បានប្រជុំណែនាំមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តទាំង២៥ និងគ្រឹះស្ថាន ឧត្តមសិក្សាសាធារណៈក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ចំនួន០៩ ដើម្បី ប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០១៥ នៅតាមវិទ្យាល័យចំនួន៤៥៥ និងគ្រឹះស្ថានឧត្តមសិក្សាចំនួន០៩។ |

| | |
|---|---|
| ខេត្តឧត្តរមានជ័យ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០៤លើក |
| ខេត្តបាត់ដំបង | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន១៤លើក |
| ខេត្តសៀមរាប | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន១៥លើក |
| ខេត្តកំពង់ស្ពឺ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០១លើក |

| | |
|---|---|
| ខេត្តកណ្ដាល | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន១៣លើក |
| ខេត្តស្វាយរៀង | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន១៣លើក |
| ខេត្តព្រៃវែង | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០២លើក |
| ខេត្តក្រចេះ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០៥លើក |
| ខេត្តកំពង់ចាម | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០២លើក |
| ខេត្តត្បូងឃ្មុំ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០៤លើក |
| ខេត្តកំពត | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន១០លើក |
| ខេត្តព្រះវិហារ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន១១លើក |
| ខេត្តព្រះសីហនុ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០៩លើក |
| ខេត្តតាកែវ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន១៥លើក |
| ខេត្តបន្ទាយមានជ័យ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០៥លើក |
| ខេត្តកោះកុង | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០៨លើក |
| ខេត្តស្ទឹងត្រែង | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០១លើក |

## ២.ឃ. ការលើកកម្ពស់សមត្ថភាព

### ២.ឃ.១.ការខារបណ្ដុះបណ្ដាលសមត្ថភាព

ក្នុងឆ្នាំ២០១៥នេះ ដោយមានសហការជាមួយអង្គការដៃគូជាតិ និងអន្តរជាតិ មានជាអាទិ៍៖ អង្គការ World Vision, USAID, WINROCK, terre des hommes cambodia ACT' s UNACT, COCD,IOMសមាគមន៍ កុមារនឹងជីវិត CLA អគ្គលេខាធិការដ្ឋាន ក៏ដូចជាលេខាធិការដ្ឋានរាជធានី-ខេត្ត បានធ្វើការបណ្ដុះបណ្ដាលសរុបបានចំនួន៩០វគ្គ ដល់សិក្ខាកាមជាមន្ត្រីលេខាធិការដ្ឋាននៃ គណៈកម្មាធិការ រាជធានី ខេត្ត ក្រុមប្រឹក្សាឃុំ សង្កាត់ គ្រូបង្គោលណែនាំតម្រង់ទិសមុនចេញដំណើរ មន្ត្រីអនុវត្តន៍ច្បាប់ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកអង្គការ និងប្រតិបត្តិករទេសចរណ៍ នៅតាមសណ្ឋាគារ សរុបបានចំនួន ៦,៤៥១នាក់ (ស្រី១,៧២៦នាក់) ។ វគ្គបណ្ដុះបណ្ដាលបានផ្ដោតជាសំខាន់ទៅលើចំណេះដឹងអំពីច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការស៊ើបអង្កេតឆ្លងដែន ការប្រមូលភស្តុតាង ជនរងគ្រោះដោយអំពើជួញដូរ បទដ្ឋានអប្បបរមាស្ដីពីសិទ្ធិការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សចំណាក ស្រុកដោយសុវត្ថិភាព ការទប់ស្កាត់អំពើជួញដូរមនុស្ស ការអភិវឌ្ឍស្ត្រី ការពង្រឹងកិច្ចការពារកុមារ សិទ្ធិកុមារ ការបង្ការនៃការរំលោភបំពានផ្សេងៗលើស្ត្រី និងកុមារ ជំនាញអន្តរាគមន៍ជួយដល់ជនរងគ្រោះ ក្នុងនោះមាន ដូចតារាងខាងក្រោម៖

*តារាងវគ្គបណ្តុះបណ្តាល*

| ល.រ | ស្ថាប័នអនុវត្ត | ចំនួនវគ្គ | សិក្ខាកាមចូលរួម | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | ២៧ | ១,៦៣៨ | ៤៨៧ |
| ២ | ក្រសួងកិច្ចការនារី | ០៣ | ៩០ | ៨៩ |
| ៣ | ក្រសួងទេចរណ៍ | ១៣ | ៥៩៩ | ២២៨ |
| ៤ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តពោធិ៍សាត់ | ០៤ | ២,១១៦ | ៦៣ |
| ៥ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តកំពង់ឆ្នាំង | ០៣ | ១៧០ | ១៩ |
| ៦ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តកំពង់ស្ពឺ | ០៣ | ១១៩ | ២៩ |
| ៧ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តរតនគិរី | ០៥ | ៣៤៨ | ៩៤ |
| ៨ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តស្ទឹងត្រែង | ០១ | ៦៥ | ១៥ |
| ៩ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តកំពង់ចាម | ០១ | ៥៤ | ១៦ |
| ១០ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តត្បូងឃ្មុំ | ០១ | ៥៣ | ០៧ |
| ១១ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តមណ្ឌលគិរី | ០១ | ៤៨ | ១៥ |
| ១២ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តព្រះសីហនុ | ០៥ | ១៦៩ | ៧៧ |
| ១៣ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តតាកែវ | ០២ | ១៦០ | ១១៦ |
| ១៤ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តកណ្តាល | ០៥ | ១៥៩ | ៨៤ |
| ១៥ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តស្វាយរៀង | ០២ | ៨១ | ៣៣ |
| ១៦ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តព្រៃវែង | ០១ | ៧១ | ២១ |
| ១៧ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តព្រះវិហារ | ០១ | ៣៩ | ១៦ |
| ១៨ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តកំពត | ០១ | ៥៨ | ២៥ |
| ១៩ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តក្រចេះ | ១១ | ៤១៤ | ២៩២ |
| **សរុប** | | **៩០វគ្គ** | **៦,៤៥១នាក់** | **១,៧៣៤នាក់** |

## ២.ឃ.២. សិក្ខាសាលា

ក្រសួងស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូជាតិ និងអន្តរជាតិ រៀបចំ និងចូលរួមសិក្ខាសាលាថ្នាក់តំបន់ផ្តោតលើប្រធានបទសំខាន់ៗដែលជាកិច្ចការអាទិភាពទាក់ទងនឹងការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស បានចំនួន**២០**លើក ក្នុងនោះមាន៖

- **អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិគ.ជ.ប.ជ**បានចូលរួមជាអធិបតីក្នុងកម្មវិធីបើកសិក្ខាសាលារបស់អង្គការ LSCW ស្តីពីការកសាងសមត្ថភាព និងចែករំលែកព័ត៌មានអំពីនីតិវិធីក្នុងការដោះស្រាយវិវាទទាក់ទងទេសន្តរប្រវេសន៍ការងារ នៅសណ្ឋាគារ Imperial Garden ភ្នំពេញ។

- **ក្រុមបច្ចេកទេសជំនួយកិច្ចការអនុវត្តន៍ច្បាប់** អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចូលរួមសិក្ខាសាលាស្តីអំពីយុវជន និងការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាជួញដូរមនុស្ស ដែលបានរៀបចំដោយអង្គការយុវជនអាស៊ាន តាមរយៈអង្គការ WINROCKនិងឧបត្ថម្ភដោយ USAIDនៅសាលាភូមិន្ទនីតិសាស្ត្រ ។
- **ក្រសួងកិច្ចការនារី** បានរៀបចំសិក្ខាសាលា ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស បូកសរុបលទ្ធផលការងារ ឆ្នាំ២០១៥ និងលើកទិសដៅបន្ត ដែលមានការចូលរួមពីប្រធាន ឬអនុប្រធានមន្ទីរកិច្ចការនារីទាំង២៥រាជធានី ខេត្ត។
- **ក្រសួងអប់រំ យុវជន និងកីឡា**
  - បានបើកសិក្ខាសាលាតម្រង់ទិសស្តីពីការប្រើប្រាស់ឧបករណ៍ផ្សព្វផ្សាយការធ្វើ ចំណាកស្រុកប្រកបដោយសុវត្ថិភាព និងបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សនៅតាមភោជនីយដ្ឋាន អ័រគីដឺ ដែលមានសិក្ខាកាមចូលរួមសរុប**២៩**នាក់ ស្រី**០៧**នាក់។
  - បានបើកសិក្ខាសាលា ស្តីពីក្របខណ្ឌច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសិក្ខាកាមចូលរួម ចំនួន**៧៥**នាក់ ស្រី**០៧**នាក់។
- **លេខាធិការដ្ឋានខេត្តស្វាយរៀង** បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ជាមួយក្រុមការងារចម្រុះស្តីពីការឆ្លើយតបភាពងាយរងគ្រោះដោយអំពើជួញដូរមនុស្ស នៅតំបន់សេដ្ឋកិច្ចពិសេសរោងចក្រសេដ្ឋកិច្ចផ្សេងៗ នៃប្រទេសកម្ពុជា-ឡាវ-វៀតណាម សហការគាំទ្រដោយអង្គការ IOM នៅសាលប្រជុំសណ្ឋាគារ វ៉ែកូ ខេត្តស្វាយរៀង ។
- **លេខាធិការដ្ឋានខេត្តក្រចេះ** បានធ្វើសិក្ខាសាលាការផ្សព្វផ្សាយ ស្តីពីសិទ្ធិកុមារ និងការទប់ស្កាត់អំពើជួញដូរមនុស្ស នៅតាមសហគមន៍ចំនួន**១២**វគ្គ ។
- **លេខាធិការដ្ឋានខេត្តបាត់ដំបង**
  - មន្ទីរអប់រំ ,មន្ទីរសង្គមកិច្ច ,មន្ទីរការងារ ,មន្ទីរកិច្ចការនារី ,មន្ទីរកសិកម្ម និងអង្គភាពជលផលខេត្តបានសហការជាមួយអង្គការទស្សនពិភពលោកខេត្តបាត់ដំបង បានធ្វើសិក្ខាសាលា ស្តីពីការកាត់បន្ថយពលកម្ម កុមារ និងការលប់បំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ចំនួន០១លើក មានអ្នកចូលរួមចំនួន៥២នាក់ ស្រីចំនួន១០ នាក់។
  - ខេត្តបាត់ដំបង បានសហការជាមួយ ខេត្តបន្ទាយមានជ័យ ,សៀមរាប និងអង្គការទស្សនពិភពលោក បានរៀប ចំសិក្ខាសាលា ស្តីពីការចែករំលែកបទពិសោធ៍ ការរៀនសូត្រ និងការអនុវត្តគម្រោងពង្រឹងសមត្ថភាព នៃដៃគូ ការងារនៅក្នុងមូលដ្ឋាន ដើម្បីសកម្មភាពប្រយុទ្ធប្រឆាំងពលកម្មកុមារចំនួន០១លើក មានអ្នកចូលរួមចំនួន ១០៣នាក់ ស្រី ចំនួន៦៨ នាក់។

# ៣. ការសន្និដ្ឋាន និង វាយតម្លៃ

សរុបរបាយការណ៍ សកម្មភាព និងលទ្ធផលការងារ ឆ្នាំ២០១៥ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) យើងអាចធ្វើការសន្និដ្ឋានបានថា អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងអំពើជួញដូរផ្លូវភេទលើស្ត្រីនិងកុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានការថយចុះបើប្រៀបធៀបនឹងឆ្នាំកន្លងទៅ ។ ដោយឡែក ការអប់រំផ្សព្វផ្សាយ បានដល់ប្រជាពលរដ្ឋគ្រប់មុខសញ្ញាជាពិសេសយុវជន រហូតដល់ទៅជាងបីលាននាក់ ដែលកើនលើសឆ្នាំ២០១៤ រហូតដល់ទៅ១៨៥% ។ ប្រជាពលរដ្ឋមានយល់ដឹងកាន់តែច្រើន អំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ចំណាកស្រុកមិនស្របច្បាប់ផលប៉ះពាល់ និងយល់ដឹងអំពីល្បិចកលរបស់មេខ្យល់ ឬជនឆបោក ។ ចំណែកឯប្រតិបត្តិការបង្ក្រាបបទល្មើសជួញដូរមនុស្ស និងការផ្តន្ទាទោស បានកើនឡើងគួរឲ្យកត់សម្គាល់ ។

## ៣.១.ចំណុចខ្លាំង

- ឆន្ទៈនយោបាយដ៏មុះមុត និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ដែលកំណត់យកបញ្ហាជួញដូរមនុស្សជាអាទិភាពមួយក្នុងចំណោមបញ្ហាជាអាទិភាពដទៃទៀតដែលត្រូវដោះស្រាយ ព្រោះអំពើនេះគឺជាការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ និងបានធ្វើឲ្យប៉ះពាល់ដល់និងអធិបតេយ្យភាពបុគ្គល ដែលជាធនធានមនុស្សសម្រាប់សក្តានុពលសេដ្ឋកិច្ច និងសង្គមជាតិ ។
- ព្រះរាជាណាចក្រកម្ពុជា មានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌ ដែលជាមូលដ្ឋាននៃការអនុវត្ត ព្រមទាំងបានបង្កើតនូវបទដ្ឋានគតិយុត្តិមួយចំនួនទៀត ដើម្បីបំពេញបន្ថែមលើការខ្វះខាត និងសម្រួលដល់ការអនុវត្ត ឲ្យរឹតតែមានប្រសិទ្ធភាពទ្វេឡើងថែមទៀត។
- មានការលើកទឹកចិត្ត និងការគាំទ្រ របស់ប្រមុខរាជរដ្ឋាភិបាលដល់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាយន្តការជាតិដើម្បីដឹកនាំ សម្របសម្រួលកិច្ចសហការជាពហុវិស័យ ពីគ្រប់ស្ថាប័នពាក់ព័ន្ធ និងជាមួយបណ្តាប្រទេសពាក់ព័ន្ធ ដើម្បីបង្ក្រាបអំពើជួញដូរមនុស្ស គ្រប់រូបភាព រួមទាំងការធ្វើអាជីវកម្មលើពលកម្មមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។
- មានផែនការ និងយុទ្ធសាស្ត្រដ៏ទូលំទូលាយគឺ ការបង្ការទប់ស្កាត់ ការបង្ក្រាប ការផ្តន្ទាទោសជនល្មើស និងការការពារជនរងគ្រោះ ដោយផ្តល់សេវាស្តានីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្តន៍ ដោយយកចិត្តទុកដាក់ជាពិសេសចំពោះការការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ។
- មានរចនាសម្ព័ន្ធទូលំទូលាយ តាំងពីថ្នាក់ជាតិ ដល់មូលដ្ឋាន មានការចាត់តាំងច្បាស់លាស់ និងមានការបណ្តុះបណ្តាល អំពីតួនាទីភារកិច្ច ជាប្រតិបត្តិករធ្វើឲ្យសម្រេចផែនការជាតិ ផែនការតាមបណ្តាថ្នាក់

ដោយមានការគាំទ្រធនធាន ពីថវិកាជាតិ និងបើកទូលាយឲ្យមានការចូលរួម ឧបត្ថម្ភ គាំទ្រ ពីបណ្តាដៃគូជាតិ និងអន្តរជាតិដើម្បីរួមគ្នាជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុប ។

- គោលនយោបាយជាតិ ស្តីពីទេសន្តរប្រវេសន៍ការងារកម្ពុជា គោលនយោបាយស្តីពីសោធននិវត្តន៍ ការតំឡើងបៀវត្សរ៍កម្មករ ការកែលម្អល័ក្ខខ័ណ្ឌការងារក្នុងស្រុក ការបង្កើតមណ្ឌលផ្តល់ព័ត៌មានស្តីពីទីផ្សារការងារ ការផ្តល់លិខិតឆ្លងដែនពិសេសដល់ពលករទេសន្តរប្រវេសន៍...។ល។ គឺជាការផ្តល់នូវកាលានុវត្តភាព និងជម្រើសដល់ប្រជាពលរដ្ឋ ឲ្យទទួលបានការងារ និងប្រាក់ចំណូលសមរម្យ មានសុវត្ថិភាព និងកាត់បន្ថយភាពប្រថុយប្រថាន នឹងគ្រោះថ្នាក់របស់ពលករកម្ពុជា ។
- បានបំពេញនូវចំណុចខ្វះខាតដែលនៅសេសសល់ពីឆ្នាំ២០១៤ ហើយបាន និងកំពុងអនុវត្តបន្ត ដែលក្នុងនោះការងារបង្ការ ទប់ស្កាត់ និងការផ្តន្ទាទោស និងបានពិនិត្យកែសម្រួលបែបបទនីតិវិធី ដើម្បីធ្វើឲ្យមានការប្រសើរឡើងនូវនីតិវិធីក្នុងការជួយជនរងគ្រោះ ការថែទាំ ការស្តារនីតិសម្បទា ដោយផ្តោតការយកចិត្តទុកដាក់លើស្ត្រី និងកុមារ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម។
- គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ដែលមានក្រសួងមហាផ្ទៃជាស្នូលគឺជាយុទ្ធសាស្ត្រនៃការប្រមូលផ្តុំកម្លាំងចលករដ៏សំខាន់បំផុត ដែលបំផុសឲ្យគ្រប់ក្រសួង ស្ថាប័ន អង្គភាព អង្គការសង្គមស៊ីវិល សមត្ថកិច្ចជំនាញគ្រប់ផ្នែក និងប្រជាពលរដ្ឋ គ្រប់រូប រួមសហការគ្នាបង្ការទប់ស្កាត់រាល់បទល្មើស និងឈានទៅចាប់ខ្លួនជនដែលប្រព្រឹត្តបទល្មើសនោះមកផ្តន្ទាទោសតាមនីតិវិធីច្បាប់ ។

## ៣.២. ចំណុចខ្សោយ និងបញ្ហាប្រឈម

ទោះបីជាមានចំណុចខ្លាំងយ៉ាងច្រើន ដូចបានរៀបរាប់ខាងលើក្តី ក៏នៅមានសេសសល់នូវភាពខ្វះចន្លោះ និងចំណុចប្រឈមជាអវិជ្ជមានមួយចំនួន ដែលធ្វើឲ្យរាំងស្ទះ ដល់ការធ្វើឲ្យសម្រេចបាននូវគោលដៅទាំងប៉ុន្មាន តាមការរំពឹងទុក ដែលចាំបាច់ត្រូវកែលម្អ និងជម្នះឲ្យបាន ។ ចំណុចទាំងនោះ មានជាអាទិ៍៖

- ទោះបីជាព័ត៌មានដែលបានផ្តល់តាមរយៈការអប់រំ ផ្សព្វផ្សាយដែលធ្វើយ៉ាងទូលំទូលាយហើយក្តី ក៏អ្នកដែលមិនយកចិត្តទុកដាក់ នៅតែមិនយល់ មួយចំនួននៅតែមិនបានទទួល ដោយការផ្សព្វផ្សាយបានដល់តែអ្នកបានចូលរួម មួយចំនួននៅតែមិនជឿ នៅតែចង់សាកល្បង នៅតែចាញ់បោកមេខ្យល់ព្រោះតែចង់មានចង់បាន កលល្បិចជនឆបោកកាន់តែទំនើប និងបត់បែន ឯសមត្ថភាពមន្ត្រីអ្នកអប់រំផ្សព្វផ្សាយខ្លះនៅមានកម្រិត មិនមានការយល់ដឹងទូលំទូលាយអំពីកលល្បិចរបស់ជនខិលខូច និងតាមមិនទាន់សភាពការណ៍ មធ្យោបាយផ្សព្វផ្សាយមិនទាន់បានប្រើប្រាស់អស់លទ្ធភាព ជាពិសេសវិទ្យុ ទូរទស្សន៍ ។
- ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅខ្វះខាត តាមតំបន់ និងតាមរដូវកាល ខ្វះចំណេះដឹងជំនាញដែលឆ្លើយតបទៅនឹងទីផ្សារ ទាំងក្នុងស្រុក ទាំងនៅក្រៅប្រទេស ដែលអាចប្រកួតប្រជែងយកកម្រិតបៀវត្សរ៍ខ្ពស់ និងការធានាល័ក្ខខ័ណ្ឌការងារត្រឹមត្រូវ ។ មួយចំនួនធំ ជាពលករដែល

គ្មានជំនាញ ឬមានជំនាញទាប និងមិនមានជម្រើសសម្រាប់ការសម្រេចចិត្ត ហើយត្រូវធ្វើទាំងប្រថុយប្រថាន ទោះបីបានដឹងពីគ្រោះថ្នាក់ដែលអាចកើតមានក៏ដោយ ។

- សមត្ថភាព និងធនធានមួយចំនួនដែលចាំបាច់សម្រាប់ការអនុវត្តច្បាប់ និងផែនការ របស់ក្រសួង មន្ទីរ ស្ថាប័ន អង្គភាពសម្រាប់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅមានកម្រិត ដែលទាមទារឲ្យស្ថាប័ននីមួយៗយកចិត្តទុកដាក់ ពង្រឹងបន្ថែម ទៀតទើបអាចឆ្លើយតបទៅនឹងសភាពការណ៍បទល្មើសឲ្យមានប្រសិទ្ធភាពបាន។
- កិច្ចសហការរវាងក្រសួង ស្ថាប័ន អង្គភាព ដែលមានសមត្ថកិច្ចពាក់ព័ន្ធនៅមានខ្វះចន្លោះដោយអន្លើ អាស្រ័យការឲ្យតម្លៃទៅលើប្រសិទ្ធភាពនៃកិច្ចសហការ និងការងារជាប្រព័ន្ធនៅមានកម្រិតនៅឡើយ ជាពិសេស ក្នុងការងារអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការទទួលខុសត្រូវក្នុងការងារជួយជនរងគ្រោះ ការត្រួតពិនិត្យរបៀបរបបការងារ និងការទទួលខុសត្រូវរបស់ក្រុមហ៊ុនក្នុងការជ្រើសរើស បណ្តុះបណ្តាល បញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ការតាមដានសុវត្ថិភាពពលករដែលបានបញ្ជូន ក្នុងវដ្តនៃទេសន្តរប្រវេសន៍ រហូតដល់ការបញ្ជូនត្រឡប់មាតុប្រទេសប្រកបដោយសុវត្ថិភាព ពេលបញ្ចប់ការងារជាដើម ។
- ការចាត់វិធានការតាមផ្លូវច្បាប់ ចំពោះភ្នាក់ងារ ឬក្រុមហ៊ុនណាដែលប្រព្រឹត្ត ផ្ទុយពីនីតិវិធី និងគោលការណ៍ណែនាំដែលបានកំណត់ បង្កឲ្យពលកររងគ្រោះជាបន្តបន្ទាប់ នៅមានកម្រិត ។
- ក្រុមការងារអន្តរក្រសួង និងរចនាសម្ព័ន្ធ និងការចាត់តាំងមន្ត្រីទទួលខុសត្រូវរហូតដល់មូលដ្ឋានឃុំសង្កាត់ របស់គណៈកម្មាធិការរាជធានី/ខេត្ត មួយចំនួន មិនទាន់បានដំណើរការ និងមិនទាន់ពង្រឹងរបៀបរបបការងារនៅឡើយ ជាហេតុធ្វើឲ្យរបាយការណ៍ ការរៀបចំផែនការសកម្មភាព និងថវិកា មិនទាន់ពេលវេលា និងនៅតែខ្វះធនធានអនុវត្ត ។
- គណៈកម្មាធិការរាជធានី ខេត្ត ខ្លះ មិនទាន់ប្រមូលផ្តុំ និងតាមដានការអនុវត្តរបស់អង្គការសង្គមស៊ីវិលក្នុងស្រុក និងអន្តរជាតិមួយចំនួន ដែលមិនមានគោលដៅ និងសកម្មភាពពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឲ្យចូលរួមធ្វើកិច្ចសហការក្នុងដំណើរការអនុវត្តផែនការរួម ជៀសវាងការធ្វើសកម្មភាពដែលមិនស៊ីចង្វាក់គ្នា និងមិនអាចប៉ាន់ប្រមាណបានអំពីប្រសិទ្ធភាពក្នុងការឆ្លើយតបទៅនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បាន ។
- ការតាមដានត្រួតពិនិត្យសុវត្ថិភាពពលករ និងសកម្មភាពក្រុមហ៊ុន ដែលទទួលបានសិទ្ធិអនុញ្ញាតជ្រើសរើសពលករទៅធ្វើការងារនៅបរទេស នៅមានកម្រិត ។
- ខ្វះវិធានការគ្រប់គ្រងអ្នកដែលទៅរកការងារដោយមិនស្របច្បាប់ និងដែលរង់ចាំទទួលភាពស្របច្បាប់នៅឯក្រៅប្រទេស ជាជាងអនុវត្តតាមគោលការណ៍ច្បាប់ជាតិ និងអនុស្សរណៈកន្លងមក ដែលមានគោលបំណង ធ្វើការបញ្ជូនពលករស្របច្បាប់ទៅក្រៅប្រទេស ដោយមានការធានា ពីរដ្ឋាភិបាល ។

# ៤. ទិសដៅ ឆ្នាំ២០១៦

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានធ្វើការប្រជុំពិភាក្សាលើកទិសដៅការងារសម្រាប់អនុវត្តបន្តនៅឆ្នាំ២០១៦ មានដូចខាងក្រោមៈ

១. ជំរុញការអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់ ០៤ចំណុច របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជាណាចក្រកម្ពុជា** ថ្លែងក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០១៥ នៅសាលមហោស្រព នៃមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍ កោះពេជ្រ រាជធានីភ្នំពេញ និងគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល លេខ០០១ គកន ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរទេសន្តរប្រវេសន៍ ។

២. បន្តជំរុញអនុវត្ត វិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

៣. រៀបចំសកម្មភាពវាយតម្លៃផែនការសកម្មភាពជាតិ ២០១៣-២០១៨ ពាក់កណ្តាលអណត្តិ និងកែលម្អសកម្មភាពជំហានបន្តរហូតដល់ឆ្នាំ២០១៨ ។

៤. រៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធ នឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ ទាំងតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ និងជំរុញអនុវត្ត ។

៥. ត្រៀមសេចក្តីព្រាងផែនការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី កម្ពុជា-ចិន ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ បង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

៦. ធ្វើការស្រាវជ្រាវអំពីកាលានុវត្តភាពការងារជាជម្រើសរបស់ពលករកម្ពុជាក្នុងនិងក្រៅប្រទេស និងស្វែងយល់ពីកត្តារុញច្រាន និងអូសទាញ ដើម្បីរៀបចំផែនការបង្ការទប់ស្កាត់ ។

៧. ត្រៀមកិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន ដើម្បីពិនិត្យសម្រេចលើសេចក្តីព្រាង កិច្ចព្រមព្រៀង ដែលបានឯកភាពគ្នាជាគោលការណ៍រួចហើយ កាលពីជំនួប នៅប្រទេសចិន នា ខែវិច្ឆិកា ឆ្នាំ២០១៥ ។

៨. ត្រៀមពិនិត្យ កិច្ចព្រមព្រៀង ទ្វេភាគី កម្ពុជា-ឥណ្ឌា តាមការស្នើសុំរបស់ រដ្ឋាភិបាលឥណ្ឌា ។

៩. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់ រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាលេស៊ី..) ដើម្បីពង្រឹងកិច្ចសហការដើម្បីចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ-និយោជក និងរវាង ប្រទេសបញ្ជូន និងប្រទេសទទួល ប្រកបដោយសមធម៌ ។

១០. បន្តពង្រីកកិច្ចសហការទូលំទូលាយ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្ស ក្នុងព្រះរាជាណាចក្រកម្ពុជា និងទៅលើប្រជាជនកម្ពុជា ។

១១. ជំរុញការអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តិនានា ទៅតាមមុខសញ្ញានៃក្រសួង ស្ថាប័ន និងអង្គភាពដែលទទួលខុសត្រូវ ឈានទៅធ្វើឲ្យសម្រេចគោលដៅរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

១២.សម្របសម្រួល ពង្រឹង និងពង្រីកកិច្ចសហការឲ្យបានទូលំទូលាយជាមួយគ្រប់ផ្នែក គ្រប់វិស័យ និងរវាងរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន ដើម្បីអនុវត្តយុទ្ធសាស្ត្រ ដែលបានគ្រោងទុកក្នុងផែនការជាតិ ផែនការក្រុម និងផែនការរាជធានីខេត្ត ។

១៣. គាំទ្រ និងពង្រឹងសមត្ថភាព របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត ដោយពង្រឹងរបបប្រជុំ និងរបាយការណ៍ឲ្យបានទៀងទាត់ តាមដានត្រួតពិនិត្យ វាយតម្លៃ និងដកបទពិសោធន៍ការងារឲ្យទទួលបានលទ្ធផលការងារល្អប្រសើរ ។

១៤.បន្តការងារផ្សព្វផ្សាយ អប់រំ តាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការជួញដូរ និងកេងប្រវ័ញ្ចពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍និងអំពើជួញដូរមនុស្សនិងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ និងជនដែលងាយរងគ្រោះ។

១៥.បន្តពង្រីកសហការជាមួយប្រទេសក្នុងតំបន់ និងជាមួយបណ្ដាប្រទេសនានានៅលើសកលលោក ដើម្បីពង្រឹងការអនុវត្ត អនុសញ្ញា និងកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគីដែលមានកន្លងមក និងពិនិត្យឡើងវិញនូវអនុស្សរណៈ ឬកិច្ចព្រមព្រៀងរវាងកម្ពុជា និងប្រទេសនានាដែលនៅមានចន្លោះខ្វះខាត

១៦. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាព នៃការអនុវត្ត កិច្ចព្រមព្រៀង ទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ាន ប្រឆាំងការជួញដូរមនុស្ស ដែលសម្ដេច**អគ្គមហាសេនាបតី តេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ទើបតែចុះហត្ថលេខារួមគ្នាកាលពី ខែវិច្ឆិកា ឆ្នាំ ២០១៥។

១៧. ជំរុញតាមដាន ត្រួតពិនិត្យ ក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ និង

១៨. បន្តរៀបចំបែបបទ នីតិវិធី សម្រាប់ការផ្ដល់នីតិសម្បទា ដល់មណ្ឌលដែលជួយគាំទ្រជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

១៩. តាមដាន និង ជំរុញការអនុម័តច្បាប់ ស្ដីពីអំពើរត់ពន្ធមនុស្ស ឲ្យបានឆាប់រហ័ស ។

២០. លើកកម្ពស់សមត្ថភាព និងពង្រឹងកិច្ចសហការរវាងមន្ត្រីអនុវត្តន៍ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្ក្រាប បទល្មើស និងផ្ដន្ទាទោសជនល្មើសតាមផ្លូវច្បាប់ ប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌ ។

២១. បន្តពង្រឹងសមត្ថភាព និងកិច្ចខិតខំប្រឹងប្រែង របស់សមត្ថកិច្ចនៅតាមបន្ទាត់ព្រំដែន ទាំងនគរបាលអន្តោប្រវេសន៍ កម្លាំងនគរបាលវរៈព្រំដែន កងកម្លាំងយោធាព្រំដែន ដែលឈរជើងនៅតាមបណ្ដាច្រកនានា ទាំងច្រកអន្តរជាតិ ច្រកតំបន់ និងច្រករបៀង ឲ្យបង្កើនការយកចិត្តទុកដាក់ចំពោះការធ្វើដំណើរឆ្លងកាត់ព្រំដែនរបស់ប្រជាពលរដ្ឋកម្ពុជា និងជនបរទេស ដើម្បីទប់ស្កាត់ការនាំមនុស្សឆ្លងដែនខុសច្បាប់ អំពើជួញដូរមនុស្សតាមគ្រប់រូបភាព។

២២. បន្តរៀបចំផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពជំនាញទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

២៣. គាំទ្រ និងពង្រឹងការអនុវត្ត គោលនយោបាយ ភូមិ/ឃុំ មានសុវត្ថិភាព របស់រាជរដ្ឋាភិបាលឲ្យកាន់តែរឹងមាំនៅក្នុងថ្នាក់មូលដ្ឋាន ដើម្បីជាមធ្យោបាយដ៏មានប្រសិទ្ធភាព ក្នុងការកាត់បន្ថយភាពរងគ្រោះរបស់ប្រជាពលរដ្ឋ រួមទាំងអំពើជួញដូរមនុស្សផងដែរ។

២៤. ជំរុញអនុវត្ត កិច្ចសហប្រតិបត្តិការ ផ្លាស់ប្តូរព័ត៌មាន និងអនុវត្តនីតិវិធីជំនួយផ្នែកច្បាប់ ទៅវិញទៅមក ក្នុងរឿងក្តីជួញដូរមនុស្សឆ្លងដែន រវាងប្រទេសក្នុងតំបន់តាមរយៈអាជ្ញាធរកណ្តាល៕

រាជធានីភ្នំពេញ ថ្ងៃទី...២៩....ខែ...មករា....ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ប្រធានគ.ជ.ប.ជ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី
- គ្រប់សមាភាព នៃគណៈកម្មាធិការជាតិ៖ គ.ជ.ប.ជ
- គ្រប់សមាសភាពក្រុមការងារអន្តរក្រសួង គ.ជ.ប.ជទាំង០៦
- គ្រប់សមាសភាព គ.រ.ប.ជ និងគ.ខ.ប.ជ
- អង្គការដៃគូអភិវឌ្ឍន៍
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

## លទ្ធផលបង្ក្រាបបទល្មើសអាជីវកម្មផ្លូវភេទ និងអំពើជួញដូរមនុស្ស ទូទាំងប្រទេស (ឆ្នាំ២០១៥)
### គិតចាប់ពីថ្ងៃទី ២៦-១២-២០១៤ ដល់ថ្ងៃទី ២៥-១២-២០១៥

| ល.រ | នាយកដ្ឋាន រាជធានី-ខេត្ត | បង្ក្រាបរួម | | | | | | | | អាជីវកម្មផ្លូវភេទ | | | | | | | | ជួញដូរមនុស្ស | | | | | | | | បញ្ជូនជនរងគ្រោះទៅ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បង្ក្រាបរួម | ជនល្មើស | | | ជនរងគ្រោះ | | | | បង្ក្រាប | ជនល្មើស | | | ជនរងគ្រោះ | | | | បង្ក្រាប | ជនល្មើស | | | ជនរងគ្រោះ | | | | មន្ទីរសង្គមកិច្ច | អង្គការ | គ្រួសារ |
| | | | រួម | ស្រី | បរទេស | រួម | -15 | 15-17 | 18+ | | រួម | ស្រី | បរទេស | រួម | -15 | 15-17 | 18+ | | រួម | ស្រី | បរទេស | រួម | -15 | 15-17 | 18+ | | | |
| 1 | បន្ទាយមានជ័យ | 3 | 4 | 1 | | 7 | 2 | | 5 | 3 | 4 | 1 | | 7 | 2 | | 5 | | | | | | | | | 5 | | 2 |
| 2 | បាត់ដំបង | 2 | 4 | 1 | | 14 | 1 | 5 | 8 | 1 | 3 | 1 | | 13 | 1 | 4 | 8 | 1 | 1 | | | 1 | | 1 | | 13 | | 1 |
| 3 | កំពង់ចាម | 6 | 8 | 7 | | 13 | | 1 | 12 | | | | | | | | | 6 | 8 | 7 | | 13 | | 1 | 12 | | | 13 |
| 4 | កំពង់ឆ្នាំង | 4 | 5 | 2 | | 8 | 2 | 2 | 4 | 2 | 2 | 1 | | 5 | 1 | | 4 | 2 | 3 | 1 | | 3 | 1 | 2 | | | | 8 |
| 5 | កំពង់ស្ពឺ | | | | | | | | | | | | | | | | | | | | | | | | | | | |
| 6 | កំពង់ធំ | 5 | 6 | 4 | | 16 | | 1 | 15 | 1 | 1 | 1 | | 6 | | | 6 | 4 | 5 | 3 | | 10 | | 1 | 9 | | | 16 |
| 7 | កំពត | | | | | | | | | | | | | | | | | | | | | | | | | | | |
| 8 | កណ្តាល | 1 | 1 | | | 1 | 1 | | | 1 | 1 | | | 1 | 1 | | | | | | | | | | | | | 1 |
| 9 | កោះកុង | 2 | 2 | 2 | | 8 | | 1 | 7 | 2 | 2 | 2 | | 8 | | 1 | 7 | | | | | | | | | 6 | 2 | |
| 10 | ក្រចេះ | | | | | | | | | | | | | | | | | | | | | | | | | | | |
| 11 | មណ្ឌលគិរី | | | | | | | | | | | | | | | | | | | | | | | | | | | |
| 12 | ភ្នំពេញ | 22 | 37 | 20 | 5 | 56 | 15 | 4 | 37 | 12 | 12 | 4 | 1 | 31 | 13 | 3 | 15 | 10 | 25 | 16 | 4 | 25 | 2 | 1 | 22 | 20 | 1 | 35 |
| 13 | ព្រះវិហារ | 1 | 1 | 1 | | 1 | 1 | | | | | | | | | | | 1 | 1 | 1 | | 1 | 1 | | | | | 1 |
| 14 | ព្រៃវែង | 1 | 1 | 1 | | 2 | | | 2 | | | | | | | | | 1 | 1 | 1 | | 2 | | | 2 | | | 2 |
| 15 | ពោធិ៍សាត់ | | | | | | | | | | | | | | | | | | | | | | | | | | | |
| 16 | រតនគិរី | | | | | | | | | | | | | | | | | | | | | | | | | | | |
| 17 | សៀមរាប | 8 | 9 | 3 | 4 | 16 | 8 | 4 | 4 | 5 | 5 | 1 | 2 | 13 | 8 | 1 | 4 | 3 | 4 | 2 | 2 | 3 | | 3 | | 5 | | 11 |
| 18 | ព្រះសីហនុ | 11 | 12 | 4 | 2 | 18 | 10 | 1 | 7 | 9 | 10 | 3 | 1 | 16 | 9 | | 7 | 2 | 2 | 1 | 1 | 2 | 1 | 1 | | 7 | | 11 |
| 19 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | 3 | 8 | 2 | | 11 | 2 | 3 | 6 | 2 | 5 | 2 | | 9 | 2 | 2 | 5 | 1 | 3 | | | 2 | | 1 | 1 | 8 | | 3 |
| 21 | តាកែវ | 5 | 5 | | 1 | 9 | 2 | 1 | 6 | 3 | 3 | | | 7 | 2 | | 5 | 2 | 2 | | 1 | 2 | | 1 | 1 | 3 | | 6 |
| 22 | ឧត្តរមានជ័យ | | | | | | | | | | | | | | | | | | | | | | | | | | | |
| 23 | កែប | | | | | | | | | | | | | | | | | | | | | | | | | | | |
| 24 | ប៉ៃលិន | 1 | 1 | 1 | | 3 | 2 | 1 | | | | | | | | | | 1 | 1 | 1 | | 3 | 2 | 1 | | | | 3 |
| 25 | នាយកដ្ឋាន | 17 | 22 | 14 | 3 | 96 | 30 | 13 | 53 | 8 | 10 | 6 | | 55 | 10 | 11 | 34 | 9 | 12 | 8 | 3 | 41 | 20 | 2 | 19 | 53 | | 43 |
| 26 | កងរាជអាវុធហត្ថ | 9 | 11 | 2 | | 14 | 7 | | 7 | 9 | 11 | 2 | | 14 | 7 | | 7 | | | | | | | | | 1 | | 13 |
| 27 | ត្បូងឃ្មុំ | 4 | 7 | 6 | 1 | 2 | | | 2 | | | | | | | | | 4 | 7 | 6 | 1 | 2 | | | 2 | | 1 | 1 |
| សរុបរួម | | 105 | 144 | 71 | 16 | 295 | 83 | 37 | 175 | 58 | 69 | 24 | 4 | 185 | 56 | 22 | 107 | 47 | 75 | 47 | 12 | 110 | 27 | 15 | 68 | 121 | 4 | 170 |

## លទ្ធផលបង្ក្រាបបទល្មើស អាជីវកម្មផ្លូវភេទ ទូទាំងប្រទេស (ឆ្នាំ២០១៥)
## គិតចាប់ពីថ្ងៃទី ២៦-១២-២០១៤ ដល់ថ្ងៃទី ២៥-១២-២០១៥

| ល.រ | នាយកដ្ឋាន រាជធានី-ខេត្ត | បង្ក្រាបសរុប | | | | | | | | មាត្រា២១ ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | | | | | | មាត្រា២២ ស្ថានទម្ងន់ទោស (ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង) | | | | | | មាត្រា២៤ អំពើអូសទាញសន្ធារកម្ម | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បង្ក្រាប | ជនរងគ្រោះ | | | | ជនល្មើស | | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | |
| | | | សរុប | -15 | 15-17 | 18 | សរុប | ប | ស | | -15 | 15-17 | 18+ | ប | ស | | -15 | 15-17 | 18+ | ប | ស | | -15 | 15-17 | 18+ | ប | ស |
| 1 | បន្ទាយមានជ័យ | 3 | 7 | 2 | | 5 | 4 | 3 | 1 | | | | | | | | | | | | | | | | | | |
| 2 | បាត់ដំបង | 1 | 13 | 1 | 4 | 8 | 3 | 2 | 1 | | | | | | | | | | | | | | | | | | |
| 3 | កំពង់ចាម | | | | | | | | | | | | | | | | | | | | | | | | | | |
| 4 | កំពង់ឆ្នាំង | 2 | 5 | 1 | | 4 | 2 | 1 | 1 | | | | | | | | | | | | | | | | | | |
| 5 | កំពង់ស្ពឺ | | | | | | | | | | | | | | | | | | | | | | | | | | |
| 6 | កំពង់ធំ | 1 | 6 | | | 6 | 1 | | 1 | | | | | | | | | | | | | | | | | | |
| 7 | កំពត | | | | | | | | | | | | | | | | | | | | | | | | | | |
| 8 | កណ្តាល | 1 | 1 | 1 | | | 1 | 1 | | | | | | | | | | | | | | | | | | | |
| 9 | កោះកុង | 2 | 8 | | 1 | 7 | 2 | | 2 | | | | | | | | | | | | | | | | | | |
| 10 | ក្រចេះ | | | | | | | | | | | | | | | | | | | | | | | | | | |
| 11 | មណ្ឌលគិរី | | | | | | | | | | | | | | | | | | | | | | | | | | |
| 12 | ភ្នំពេញ | 12 | 31 | 13 | 3 | 15 | 12 | 8 | 4 | | | | | | | | | | | | | | | | | | |
| 13 | ព្រះវិហារ | | | | | | | | | | | | | | | | | | | | | | | | | | |
| 14 | ព្រៃវែង | | | | | | | | | | | | | | | | | | | | | | | | | | |
| 15 | ពោធិ៍សាត់ | | | | | | | | | | | | | | | | | | | | | | | | | | |
| 16 | រតនគិរី | | | | | | | | | | | | | | | | | | | | | | | | | | |
| 17 | សៀមរាប | 5 | 13 | 8 | 1 | 4 | 5 | 4 | 1 | | | | | | | | | | | | | | | | | | |
| 18 | ព្រះសីហនុ | 9 | 16 | 9 | | 7 | 10 | 7 | 3 | | | | | | | | | | | | | | | | | | |
| 19 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | 2 | 9 | 2 | 2 | 5 | 5 | 3 | 2 | | | | | | | | | | | | | | | | | | |
| 21 | តាកែវ | 3 | 7 | 2 | | 5 | 3 | 3 | | | | | | | | | | | | | | | | | | | |
| 22 | ឧត្តរមានជ័យ | | | | | | | | | | | | | | | | | | | | | | | | | | |
| 23 | កែប | | | | | | | | | | | | | | | | | | | | | | | | | | |
| 24 | ប៉ៃលិន | | | | | | | | | | | | | | | | | | | | | | | | | | |
| 25 | នាយកដ្ឋាន | 8 | 55 | 10 | 11 | 34 | 10 | 4 | 6 | | | | | | | | | | | | | | | | | | |
| 26 | កងរាជអាវុធហត្ថ | 9 | 14 | 7 | | 7 | 11 | 9 | 2 | | | | | | | | | | | | | | | | | | |
| 27 | ត្បូងឃ្មុំ | | | | | | | | | | | | | | | | | | | | | | | | | | |
| | សរុបរួម | 58 | 185 | 56 | 22 | 107 | 69 | 45 | 24 | | | | | | | | | | | | | | | | | | |

| ល.រ | នាយកដ្ឋាន រាជធានី-ខេត្ត | មាត្រា២៦ សន្ធារកម្ម | | | | មាត្រា២៦ សន្ធារកម្ម (មានអតិថិជន) | | | | | | មាត្រា២៧ ស្ថានទម្ងន់ទោសនៃសន្ធារកម្ម | | | | | | មាត្រា២៨ សន្ធារកម្មទាក់ទងនឹងពេស្យាចារកុមារ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បង្ក្រាប | ជ.គ្រោះ: 18+ | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | |
| | | | | ប | ស | | -15 | 15-17 | 18+ | ប | ស | | -15 | 15-17 | 18+ | ប | ស | | -15 | 15-17 | 18+ | ប | ស |
| 1 | បន្ទាយមានជ័យ | 1 | 5 | 1 | 1 | | | | | | | | | | | | | | | | | | |
| 2 | បាត់ដំបង | | | | | | | | | | | | | | | | | 1 | 1 | 4 | 8 | 2 | 1 |
| 3 | កំពង់ចាម | | | | | | | | | | | | | | | | | | | | | | |
| 4 | កំពង់ឆ្នាំង | 1 | 4 | | 1 | | | | | | | | | | | | | | | | | | |
| 5 | កំពង់ស្ពឺ | | | | | | | | | | | | | | | | | | | | | | |
| 6 | កំពង់ធំ | 1 | 6 | | 1 | | | | | | | | | | | | | | | | | | |
| 7 | កំពត | | | | | | | | | | | | | | | | | | | | | | |
| 8 | កណ្តាល | | | | | | | | | | | | | | | | | | | | | | |
| 9 | កោះកុង | | | | | | | | | | | 1 | | | 4 | | 1 | 1 | | 1 | 3 | | 1 |
| 10 | ក្រចេះ | | | | | | | | | | | | | | | | | | | | | | |
| 11 | មណ្ឌលគិរី | | | | | | | | | | | | | | | | | | | | | | |
| 12 | ភ្នំពេញ | 2 | 9 | 1 | 1 | | | | | | | 2 | 1 | 2 | 3 | | 2 | 1 | | 1 | 2 | | 1 |
| 13 | ព្រះវិហារ | | | | | | | | | | | | | | | | | | | | | | |
| 14 | ព្រៃវែង | | | | | | | | | | | | | | | | | | | | | | |
| 15 | ពោធិ៍សាត់ | | | | | | | | | | | | | | | | | | | | | | |
| 16 | រតនគិរី | | | | | | | | | | | | | | | | | | | | | | |
| 17 | សៀមរាប | | | | | 1 | | 1 | 4 | | 1 | | | | | | | | | | | | |
| 18 | ព្រះសីហនុ | 1 | 1 | | 1 | | | | | | | 1 | | | 6 | | 2 | | | | | | |
| 19 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | | | | | | | | | | | | | | | | | 1 | 1 | 2 | 5 | 2 | 2 |
| 21 | តាកែវ | 1 | 5 | 1 | | | | | | | | | | | | | | | | | | | |
| 22 | ឧត្តរមានជ័យ | | | | | | | | | | | | | | | | | | | | | | |
| 23 | កែប | | | | | | | | | | | | | | | | | | | | | | |
| 24 | ប៉ៃលិន | | | | | | | | | | | | | | | | | | | | | | |
| 25 | នាយកដ្ឋាន | 1 | 4 | | 1 | 1 | | 1 | 3 | | 1 | 1 | | 2 | 4 | 1 | 1 | 4 | | 8 | 23 | 2 | 3 |
| 26 | កងរាជអាវុធហត្ថ | 2 | 7 | 1 | 2 | | | | | | | | | | | | | | | | | | |
| 27 | ត្បូងឃ្មុំ | | | | | | | | | | | | | | | | | | | | | | |
| | សរុបរួម | 10 | 41 | 4 | 8 | 2 | | 2 | 7 | | 2 | 5 | 1 | 4 | 17 | 1 | 6 | 8 | 2 | 16 | 41 | 6 | 8 |

# លទ្ធផលបង្ក្រាបបទល្មើស អាជីវកម្មផ្លូវភេទ ទូទាំងប្រទេស (ឆ្នាំ២០១៥)
## គិតចាប់ពីថ្ងៃទី ២៦-១២-២០១៤ ដល់ថ្ងៃទី ២៥-១២-២០១៥

| ល.រ | នាយកដ្ឋាន រាជធានី-ខេត្ត | មាត្រា២៩ | | | | | | មាត្រា៣០ | | | | | | មាត្រា៣១ | | | | | | មាត្រា៣២ | | | | | | មាត្រា៣៣ | | | | | | មាត្រា៣៤ | | | | | | មាត្រា៤១ | | | | | | មាត្រា៤២ | | | | មាត្រា៤៣ | | | | ជនរងគ្រោះ បញ្ជូនទៅ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សញ្ញារកម្មដោយមាន ការធ្វើទារុណកម្ម | | | | | | ការដឹកនាំពេស្យាចារ | | | | | | ការដឹកនាំគ្រឹះស្ថាន ពេស្យាចារ | | | | | | ការផ្តល់ទីកន្លែង សម្រាប់ធ្វើពេស្យាចារ | | | | | | បទល្មើសទាក់ទងនឹង ពេស្យាចារកុមារ | | | | | | រូបភាព និងសម្ភារៈ អាសអាភាស | | | | | | រូបភាព និងសម្ភារៈ អាសអាភាសនៃកុមារ | | | | | | អំពើរួមភេទ ជាមួយអនីតិ ជនអាយុ | | | | អំពើអាស ប្រឆាំងនឹងអ នីតិជនអាយុ | | | | | | |
| | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជ.គ្រោះ -15 | ជនល្មើស | | បង្ក្រាប | ជ.គ្រោះ -15 | ជនល្មើស | | ម.សង្គមកិច្ច | អង្គការ | គ្រួសារ |
| | | | -15 | 15-17 | 18+ | ប | ស | | -15 | 15-17 | 18+ | ប | ស | | -15 | 15-17 | 18+ | ប | ស | | -15 | 15-17 | 18+ | ប | ស | | -15 | 15-17 | 18+ | ប | ស | | -15 | 15-17 | 18+ | ប | ស | | -15 | 15-17 | 18+ | ប | ស | | | ប | ស | | | ប | ស | | | |
| 1 | បន្ទាយមានជ័យ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 1 | 1 | 1 | | 1 | 1 | 1 | | 5 | | 2 |
| 2 | បាត់ដំបង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 13 | | |
| 3 | កំពង់ចាម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 4 | កំពង់ឆ្នាំង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 1 | 1 | 1 | | | | | | | | 5 |
| 5 | កំពង់ស្ពឺ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 6 | កំពង់ធំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 6 |
| 7 | កំពត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 8 | កណ្តាល | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 1 | 1 | 1 | | | | | | | | 1 |
| 9 | កោះកុង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 6 | 2 | |
| 10 | ក្រចេះ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 11 | មណ្ឌលគិរី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 12 | ភ្នំពេញ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 1 | | | 1 | 1 | | | | | | | | 5 | 7 | 5 | | 1 | 5 | 1 | | 15 | | 16 |
| 13 | ព្រះវិហារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 14 | ព្រៃវែង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 15 | ពោធិ៍សាត់ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 16 | រតនគិរី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 17 | សៀមរាប | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 3 | 5 | 3 | | 1 | 3 | 1 | | 5 | | 8 |
| 18 | ព្រះសីហនុ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 2 | 2 | 2 | | 5 | 7 | 5 | | 7 | | 9 |
| 19 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 1 | 1 | 1 | | | | | | 8 | | 1 |
| 21 | តាកែវ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 2 | 2 | 2 | | | | | | 3 | | 4 |
| 22 | ឧត្តរមានជ័យ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 23 | កែប | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 24 | ប៉ៃលិន | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 25 | នាយកដ្ឋាន | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 1 | 10 | 1 | | 51 | | 4 |
| 26 | កងរាជអាវុធហត្ថ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 7 | 7 | 8 | | | | | | 1 | | 13 |
| 27 | ត្បូងឃ្មុំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | សរុបរួម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 1 | | | 1 | 1 | | | | | | | | 23 | 27 | 24 | | 9 | 26 | 9 | | 114 | 2 | 69 |

**លទ្ធផលបង្ក្រាបបទល្មើសអាជីវកម្មផ្លូវភេទ និងអំពើជួញដូរមនុស្ស ទូទាំងប្រទេស (ឆ្នាំ២០១៥)**

**គិតពីថ្ងៃទី ២៦-១២-២០១៤ ដល់ថ្ងៃទី ២៥-១២-២០១៥**

| ល.រ | ប្រភេទបទល្មើស | មាត្រា | ផ្តន្ទាទោស | ករណី | ជនល្មើស | | | | ជនរងគ្រោះ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | រួម | ស្រី | បរទេស | | សរុប | | -១៥ | | ១៥-១៧ | | ១៨+ | | សង្គមកិច្ច | អង្គការ | គ្រួសារ |
| | | | | | | | រួម | ស្រី | រួម | ស្រី | រួម | ស្រី | រួម | ស្រី | រួម | ស្រី | | | |
| I | **ជួញដូរមនុស្ស** | | | 47 | 75 | 47 | 12 | 3 | 110 | 65 | 27 | 10 | 15 | 11 | 68 | 44 | 7 | 2 | 101 |
| 1 | ការនាំយកអនីតិជន ជាអាទិ៍ចេញដោយមិនស្របច្បាប់ | មាត្រា៩ | ២-៥ | 5 | 6 | 3 | | | 5 | 3 | 2 | 2 | 3 | 1 | | | | | 5 |
| 2 | ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | មាត្រា១០ | ៧-១៥/១៥-២០ | 13 | 18 | 14 | 1 | 1 | 15 | 15 | 1 | 1 | 3 | 3 | 11 | 11 | 2 | | 13 |
| 3 | ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | មាត្រា១១ | ៧-១៥/១៥-២០ | 14 | 27 | 19 | 2 | 1 | 33 | 18 | 2 | | 2 | | 29 | 18 | | 1 | 32 |
| 4 | ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | មាត្រា១២ | ៧-១៥/១៥-២០ | 2 | 2 | 1 | | | 13 | | | | | | 13 | | | | 13 |
| 5 | អំពើលក់ដូរមនុស្ស | មាត្រា១៤ | ២-៥ | 2 | 3 | 2 | 1 | | 2 | 2 | 1 | 1 | | | 1 | 1 | | | 2 |
| 6 | អំពើលក់ដូរមនុស្សដោយមានគោលដៅ | មាត្រា១៥ | ៧-១៥/១៥-២០ | | | | | | | | | | | | | | | | |
| 7 | អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | មាត្រា១៦ | ៧-១៥/១៥-២០ | 4 | 10 | 6 | 3 | 1 | 15 | 15 | | | 1 | 1 | 14 | 14 | 5 | | 10 |
| 8 | ការដឹកជញ្ជូនដោយមានគោលដៅ | មាត្រា១៧ | ៧-១៥/១៥-២០ | | | | | | | | | | | | | | | | |
| 9 | អំពើនាំឆ្លងដែន | មាត្រា១៨ | ៧-១៥/១៥-២០ | | | | | | | | | | | | | | | | |
| 10 | ការទទួលយកមនុស្សដោយមានគោលដៅ | មាត្រា១៩ | ៧-១៥/១៥-២០ | | | | | | | | | | | | | | | | |
| 11 | ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | មាត្រា២០ | ២-៥/៥-១០ | | | | | | | | | | | | | | | | |
| 12 | ការទិញពេស្យាចារកុមារ | មាត្រា៣៤ | ២-៥/៧-១៥ | 7 | 9 | 2 | 5 | | 27 | 12 | 21 | 6 | 6 | 6 | | | | 1 | 26 |
| 13 | អំពើអូសទាញពេស្យាចារកុមារ | មាត្រា៣៥ | ២-៥/៥-១០ | | | | | | | | | | | | | | | | |
| 14 | ការអោយខ្ចីប្រាក់ដោយមានលក្ខខណ្ឌទាក់ទងទៅនឹងអំពើពេស្យាចារកុមារ | មាត្រា៣៦ | ៥-១០ | | | | | | | | | | | | | | | | |
| 15 | កិច្ចសន្យានៃអំពើពេស្យាចារកុមារ | មាត្រា៣៧ | ៥-១០ | | | | | | | | | | | | | | | | |
| 16 | កិច្ចសន្យាសំរាប់អំពើលក់-ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ | មាត្រា៤៥ | | | | | | | | | | | | | | | | | |
| II | **អាជីវកម្មផ្លូវភេទ** | | | 58 | 69 | 24 | 4 | | 185 | 166 | 56 | 37 | 22 | 22 | 107 | 107 | 114 | 2 | 69 |
| 1 | ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | មាត្រា២១ | ៣-៥/៥-១០ | | | | | | | | | | | | | | | | |
| 2 | ស្ថានទម្ងន់ទោស(ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង) | មាត្រា២២ | ១ជីវិត | | | | | | | | | | | | | | | | |
| 3 | អំពើអូសទាញសញ្ចារកម្ម | មាត្រា២៤ | ១ថ្ងៃ-៦ថ្ងៃ | | | | | | | | | | | | | | | | |
| 4 | សញ្ចារកម្ម | មាត្រា២៦ | ២-៥ | 12 | 14 | 10 | | | 50 | 50 | | | 2 | 2 | 48 | 48 | 31 | | 19 |
| 5 | ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | មាត្រា២៧ | ៥-១០ | 5 | 7 | 6 | | | 22 | 22 | 1 | 1 | 4 | 4 | 17 | 17 | 21 | | 1 |
| 6 | សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ | មាត្រា២៨ | ៧-១៥ | 8 | 14 | 8 | | | 59 | 59 | 2 | 2 | 16 | 16 | 41 | 41 | 51 | 2 | 6 |
| 7 | សញ្ចារកម្មដោយមានការធ្វើទារុណកម្ម | មាត្រា២៩ | ១០-២០ | | | | | | | | | | | | | | | | |
| 8 | ការដឹកនាំពេស្យាចារ | មាត្រា៣០ | ២-៥ | | | | | | | | | | | | | | | | |
| 9 | ការដឹកនាំគ្រឹះស្ថានពេស្យាចារ | មាត្រា៣១ | ២-៥ | | | | | | | | | | | | | | | | |
| 10 | ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | មាត្រា៣២ | ២-៥ | | | | | | | | | | | | | | | | |
| 11 | បទល្មើសទាក់ទងនឹងពេស្យាចារកុមារ | មាត្រា៣៣ | ៧-១៥ | | | | | | | | | | | | | | | | |
| 12 | រូបភាព និងសម្ភារៈអាសអាភាស | មាត្រា៣៩ | ៧ថ្ងៃ-១ខែ/១ខែ-១ឆ្នាំ | 1 | 1 | | | | 1 | 1 | | | | | 1 | 1 | | | 1 |
| 13 | រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | មាត្រា៤១ | ២-៥/៥-១០/១០-២០ | | | | | | | | | | | | | | | | |
| 14 | អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | មាត្រា៤២ | ៥-១០ | 23 | 24 | | 1 | | 27 | 24 | 27 | 24 | | | | | 1 | | 26 |
| 15 | អំពើអាសគ្រាមនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | មាត្រា៤៣ | ១-៣ | 9 | 9 | | 3 | | 26 | 10 | 26 | 10 | | | | | 10 | | 16 |
| | **សរុប១២មាត្រា** | | | 32 | 46 | 27 | 7 | 1 | 116 | 88 | 25 | 10 | 25 | 25 | 66 | 53 | 53 | 3 | 60 |
| | **សរុបរួម** | | | 105 | 144 | 71 | 16 | 3 | 295 | 231 | 83 | 47 | 37 | 33 | 175 | 151 | 121 | 4 | 170 |

**តារាងប្រៀបធៀបលទ្ធផលបង្ក្រាបបទល្មើសអាជីវកម្មផ្លូវភេទ និងអំពើជួញដូរមនុស្ស ទូទាំងប្រទេស ( ឆ្នាំ២០១៤ និង២០១៥ )**

**គិតពីថ្ងៃទី ២៦-១២-២០១៤ ដល់ថ្ងៃទី ២៥-១២-២០១៥**

| ល.រ | នាយកដ្ឋាន រាជធានី-ខេត្ត | បង្ក្រាបរួម | | | | | | ជនល្មើស | | | | | | ជនរងគ្រោះ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំ (២០១៤) | | | ឆ្នាំ (២០១៥) | | | ឆ្នាំ (២០១៤) | | | ឆ្នាំ (២០១៥) | | | ឆ្នាំ (២០១៤) | | | ឆ្នាំ (២០១៥) | | |
| | | រួម | អាជីវកម្មផ្លូវភេទ | ជួញដូរមនុស្ស | រួម | អាជីវកម្មផ្លូវភេទ | ជួញដូរមនុស្ស | រួម | អាជីវកម្មផ្លូវភេទ | ជួញដូរមនុស្ស | រួម | អាជីវកម្មផ្លូវភេទ | ជួញដូរមនុស្ស | រួម | អាជីវកម្មផ្លូវភេទ | ជួញដូរមនុស្ស | រួម | អាជីវកម្មផ្លូវភេទ | ជួញដូរមនុស្ស |
| 1 | បន្ទាយមានជ័យ | 7 | 3 | 4 | 3 | 3 | | 7 | 3 | 4 | 4 | 4 | | 84 | 12 | 72 | 7 | 7 | |
| 2 | បាត់ដំបង | 9 | 7 | 2 | 2 | 1 | 1 | 9 | 7 | 2 | 4 | 3 | 1 | 13 | 11 | 2 | 14 | 13 | 1 |
| 3 | កំពង់ចាម | 11 | 2 | 9 | 6 | | 6 | 12 | 2 | 10 | 8 | | 8 | 22 | 10 | 12 | 13 | | 13 |
| 4 | កំពង់ឆ្នាំង | 2 | 2 | | 4 | 2 | 2 | 2 | 2 | | 5 | 2 | 3 | 2 | 2 | | 8 | 5 | 3 |
| 5 | កំពង់ស្ពឺ | 1 | | 1 | | | | 1 | | 1 | | | | 3 | | 3 | | | |
| 6 | កំពង់ធំ | | | | 5 | 1 | 4 | | | | 6 | 1 | 5 | | | | 16 | 6 | 10 |
| 7 | កំពត | | | | | | | | | | | | | | | | | | |
| 8 | កណ្ដាល | 3 | 1 | 2 | 1 | 1 | | 4 | 2 | 2 | 1 | 1 | | 13 | 9 | 4 | 1 | 1 | |
| 9 | កោះកុង | 4 | 2 | 2 | 2 | 2 | | 6 | 3 | 3 | 2 | 2 | | 33 | 8 | 25 | 8 | 8 | |
| 10 | ក្រចេះ | | | | | | | | | | | | | | | | | | |
| 11 | មណ្ឌលគិរី | | | | | | | | | | | | | | | | | | |
| 12 | ភ្នំពេញ | 21 | 11 | 10 | 22 | 12 | 10 | 35 | 14 | 21 | 37 | 12 | 25 | 63 | 25 | 38 | 56 | 31 | 25 |
| 13 | ព្រះវិហារ | | | | 1 | | 1 | | | | 1 | | 1 | | | | 1 | | 1 |
| 14 | ព្រៃវែង | 1 | 1 | | 1 | | 1 | 1 | 1 | | 1 | | 1 | 2 | 2 | | 2 | | 2 |
| 15 | ពោធិ៍សាត់ | | | | | | | | | | | | | | | | | | |
| 16 | រតនគិរី | 1 | | 1 | | | | 1 | | 1 | | | | 4 | | 4 | | | |
| 17 | សៀមរាប | 3 | 1 | 2 | 8 | 5 | 3 | 3 | 1 | 2 | 9 | 5 | 4 | 8 | 3 | 5 | 16 | 13 | 3 |
| 18 | ព្រះសីហនុ | 9 | 7 | 2 | 11 | 9 | 2 | 9 | 7 | 2 | 12 | 10 | 2 | 21 | 19 | 2 | 18 | 16 | 2 |
| 19 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | 1 | 1 | | 3 | 2 | 1 | 1 | 1 | | 8 | 5 | 3 | 1 | 1 | | 11 | 9 | 2 |
| 21 | តាកែវ | | | | 5 | 3 | 2 | | | | 5 | 3 | 2 | | | | 9 | 7 | 2 |
| 22 | ឧត្ដរមានជ័យ | 1 | | 1 | | | | 5 | | 5 | | | | 51 | | 51 | | | |
| 23 | កែប | | | | | | | | | | | | | | | | | | |
| 24 | ប៉ៃលិន | | | | 1 | | 1 | | | | 1 | | 1 | | | | 3 | | 3 |
| 25 | នាយកដ្ឋាន | 16 | 11 | 5 | 17 | 8 | 9 | 19 | 14 | 5 | 22 | 10 | 12 | 59 | 47 | 12 | 96 | 55 | 41 |
| 26 | កងរាជអាវុធហត្ថ | 5 | 5 | | 9 | 9 | | 12 | 12 | | 11 | 11 | | 33 | 33 | | 14 | 14 | |
| 27 | ត្បូងឃ្មុំ | | | | 4 | | 4 | | | | 7 | | 7 | | | | 2 | | 2 |
| | **សរុបរួម** | 95 | 54 | 41 | 105 | 58 | 47 | 127 | 69 | 58 | 144 | 69 | 75 | 412 | 182 | 230 | 295 | 185 | 110 |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គស្នងការដ្ឋាននគរបាលជាតិ
នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌
នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស
និងការពារអនីតិជន

## បញ្ជីឈ្មោះជនល្មើសជាជនបរទេស ដែលបានឃាត់ខ្លួន (ឆ្នាំ២០១៥)
## គិតចាប់ពីថ្ងៃទី ២៦-១២-២០១៤ ដល់ថ្ងៃទី ២៥-១២-២០១៥

| ល.រ | ឈ្មោះជនល្មើស | ភេទ | អាយុ | ជនជាតិ | បទល្មើស | ថ្ងៃប្រព្រឹត្ត | ទីកន្លែងប្រព្រឹត្ត | ថ្ងៃឃាត់ | អង្គភាពឃាត់ | ថ្ងៃឃុំខ្លួន |
|---|---|---|---|---|---|---|---|---|---|---|
| ១ | Xie Tao Sheng | ប្រុស | ៥០ | ចិន | អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ២៦-១២-២០១៤ | ភ្នំពេញ-ចំការមន | ២៦-១២-២០១៤ | ភ្នំពេញ | ២៧-១២-២០១៤ |
| ២ | Hu De Hua | ប្រុស | ៣៥ | ចិន | អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ២៦-១២-២០១៤ | ភ្នំពេញ-ចំការមន | ២៦-១២-២០១៤ | ភ្នំពេញ | ២៧-១២-២០១៤ |
| ៣ | Zhou Yanping | ស្រី | ៤១ | ចិន | អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ២៦-១២-២០១៤ | ភ្នំពេញ-ចំការមន | ២៦-១២-២០១៤ | ភ្នំពេញ | ២៧-១២-២០១៤ |
| ៤ | PEDRO TIKH | ប្រុស | ៤៦ | រុស្ស៊ី | ការទិញពេស្យាចារកុមារ | ១៦-១១-២០១៤ | សៀមរាប-សៀមរាប | ២៦-១២-២០១៤ | សៀមរាប | ២៦-១២-២០១៤ |
| ៥ | YU CHONG | ប្រុស | ៤៤ | ចិន | អំពើលក់ដូរមនុស្ស | ១១-១២-២០១៤ | ចិន | ១១-០២-២០១៥ | តាកែវ | ១៤-០២-២០១៥ |
| ៦ | SHIN JANG EUN | ប្រុស | ៤៣ | កូរ៉េ | ការទិញពេស្យាចារកុមារ | ២៥-១២-២០១៤ | សៀមរាប-សៀមរាប | ២៨-០២-២០១៥ | សៀមរាប | ២៨-០២-២០១៥ |
| ៧ | RAMEL PIRMIM | ប្រុស | ៣២ | ស្វីស | អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១-០១-២០១៥ | សៀមរាប-សៀមរាប | ១២-០៣-២០១៥ | សៀមរាប | ១៣-០៣-២០១៥ |
| ៨ | លី ស៊ាវពីង | ស្រី | ៥២ | ចិន | ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០៨-០៣-២០១៥ | ត្បូងឃ្មុំ-តំបែរ | ២១-០៣-២០១៥ | ត្បូងឃ្មុំ | ២៤-០៣-២០១៥ |
| ៩ | ROBERT ANTHONY HAYS | ប្រុស | ៥៦ | អាមេរិច | អំពើអាសអាភាសលើអនីតិជនអាយុក្រោម១៥ឆ្នាំ | ១៨-០៥-២០១២ | ព្រះសីហនុ-ព្រះសីហនុ | ០៥-០៥-២០១៥ | ព្រះសីហនុ | ០៥-០៥-២០១៥ |
| ១០ | Brian Davit Naswall | ប្រុស | ៥៣ | អាមេរិច | ការទិញពេស្យាចារកុមារ | ០១-០៧-២០១៥ | ភ្នំពេញ | ២៣-០៥-២០១៥ | នាយកដ្ឋាន | ២៧-០៥-២០១៥ |
| ១១ | BERNARDO PINA PAEZ | ប្រុស | ៥៩ | ម៉ិចស៊ិច | ការទិញពេស្យាចារកុមារ | ១០-០៦-២០១៥ | ព្រះសីហនុ-ព្រះសីហនុ | ១៤-០៦-២០១៥ | ព្រះសីហនុ | ១៦-០៦-២០១៥ |
| ១២ | BERNARD LOUIS FRANCOIS SCUDELLER | ប្រុស | ៥៥ | បារាំង | ការទិញពេស្យាចារកុមារ | ០១-០១-២០១៤ | កណ្តាល-ស្អាង | ១៥-០៦-២០១៥ | នាយកដ្ឋាន | ១៨-០៦-២០១៥ |
| ១៣ | UDO SABINIE WICZ | ប្រុស | ៥៦ | អាល្លឺម៉ង់ | អំពើអាសអាភាសលើអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១-០៦-២០១៥ | ភ្នំពេញ-មានជ័យ | ១៦-០៦-២០១៥ | ភ្នំពេញ | ១៩-០៦-២០១៥ |
| ១៤ | BEJENARI LUIDMILA | ស្រី | ២៦ | ម៉ុលដូវី | ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ១៩-០៦-២០១៥ | ភ្នំពេញ-ដូនពេញ | ១៩-០៦-២០១៥ | នាយកដ្ឋាន | ២២-០៦-២០១៥ |
| ១៥ | Cao Vuhua | ប្រុស | ៤២ | ចិន | ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០៩-០៩-២០១៥ | ភ្នំពេញ-៧មករា | ០៩-០៩-២០១៥ | ភ្នំពេញ | ០៩-១២-២០១៥ |
| ១៦ | SHEPPARD ROY | ប្រុស | ៧៦ | អង់គ្លេស | អំពើអាសអាភាសលើអនីតិជនអាយុក្រោម១៥ឆ្នាំ | ១៥-១០-២០១៥ | សៀមរាប-សៀមរាប | ២៩-១០-២០១៥ | សៀមរាប | ២៩-១០-២០១៥ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១៧ | YANG YONGDON | ប្រុស | ៤២ | ចិន | ការនាំយកអនីតិជន ជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០១-០៣-២០១៥ | ព្រះសីហនុ-ព្រះសីហនុ | ១៦-០៧-២០១៥<br>ដីកាលេខ: ៨៣៥តព្រ/១៥<br>ចុះថ្ងៃទី: ២២/០៦/២០១៥ | ព្រះសីហនុ | ១៦-០៧-២០១៥ |

**លទ្ធផលបង្ក្រាបជនបរទេសដែលបានប្រព្រឹត្តបទល្មើសអាជីវកម្មផ្លូវភេទ និងអំពើជួញដូរមនុស្ស ទូទាំងប្រទេស (២០១៥)**
**គិតចាប់ពីថ្ងៃទី ២៦-១២-២០១៤ ដល់ថ្ងៃទី ២៥-១២-២០១៥**

| ល.រ | ជនជាតិ | បង្ក្រាបរួម | | | | | | | អាជីវកម្មផ្លូវភេទ | | | | | | | ជួញដូរមនុស្ស | | | | | | | បញ្ជូនជនរងគ្រោះទៅ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បង្ក្រាបរួម | ជនល្មើស | | ជនរងគ្រោះ | | | | បង្ក្រាប | ជនល្មើស | | ជនរងគ្រោះ | | | | បង្ក្រាប | ជនល្មើស | | ជនរងគ្រោះ | | | | មន្ទីរសង្គមកិច្ច | អង្គការ | គ្រួសារ |
| | | | រួម | ស្រី | រួម | -15 | 15-17 | 18+ | | រួម | ស្រី | រួម | -15 | 15-17 | 18+ | | រួម | ស្រី | រួម | -15 | 15-17 | 18+ | | | |
| 1 | កូរ៉េ | 1 | 1 | | 1 | | 1 | | | | | | | | | 1 | 1 | | 1 | | 1 | | | | 1 |
| 2 | ចិន | 4 | 6 | 2 | 9 | | | 9 | | | | | | | | 4 | 6 | 2 | 9 | | | 9 | | 1 | 8 |
| 3 | បារាំង | 1 | 1 | | 15 | 15 | | | | | | | | | | 1 | 1 | | 15 | 15 | | | | | 15 |
| 4 | ម៉ិចសិច | 1 | 1 | | 2 | 1 | 1 | | | | | | | | | 1 | 1 | | 2 | 1 | 1 | | | | 2 |
| 5 | ម៉ុលដូវី | 1 | 1 | 1 | 2 | | | 2 | | | | | | | | 1 | 1 | 1 | 2 | | | 2 | 2 | | |
| 6 | ស្វេស | 1 | 1 | | 2 | | 2 | | | | | | | | | 1 | 1 | | 2 | | 2 | | | | 2 |
| 7 | ស៊ីស | 1 | 1 | | 3 | 3 | | | 1 | 1 | | 3 | 3 | | | | | | | | | | | | 3 |
| 8 | អង់គ្លេស | 1 | 1 | | 3 | 3 | | | 1 | 1 | | 3 | 3 | | | | | | | | | | | | 3 |
| 9 | អាមេរិច | 2 | 2 | | 8 | 7 | 1 | | 1 | 1 | | 3 | 3 | | | 1 | 1 | | 5 | 4 | 1 | | | | 8 |
| 10 | អាល្លឺម៉ង់ | 1 | 1 | | 5 | 5 | | | 1 | 1 | | 5 | 5 | | | | | | | | | | | | 5 |
| | សរុបរួម | 14 | 16 | 3 | 50 | 34 | 5 | 11 | 4 | 4 | | 14 | 14 | | | 10 | 12 | 3 | 36 | 20 | 5 | 11 | 2 | 1 | 47 |

# កម្រងរូបភាពសកម្មភាពទិវាជាតិ១២ធ្នូ ឆ្នាំ២០១៥






















រួមគ្នាប្រយុទ្ធ
ប្រឆាំងអំពើ
ជួញដូរមនុស្ស៖
យល់ដឹង! ប្រុងស្មារតី!
ធ្វើសកម្មភាព!
We together
combat trafficking
in persons:
Awareness!Attention!
Action!
អបអរសាទរ!
ទិវាជាតិ
ប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស
១២ធ្នូ ឆ្នាំ២០១៥!
Congratulation!
The Celebration
































POLICE
















អបអរសាទរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
១២ ធ្នូ ២០១៥

# របាយការណ៍វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីដឹកនាំក្នុងរចនាសម្ព័ន្ធ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ក្រោមជាតិ

## ដែលអគ្គលេខាធិការដ្ឋាន គ.ជ. ប.ជ បានចុះអនុវត្តទូទាំង២៥ រាជធានី ខេត្ត

## ពីថ្ងៃទី១៤ ខែកក្កដា ដល់ ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៥



អនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជក្នុងកិច្ចប្រជុំឆមាស ទី១ ឆ្នាំ ២០១៥ នៅក្រសួងមហាផ្ទៃ ៖

"មានគោលការណ៍ល្អយ៉ាងណាក៏ដោយ ប៉ុន្តែបើមិនមានយន្តការ ឬគ្មានការចាត់តាំងអនុវត្ត នោះគឺជាយន្តការដែលមិនមានប្រសិទ្ធភាព និងគ្មានលទ្ធផល"

វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីដឹកនាំ ក្នុងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី ខេត្ត ទាំង២៥ ៖

- ចាប់ផ្តើមពីថ្ងៃទី ១៤-១៥ ខែកក្កដា ឆ្នាំ២០១៥ នៅខេត្តកោះកុង
- និងបិទបញ្ចប់ នៅថ្ងៃទី ២៦-២៧ ខែសីហា ឆ្នាំ២០១៥ នៅខេត្តព្រៃវែង

អ្នកចូលរួមជាអភិបាល អភិបាលរង រាជធានី ខេត្ត អនុប្រធានតុលាការ ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង មន្ត្រីលេខាធិការដ្ឋាន ប្រធាន អនុប្រធានមន្ទីរក្រោមឱវាទ ស្នងការ ស្នងការរងទទួលបន្ទុកការងារប្រឆាំងការជួញដូរមនុស្ស មេបញ្ជាការ មេបញ្ជាការរង អាវុធហត្ថរាជធានី ខេត្ត កម្លាំងឈរជើងក្នុងខេត្ត និងតាមច្រកព្រំដែន អភិបាល អភិបាលរង ក្រុង ស្រុក ខណ្ឌ អធិការ អធិការរង ទូទាំង ២៥ រាជធានី ខេត្ត ៖

សរុបសិក្ខាកាមទាំងអស់៖ **<u>១.៤៧៤នាក់ ស្រី ៤៧៨នាក់</u>** ។

គ្រូបង្គោលជាមន្ត្រីបច្ចេកទេស នៃបណ្តាក្រុមការងារជំនាញទាំង៦ របស់អគ្គលេខាធិការដ្ឋាន ដែលបានទទួលការបណ្តុះបណ្តាលរួច ចំនួន **៣០នាក់** ចែកចេញជា ៦ក្រុម ក្រោមការគ្រប់គ្រងរបស់ អគ្គលេខាធិការរងទទួលបន្ទុក ក្រោមការដឹកនាំផ្ទាល់ និងពិនិត្យតាមដាន ពីអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងអគ្គលេខាធិការ ។

១.វគ្គបណ្តុះបណ្តាលខេត្តកោះកុង ថ្ងៃទី ១៨-១៩ ខែកក្កដា ឆ្នាំ២០១៩
សិក្ខាកាមចូលរួម ៣៨នាក់ ស្រី១២នាក់




២.វគ្គបណ្តុះបណ្តាលខេត្តព្រះសីហនុ ថ្ងៃទី ១៦-១៧ ខែកក្កដា ឆ្នាំ២០១៩
សិក្ខាកាមចូលរួម ៤២នាក់ ស្រី១៣នាក់




៣.វគ្គបណ្តុះបណ្តាលខេត្ត កំពង់ចាម ថ្ងៃទី ២២-២៣ ខែកក្កដា ឆ្នាំ២០១៩
សិក្ខាកាមចូលរួម ៤២នាក់ ស្រី១៦នាក់




៤.វគ្គបណ្តុះបណ្តាលខេត្ត ស្វាយរៀង ថ្ងៃទី ២៦-២៧ ខែកក្កដា ឆ្នាំ២០១៩
សិក្ខាកាមចូលរួម ៩២នាក់ ស្រី១៨នាក់




៥.វគ្គបណ្ដុះបណ្ដាលខេត្តបាត់ដំបង ថ្ងៃទី ២៨-២៩ ខែកក្កដា ឆ្នាំ២០១៥
សិក្ខាកាមចូលរួម ៥៩នាក់ ស្រី២២នាក់





៦.វគ្គបណ្ដុះបណ្ដាលខេត្តកំពត ថ្ងៃទី ៣០-៣១ ខែកក្កដា ឆ្នាំ២០១៥
សិក្ខាកាមចូលរួម ៤៧នាក់ ស្រី១៥នាក់





៧.វគ្គបណ្ដុះបណ្ដាលខេត្តកំពង់ឆ្នាំង ថ្ងៃទី ៣០-៣១ ខែកក្កដា ឆ្នាំ២០១៥
សិក្ខាកាមចូលរួម ៥៣នាក់ ស្រី២៨នាក់





៨.វគ្គបណ្ដុះបណ្ដាលខេត្តស្ទឹងត្រែង ថ្ងៃទី ៣០-៣១ ខែកក្កដា ឆ្នាំ២០១៥
សិក្ខាកាមចូលរួម ៥៦នាក់ ស្រី០៩នាក់





៩.វគ្គបណ្តុះបណ្តាលខេត្តរតនៈគីរី  ថ្ងៃទី ០៣-០៤ ខែសីហា ឆ្នាំ២០១៥
សិក្ខាកាមចូលរួម ៤២នាក់ ស្រី១៥នាក់





១០.វគ្គបណ្តុះបណ្តាលខេត្តប៉ៃលិន  ថ្ងៃទី  ០៣-០៤ ខែសីហា ឆ្នាំ២០១៥
សិក្ខាកាមចូលរួម ៥៨នាក់ ស្រី១៨នាក់





១១.វគ្គបណ្តុះបណ្តាលខេត្តសៀមរាប ថ្ងៃទី ០៣-០៤ ខែសីហា ឆ្នាំ២០១៥
សិក្ខាកាមចូលរួម៥៧នាក់ ស្រី០៥នាក់






១២.វគ្គបណ្តុះបណ្តាលខេត្តកំពង់ស្ពឺ ថ្ងៃទី ០៤-០៥ ខែសីហា ឆ្នាំ២០១៥
សិក្ខាកាមចូលរួម ៤៩នាក់ ស្រី២១នាក់





១៣.វគ្គបណ្តុះបណ្តាលខេត្តកំពង់ធំ ថ្ងៃទី ០៥-០៦ ខែសីហា ឆ្នាំ២០១៩
សិក្ខាកាមចូលរួម ៥០នាក់ ស្រី១៦នាក់




១៤.វគ្គបណ្តុះបណ្តាលខេត្តកែប ថ្ងៃទី ០៦-០៧ ខែសីហា ឆ្នាំ២០១៩
សិក្ខាកាមចូលរួម ៨២នាក់ ស្រី០៥នាក់




១៥.វគ្គបណ្តុះបណ្តាលខេត្តក្រចេះ ថ្ងៃទី ០៦-០៧ ខែសីហា ឆ្នាំ២០១៩
សិក្ខាកាមចូលរួម ៩២នាក់ ស្រី០៨នាក់




១៦.វគ្គបណ្តុះបណ្តាលខេត្តបន្ទាយមានជ័យ ថ្ងៃទី ០៦-០៧ ខែសីហា ឆ្នាំ២០១៩
សិក្ខាកាមចូលរួម ៦៨នាក់ ស្រី១៦នាក់




១៧.វគ្គបណ្តុះបណ្តាលខេត្តត្បូងឃ្មុំ ថ្ងៃទី ១០-១១ ខែសីហា ឆ្នាំ២០១៥
សិក្ខាកាមចូលរួម ៥៣នាក់ ស្រី០៧នាក់





១៨.វគ្គបណ្តុះបណ្តាលខេត្តពោធិសាត់ ថ្ងៃទី ១១-១២ ខែសីហា ឆ្នាំ២០១៥
សិក្ខាកាមចូលរួម ៤៨នាក់ ស្រី២១នាក់





១៩.វគ្គបណ្តុះបណ្តាលខេត្តកណ្តាល ថ្ងៃទី ១៣-១៤ ខែសីហា ឆ្នាំ២០១៥
សិក្ខាកាមចូលរួម ១០៥នាក់ ស្រី២៨នាក់






២០.វគ្គបណ្តុះបណ្តាលខេត្តមណ្ឌលគិរី ថ្ងៃទី ១៣-១៤ ខែសីហា ឆ្នាំ២០១៥
សិក្ខាកាមចូលរួម ៤៦នាក់ ស្រី១៣នាក់





២១.វគ្គបណ្តុះបណ្តាលខេត្តតាកែវ ថ្ងៃទី ១៩-២០ ខែសីហា ឆ្នាំ២០១៥
សិក្ខាកាមចូលរួម ៨៣នាក់ ស្រី១៨នាក់






២២.វគ្គបណ្តុះបណ្តាលខេត្តឧត្តរមានជ័យ ថ្ងៃទី ១៩-២០ ខែសីហា ឆ្នាំ២០១៥
សិក្ខាកាមចូលរួម ៨៦នាក់ ស្រី២៣នាក់





២៣.វគ្គបណ្តុះបណ្តាលខេត្តព្រះវិហារ ថ្ងៃទី ២០-២១ ខែសីហា ឆ្នាំ២០១៥
សិក្ខាកាមចូលរួម ៨៧នាក់ ស្រី១៦នាក់





២៨.វគ្គបណ្តុះបណ្តាលរាជធានីភ្នំពេញ ថ្ងៃទី ២៨-២៩ ខែសីហា ឆ្នាំ២០១៥
ដែលមានសមាសភាពចូលរួម ១៦៣នាក់ ស្រី៧៨នាក់









២៥.វគ្គបណ្តុះបណ្តាលខេត្តព្រៃវែង ថ្ងៃទី ២៦-២៧ ខែសីហា ឆ្នាំ២០១៥
សិក្ខាកាមចូលរួម ៦៦នាក់ ស្រី២៥នាក់





**សកម្មភាពបង្ក្រាបទប់ស្កាត់ (ខេត្តបន្ទាយមានជ័យ)**

នគរបាលប៉ុស្តិ៍អូរបីជាន់ ស្រុកអូរជ្រៅ សហការជាមួយ ការិយាល័យ ប្រឆាំងការជួញដូរ និងរ:ការពារព្រំដែន ៩១១ ចុះទប់ស្កាត់ និងអប់រំពលករ បំរុងចំណាកស្រុក




បណ្តាញអ្នកដោះមីន អ្នកស្ម័គ្រចិត្តភូមិ ក្រុមកាកបាទក្រហមឃុំ និងប៉ុស្តិ៍នគរបាលរដ្ឋបាល ឃុំស្វាយចេក ចុះផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុក និងការជួញដូរមនុស្ស នៅភូមិចំការគឃុំចំការគស្រុកស្វាយចេក ខេត្ត







ការបញ្ជូនពលករត្រឡប់ពីប្រទេសថៃដោយអាជ្ញាធរថៃជាប្រចាំ តាមច្រកអន្តរជាតិប៉ោយប៉ែត





ខេត្តស្វាយរៀង៖ ការបញ្ជ្រាបការផ្សព្វផ្សាយអំពី ការយល់ដឹងអំពីការជួញដូរមនុស្ស ក្នុងវេទិកាភូមិឃុំមានសុវត្ថិភាព របស់ស្នងការដ្ឋាននគរបាលខេត្តនិងក្រុមការងារខេត្ត ស្រុកនៅឃុំសម្បត្តិមានជ័យស្រុករមាសហែក




សកម្មភាពវគ្គបណ្តុះបណ្តាលបន្ត ដល់ក្រុមការងារប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក និងឃុំ សង្កាត់








ខេត្តកណ្តាល៖ យុទ្ធនាការអប់រំបង្ការទប់ស្កាត់ និងប្រឆាំងអំពើជួញដូរមនុស្ស នៅឃុំសំពៅពូន ស្រុកកោះធំ






កិច្ចប្រជុំប្រកាសសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
ស្រុកពញាឮ និង ឃុំទាំង១១ ស្រុកខ្សាច់កណ្តាល ស្រុកមុខកំពូល ស្រុកលើកដែក និងស្រុកមួយចំនួនទៀត








## ខេត្តសៀមរាប

ការងារផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋ តាមសហគមន៍ មូលដ្ឋានភូមិ ឃុំ សង្កាត់





សកម្មភាពបង្ក្រាប





## ខេត្តបាត់ដំបង៖

សកម្មភាពផ្សព្វផ្សាយ អប់រំ និងយុទ្ធនាការបង្ការទប់ស្កាត់









ខេត្តកំពង់ចាមៈ យុទ្ធនាការផ្សព្វផ្សាយអប់រំ





ខេត្តពោធិសាត់







រាជធានីភ្នំពេញៈ សកម្មភាពបង្ក្រាប

















រៀបចំសហការដោយ:










**រីករាយ ចូលរួម ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទាំងអស់គ្នា !**